# ស្ថានភាពពន្ធនាគារ
# នៅកម្ពុជា



របាយការណ៍ដោយមជ្ឈមណ្ឌលនៃអង្គការសហប្រជាជាតិ

ដើម្បីសិទ្ធិមនុស្ស

ការិយាល័យប្រចាំនៅកម្ពុជា

# បញ្ជីមាតិកា


| | | |
|---|---|---|
| មជ្ឈមណ្ឌល អ.ស.ប. ដើម្បីសិទ្ធិមនុស្ស | | i |
| ការទទួលស្គាល់ | | ii |
| ពាក្យកាត់ដែលបានប្រើ | | iii |
| ពន្ធនាគារដែល" ក្រុមកម្មវិធីផ្តល់ជំនួយខាងពន្ធនាគារ" បានចុះទៅពិនិត្យមើល | | iv |
| | កថាខណ្ឌ | ទំព័រ |
| ជំពូក ១ ស្ថានភាពពន្ធនាគារនៅកម្ពុជា | ១-១២ | ១-៧ |
| ជំពូក ២ កម្មវិធីផ្តល់ជំនួយពន្ធនាគារ : | | |
| ការបណ្តុះបណ្តាល ការស្រាវជ្រាវ និងការចេញធ្វើសកម្មភាព | ១៣-១៤ | ៨-១៤ |
| ជំពូក ៣ ចំនួនពន្ធនាគារ : តើពន្ធនាគារទាំងអស់នៅឯណាខ្លះ ? | ២៥-៣៥ | ១៥-២៣ |
| ជំពូក ៤ ការគ្រប់គ្រងពន្ធនាគារ និងបុគ្គលិកពន្ធនាគារ : | | |
| រកមើលព្រៃដើម្បីសំគាល់ដើមឈើទុក | ៣៦-៤៧ | ២៤-៣១ |
| ជំពូក ៥ ស្ថានភាព : ចាប់វាឲ្យជាប់កុំឲ្យវាធ្លាក់ទាន់ | ៤៨-៦៨ | ៣២-៤៧ |
| ជំពូក ៦ ការត្រួតពិនិត្យពន្ធនាគារ | ៦៩-៨០ | ៤៨-៥៥ |
| ជំពូក ៧ ការទាក់ទង : ការចាំបាច់ត្រូវមានការច្បាស់លាស់ | ៨១-៩២ | ៥៦-៦០ |
| ជំពូក ៨ ពន្ធនាគារ PJ : តើអ្វីៗអាចខុសយ៉ាងដូចម្តេច ? | ៩៣-១១៤ | ៦១-៦៨ |
| ជំពូក ៩ សៀមរាប : ទីណាមានវត្ថុបំណង ទីនោះមានមធ្យោបាយ | ១១៥-១២៤ | ៦៨-៧១ |
| **អនុសាសន៍** | | |
| កម្មវិធីអក្ខរកម្ម | ១(១.១-១.៣) | ៧១ |
| ពិធីសារស្តីពីសន្តិសុខ និងកាំភ្លើង | ២(២.១-២.៣) | ៧១-៧២ |
| បញ្ញត្តិច្បាប់សំរាប់ពន្ធនាគារ | ៣(៣.១-៣.៥) | ៧២-៧៣ |
| សុខភាពនៅពន្ធនាគារ និងសេវាខាងពេទ្យ | ៤(៤.១-៤.១៤) | ៧៣-៧៤ |

| | | |
|---|---|---|
| ការសាងសង់ពន្ធនាគារឡើងវិញ | ៥(៥.១-៥.៣) | ៧៤-៧៥ |
| ការបំបែកចេញដោយឡែកពីគ្នា | ៦(៦.១-៦.៥) | ៧៥ |
| បញ្ជីពន្ធនាគារ និងឯកសារ | ៧(៧.១-៧.២) | ៧៥ |
| គ្រឿងប្រដាប់សំរាប់ដេក សំលៀកបំពាក់ និងការភស្តុភារសំរាប់អ្នកទោស | ៨(៨.១-៨.៣) | ៧៥-៧៦ |
| ចំណីអាហារ | ៩(៩.១-៩.៦) | ៧៦ |
| ការហាត់ប្រាណ និងកីឡា | ១០(១០.១-១០.២) | ៧៦-៧៧ |
| វិន័យ និងទណ្ឌកម្ម | ១១(១១.១-១១.២) | ៧៧ |
| ទំនាក់ទំនងជាមួយមជ្ឈដ្ឋានខាងក្រៅ | ១២(១២.១-១២.៩) | ៧៧-៧៨ |
| បុគ្គលិកពន្ធនាគារ | ១៣(១៣.១-១៣.១) | ៧៨ |
| អធិការកិច្ច | ១៤(១៤.១-១៤.៣) | ៧៨-៧៩ |
| ការងារ | ១៥(១៥.១-១៥.៤) | ៧៩ |
| រដ្ឋបាល | ១៦(១៦.១-១៦.១) | ៧៩-៨០ |
| ច្បាប់ | ១៧(១៧.១-១៧.១) | ៨០ |
| ការលួចចេញ | ១៨(១៨.១-១៨.៣) | ៨០ |
| ការផ្ទេរអ្នកទោស | ១៩(១៩.១-១៩.១) | ៨០ |
| ស្ត្រី | ២០(២០.១-២០.៨) | ៨០-៨១ |
| យុវជន | ២១(២១.១-២១.៣) | ៨១ |
| ការបិទពន្ធនាគារT3 និងភីទៅឯពន្ធនាគារព្រៃស | ២២(២២.១-២២.២) | ៨១-៨២ |
| អនាម័យ និងអនាម័យផ្ទាល់ខ្លួន | ២៣(២៣.១-២៣.៦) | ៨២-៨៣ |
| ការឃុំឃាំងមុនពេលវិនិច្ឆ័យទោស (ការឃាត់ខ្លួន ការបង់ប្រាក់ធានា និងការសួរចម្លើយ) | ២៤(២៤.១-២៤.៣) | ៨៣ |
| កម្មវិធីកាត់ទោស និងការដោះលែងមុនកំណត់ | ២៥(២៥.១-២៥.១) | ៨៣ |
| ពន្ធនាគារ PJ | ២៦(២៦.១-២៦.២) | ៨៤ |
| នីតិក្រមធ្វើពាក្យបណ្តឹង | ២៧(២៧.១-២៧.៣) | ៨៤ |
| អ្នកទោសបរទេស | ២៨(២៨.១-២៨.១) | ៨៤ |

ឧបសម្ព័ន្ធ


| | | |
|---|---|---|
| ឧបសម្ព័ន្ធ | I | ៨៥-៨៨ |
| ឧបសម្ព័ន្ធ | II | ៨៩-៩៦ |
| ឧបសម្ព័ន្ធ | III | ៩៧-១៣១ |
| ឧបសម្ព័ន្ធ | IV | ១៣២-១៣៥ |
| ឧបសម្ព័ន្ធ | V | ១៣៦-១៤៥ |
| ឧបសម្ព័ន្ធ | VI | ១៤៦-១៤៧ |
| ឧបសម្ព័ន្ធ | VII | ១៤៨-១៤៩ |
| ឧបសម្ព័ន្ធ | VIII | ១៥០ |
| ឧបសម្ព័ន្ធ | IX | ១៥១-១៥៣ |
| ឧបសម្ព័ន្ធ | X | ១៥៤ |

# មជ្ឈមណ្ឌល អ.ស.ប ដើម្បីសិទ្ធិមនុស្ស
# ការិយាល័យសំរាប់ចុះសញ្ញាជាក់ស្តែងនៅប្រទេសកម្ពុជា

មជ្ឈមណ្ឌល អ.ស.ប. ដើម្បីសិទ្ធិមនុស្ស គឺជាសាខាមួយរបស់លេខាធិការដ្ឋាន អ.ស.ប. ដែលផ្តល់សេវាកម្មដល់អង្គការនានារបស់ អ.ស.ប. ដែលទទួលបន្ទុកសិទ្ធិមនុស្ស និងជួយរដ្ឋទាំងឡាយជាសមាជិកទាក់ទិននឹងបញ្ហាបែបនេះ ។

នៅថ្ងៃទី ២០ ធ្នូ ១៩៩៣ ផ្អែកតាមសេចក្តីសំរេចលេខ 48/154 ក្រោមចំណងជើងថា "សភាពការណ៍សិទ្ធិមនុស្សនៅកម្ពុជា" មហាសន្និបាត អ.ស.ប. ដោយបានរំឭកពីសេចក្តីសំរេចចិត្តពីខាងដើមលេខ 93/6 របស់គណៈកម្មការ អ.ស.ប. ស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី ១៩ កុម្ភៈ ១៩៩៣ បានទទួលស្វាគមន៍ការបង្កបង្កើតឲ្យមាននៅក្នុងប្រទេសកម្ពុជា នូវវត្តមានរបស់មជ្ឈមណ្ឌល អ.ស.ប. ដើម្បីសិទ្ធិមនុស្ស ដើម្បីដំណើរការការងារ បន្ទាប់ពីអ៊ុនតាក់បានចប់បេសកកម្មចេញពីកម្ពុជាវិញ ។ អាណត្តិសំរាប់ឲ្យមជ្ឈមណ្ឌលនេះដំណើរការនៅកម្ពុជា មានកំណត់ដូចតទៅនេះ ៖

ក. គ្រប់គ្រងការអនុវត្តន៍កម្មវិធីអប់រំ និងជួយបច្ចេកទេស និងកម្មវិធីផ្តល់សេវាខាងកិច្ចការឲ្យយោបល់ និងធានានូវការបន្តឲ្យមានកម្មវិធីទាំងនេះតទៅទៀត.

ខ. ជួយដល់រដ្ឋាភិបាលកម្ពុជា ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនតាមឯកសារទាំងឡាយ ស្តីពីសិទ្ធិមនុស្ស ដែលទើបតែបានរួមសច្ចាប័ន រួមមានរបាយការណ៍នានាទាក់ទងដល់គណៈកម្មាធិការតាមដាន ក្នុងកិច្ចការដែលជាប់ទាក់ទិន.

គ. ផ្តល់ការគាំទ្រដល់ក្រុមសិទ្ធិមនុស្សពិតប្រាកដ នៅក្នុងប្រទេសកម្ពុជា.

ឃ. រួមវិភាគទានក្នុងការបង្កើត និង / ឬការពង្រឹងស្ថាប័នជាតិ សំរាប់ការជំរុញលើកកំពស់ និងការការពារសិទ្ធិមនុស្ស.

ង. បន្តជួយក្នុងការធ្វើពង្រាង និងការអនុវត្តន៍ ដើម្បីលើកកំពស់ និងការពារសិទ្ធិមនុស្ស.

ច. បន្តជួយក្នុងការហ្វឹកហ្វឺនអ្នកទទួលខុសត្រូវ លើការគ្រប់គ្រងច្បាប់តុលាការ ។

មជ្ឈមណ្ឌល អ.ស.ប. ដើម្បីសិទ្ធិមនុស្ស ត្រូវបង្កើតឲ្យមាននៅទីក្រុងភ្នំពេញ នៅថ្ងៃទី ១ តុលា ១៩៩៣ ។ នៅថ្ងៃទី ២៣ វិច្ឆិកា ១៩៩៣ លោក Justice Michael Kirby នៃប្រទេសអូស្ត្រាលី ត្រូវចាត់តាំងជាតំណាងពិសេសរបស់លោកអគ្គលេខាធិការ អ.ស.ប. ខាងកិច្ចការសិទ្ធិមនុស្សនៅប្រទេសកម្ពុជា ។

របាយការណ៍ដែលដាក់ជូនមកនេះ គឺដោយអនុលោមតាមអាណត្តិនេះ ។

## ការទទួលស្គាល់

មជ្ឈមណ្ឌល អ.ស.ប. ដើម្បីសិទ្ធិមនុស្ស (UNCHR) សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម ស ខេង និងឯកឧត្តម យូ ហុកគ្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងឯកឧត្តម ចែម ស្នួន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបានជួយទ្រទ្រង់ និងជួយជំរុញលើកទឹកចិត្តដល់កម្មវិធីផ្តល់ជំនួយខាងពន្ធនាគារ ។ យើងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះបុគ្គលិកក្នុងនាយកដ្ឋានពន្ធនាគារ ក្នុងក្រសួងមហាផ្ទៃ និងជាពិសេសអតីតនាយក យិន ស្រ៊ាង នាយករង ស្រេង ស្រ៊ាង និងមន្ត្រីទទួលបន្ទុកភ្ជាប់ទំនាក់ទំនង វរសេនីយឯក លីវ វ៉ាន់លី ។ សូមថ្លែងអំណរគុណផងដែរ ចំពោះមន្ត្រីជាច្រើនរបស់រដ្ឋាភិបាល បុគ្គលិកពន្ធនាគារ មន្ត្រីតុលាការ និងតំណាងរបស់អង្គការក្រៅរដ្ឋាភិបាលដែលបានចូលរួម ដោយចំណាយពេលវេលា និងមតិយោបល់ដោយស្មោះស្ម័គ្រ ។ សូមថ្លែងអំណរគុណយ៉ាងច្រើន ចំពោះនិស្សិតរបស់យើងនៅក្នុងកម្មវិធី និងចំពោះអ្នកទោសទាំងឡាយ ដែលបាននិយាយរឿងរ៉ាវរបស់គេប្រាប់យើង ។

យើងខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះអង្គការគណៈកម្មាធិការជនភៀសខ្លួនអាមេរិក ដែលមាន
រូបលោក ស៊ិន តិមហ៊ន លោក សម សុភាព និងវេជ្ជបណ្ឌិត ហ្គេព្រៀល ជ. អធ័រមែន មកពីក្រុម
គ្រូពេទ្យសម្រាប់សិទ្ធិមនុស្ស ។

បើមានសំណូមពរចង់សាកសួរពត៌មាន សូមទាក់ទងតាមអាស័យដ្ឋាន :

ការិយាល័យសម្រាប់មុខសញ្ញាផ្ទាល់នៅកម្ពុជា
មជ្ឈមណ្ឌល អ.ស.ប. ដើម្បីសិទ្ធិមនុស្ស
ប្រអប់សំបុត្រលេខ ១០៨
ទីក្រុងភ្នំពេញ
ទូរស័ព្ទ : ៨៥៥ ១៥ ៩១ ៣៨៤៦
ហ្វាក់ : ៨៥៥ ២៣ ៦២១៧៦

## ពាក្យកាត់ដែលបានប្រើ

| | |
|---|---|
| ARC | គណៈកម្មាធិការជនភៀសខ្លួនអាមេរិក |
| ICRC | គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ |
| LICADHO | សម្ព័ន្ធកម្ពុជាដើម្បីលើកកំពស់ និងការពារសិទ្ធិមនុស្ស |
| MDM | គ្រូពេទ្យពិភពលោក |
| MJ | ក្រសួងយុត្តិធម៌ |
| MI | ក្រសួងមហាផ្ទៃ |
| PAP | កម្មវិធីផ្តល់ជំនួយខាងពន្ធនាគារ |
| PHR | គ្រូពេទ្យសំរាប់សិទ្ធិមនុស្ស |
| SMRTP | បញ្ញត្តិច្បាប់អប្បបរមាជាបទដ្ឋានសំរាប់ការប្រព្រឹត្តិចំពោះអ្នកទោស |
| SOC | រដ្ឋាភិបាលរបស់រដ្ឋកម្ពុជា |
| TCP | បញ្ញត្តិទាក់ទងនឹងច្បាប់តុលាការ និងច្បាប់ព្រហ្មទណ្ឌ និងនីតិវិធី ដែលអាចអនុវត្តបាននៅកម្ពុជា ក្នុងរយៈពេលអន្តរកាល ឆ្នាំ១៩៩២ |
| UNCHR | មជ្ឈមណ្ឌល អ.ស.ប. ដើម្បីសិទ្ធិមនុស្ស |
| UNTAC | អាជ្ញាធរបណ្តោះអាសន្នរបស់ អ.ស.ប. នៅកម្ពុជា |
| WATSAN | កម្មវិធីទឹក និងអនាម័យ របស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ នៅតាមពន្ធនាគារ នៅកម្ពុជា ។ |




* ពន្ធនាគារដែលក្រុម "កម្មវិធីផ្តល់ជំនួយខាងពន្ធនាគារ" បានចុះទៅពិនិត្យមើល ។

ភ្នំពេញ : ពន្ធនាគារ ៣

## ជំពូក ១

## សេចក្តីផ្តើម : ស្ថានភាពពន្ធនាគារនៅកម្ពុជា

១. ពន្ធនាគារទាំងឡាយនៅកម្ពុជា ស្ថិតនៅក្នុងស្ថានភាពមានវិបត្តិ ។ ការគ្រប់គ្រងច្បាប់ព្រហ្មទណ្ឌ មានភាពច្របូកច្របល់ ។ អាគារទាំងឡាយនៃពន្ធនាគារ បើនិយាយឲ្យចំទៅកំពុងតែបែកបាក់ធ្លាក់ចុះទ្រុឌទ្រោម ។ កិច្ចការថែទាំសុខភាព ច្រើនតែគ្មាន ហើយជម្ងឺ និងអាហារមិនគ្រប់គ្រាន់ កំពុងតែរីករាលដាលគ្មានទីកំណត់ ។



បន្ទប់តូចៗនៅជាប់គ្នាជាទីឃុំឃាំង-ពន្ធនាគារតាខ្មៅ

២. សារៈសំខាន់នៃពន្ធនាគារ ចំពោះអ្នកដែលមានការយកចិត្តទុកដាក់ក្នុងវិស័យសិទ្ធិមនុស្ស និងក្នុងការគ្រប់គ្រងច្បាប់តុលាការ មិនអាចឲ្យគេព្រងើយកន្តើយបានទេ ។ វាជាចំណុចសំខាន់ ដែលឆ្លងតាមចំណុចនោះ គេអាចមើលឃើញដំណើររៀបចំអនុវត្តប្រព័ន្ធច្បាប់តុលាការ ដូចដែលវាមាននៅទីនេះ ។ ការសិក្សាករណីដូចមានក្នុងទីនេះ គឺជាការឆ្លុះបង្ហាញ

យ៉ាងច្បាស់បំផុត នូវការនិយាយស្តី ឬរឿងរ៉ាវអំពីយុត្តិធម៌ / អយុត្តិធម៌ទាំងនេះ ។ គឺជាករណី នៅក្នុងពន្ធនាគារ និងនៅក្នុងស្ថាប័នផ្សេងៗទៀត ដែលគេនឹងឃើញការឆ្លុះបញ្ចាំងពីសិទ្ធិមនុស្ស នៅក្នុងប្រទេសបានច្បាស់លាស់បំផុត ។ គឺនៅក្នុងពន្ធនាគារនេះហើយដែលយើងអាចមើលឃើញបានរហ័ស និងច្បាស់លាស់នូវការយកចិត្តទុកដាក់ចំពោះសិទ្ធិមនុស្ស ។

៣. ពន្ធនាគារជាផលិតផលនៃរយៈកាលទាំងឡាយ នៅក្នុងប្រវត្តិសាស្ត្រថ្មីៗនេះរបស់ប្រទេសជាតិ នៅពេលដែលស្ថិតក្រោមការជិះជាន់ ។ នោះគឺ ក្នុងអំឡុងពេលគ្រប់គ្រងដោយរបបអាណានិគមនិយមបារាំង ឬថ្មីជាងនេះទៅទៀត ក្នុងរយៈពេលវៀតណាមកាន់កាប់ ។ ជាការពិត ការប្រើប្រាស់ពន្ធនាគារតាមបែបជាប្រព័ន្ធនៅក្នុងសង្គមកម្ពុជា គឺវាទើបតែមានថ្មីពេក ។ វាហាក់ដូចប្រជាពលរដ្ឋកម្ពុជាខ្លួនឯង មិនសូវមានចំណូលចិត្តគិតគូរកសាងកន្លែងយ៉ាងនេះទេ ។ ទោះជាមានហេតុផលលើកឡើងសមស្របយ៉ាងណាក្តី ក៏ពន្ធនាគារ គឺពិតជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលបច្ចុប្បន្ននេះ ។ ក៏ប៉ុន្តែ ការយល់ដឹងថា ពន្ធនាគារត្រូវសាងសង់ជាសំខាន់ក្នុងអំឡុងពេលពីរខុសគ្នានៃប្រវត្តិសាស្ត្រកម្ពុជា គឺពិតជាបញ្ជាក់នូវការពន្យល់តាមលទ្ធភាពច្រើនយ៉ាង ដូចជា ថាតើហេតុអ្វីបានជាពន្ធនាគារឥឡូវនេះ ស្ថិតនៅក្នុងភាពមានវិបត្តិដូច្នេះ ។ ទីមួយ គឺពន្ធនាគារភាគច្រើនសុទ្ធតែចាស់ៗ មានតាំងពីជំនាន់ទសវត្សរ៍ឆ្នាំ ៣០ មកម្ល៉េះ ។ ទីពីរ ភាគច្រើននៃពន្ធនាគារទាំងនេះ គឺជាសំណង់ដែលគេសាងសង់ឡើងយ៉ាងរហ័ស ដើម្បីផ្តល់ឲ្យទាន់សេចក្តីត្រូវការនូវពន្ធនាគារ ដែលត្រូវកើនឡើងយ៉ាងរហ័សក្នុងរយៈពេលក្រោយខ្មែរក្រហមកាន់កាប់ ។ ទីបី វាប្រហែលជាការតំណាងឲ្យជនជាតិខ្មែរជាច្រើននៃរបបដ៏គួរឲ្យស្អប់ខ្ពើម និងរបបបរទេស ហើយដោយហេតុនេះ វាក៏ទៅជារឿងមួយមិនគួរឲ្យនរណាយកចិត្តទុកដាក់គិតគូរពិចារណាអ្វីច្រើនប៉ុន្មាន ។ ប៉ុន្តែ រឿងរ៉ាវ និងបញ្ហាដែលលេចចេញពីគំនិត និងពីសភាពការពិតនៃពន្ធនាគារ មិនងាយនឹងរសាបរលាបបាត់ទៅវិញបាន ដោយធ្វើមិនដឹងមិនឮចំពោះរឿងពន្ធនាគារនោះទេ ។ រដ្ឋាភិបាលបច្ចុប្បន្ន នឹងមានការទទួលខុសត្រូវក្នុងការកសាងឡើងវិញនូវពន្ធនាគារចាស់ៗ និងសាងសង់ពន្ធនាគារថ្មីៗទៀត ។

## អ៊ុនតាក់

៤. ស្ថានភាពមិនសមរម្យរបស់ពន្ធនាគារកម្ពុជា បានកើតមានឡើងក្នុងរយៈពេលពីខែមីនា ១៩៩២ ដល់ខែកញ្ញា ១៩៩៣ ពេលដែលអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ (អ៊ុនតាក់) បានផ្តល់ការត្រួតពិនិត្យ និងការគ្រប់គ្រងទីភ្នាក់ងាររបស់រដ្ឋាភិបាល ។ ការិយាល័យសិទ្ធិមនុស្ស និងទីបញ្ជាការដ្ឋានប៉ូលីសស៊ីវិលអ៊ុនតាក់ បានចាប់ផ្តើមធ្វើអធិការកិច្ច និងការត្រួតពិនិត្យមើលពន្ធនាគារនៅដើមឆ្នាំ ១៩៩២ ។ គេបានឃើញភ្លាមថា :".....

ពន្ធនាគារកម្ពុជា ពុំមានលក្ខណៈឆ្លើយតបតាមបទដ្ឋានអន្តរជាតិទេ"[1] ។ ការិយាល័យសិទ្ធិមនុស្សបានពិនិត្យឃើញ :

១) ការប្រើច្រវាក់ខ្នោះឃ្នាងដាក់អ្នកទោសនៅគ្រប់កន្លែង សំរាប់ជាការធ្វើទណ្ឌកម្មក៏ដូចជាវិធានការធានាសន្តិសុខដែលជារឿងជាទម្លាប់ទៅហើយ ។

២) ការប្រើគុកងងឹតជាបន្ទប់តូចៗ ដាក់តែមនុស្សម្នាក់ ឬដោយគ្មានចេញចូលសំរាប់រយៈពេលអូសបន្លាយយូរ ។

៣) អ្នកទោសដែលត្រូវគេដាក់ខ្នោះ ដាក់ច្រវាក់ ឬបង្ខាំងទុកក្នុងបន្ទប់តូចងងឹត មិនត្រូវបានគេអនុញ្ញាតឲ្យចេញក្រៅដើម្បីហាត់ប្រាណទេ[2] ។

៥. នៅក្នុងសេចក្តីថ្លែងការណ៍មួយ ចុះថ្ងៃទី ៤ កក្កដា ១៩៩៣ សម្តេចព្រះនរោត្តម សីហនុ មានព្រះបន្ទូលចំពោះស្ថានភាពទូទៅនៅក្នុងពន្ធនាគារថាជាប្រការ " គួរអោយសោកស្តាយ " ។

៦. មានឧទាហរណ៍ជាច្រើន ដែលគេរាយការណ៍ពីការស្លាប់ ទាក់ទងនឹងការផ្គត់ផ្គង់ស្បៀងអាហារមិនគ្រប់គ្រាន់ និងជម្ងឺដម្កាត់ផ្សេងៗដែលកើតមាន រួមជាមួយនឹងការខ្វះអាហារ ។ នៅខែមិថុនា ១៩៩២ រដ្ឋាភិបាលកាលណោះ គឺ"រដ្ឋកម្ពុជា" បានចេញសេចក្តីណែនាំមួយតាមរយៈក្រសួងសន្តិសុខជាតិ និងមហាផ្ទៃ ដើម្បីដោះច្រវាក់ខ្នោះឃ្នាងចេញឲ្យអស់ ។ ប្រការនេះបាននាំឲ្យមានការថយចុះ តាមដែលគេរាយការណ៍អំពីការប្រើប្រាស់វា ទោះបីជាមានការបន្តប្រើមកទៀតក្តី ។ កំណត់សំគាល់មួយ លើករណីដែលដកស្រង់ចេញពីរបាយការណ៍ចុងក្រោយរបស់ការិយាល័យសិទ្ធិមនុស្ស បានបញ្ជាក់ពីភាពធ្ងន់ធ្ងរ នៃបញ្ហាដែលត្រូវប្រឈមមុខក្នុងឆ្នាំ ១៩៩២ ។

## ការកែលំអ

៧. ការិយាល័យសិទ្ធិមនុស្ស បានដឹកនាំការត្រួតពិនិត្យមើលអ្នកទោសទាំងអស់ពីរដងនៅក្នុងខែសីហា ១៩៩២ និងខែកក្កដា ១៩៩៣ ហើយជាលទ្ធផលគឺ បានដោះលែងអ្នកទោសរាប់រយរាប់ពាន់នាក់ ដែលគេរកឃើញថាគ្មានភស្តុតាងគ្រប់គ្រាន់ត្រូវចោទប្រកាន់គេ ឬក៏អ្នកទោសទាំងនោះត្រូវគេឃុំទុកក្នុងរយៈពេលអូសបន្លាយយូរមកហើយ ដោយគ្មានការជំនុំជំរះកាត់ទោសឡើយ ។ ទោះបីមានការត្រួតពិនិត្យមើលយ៉ាងនេះក៏ដោយ ក៏ប្រព័ន្ធតុលាការដែលខ្វះសមត្ថភាពដើម្បីដំណើរការជំនុំជំរះកាត់ទោស មិនអាចទប់ស្កាត់បាននូវភាពដូចគ្នានេះ នៃ

1. អាជ្ញាធរបណ្តោះអាសន្នរបស់ អ.ស.ប. នៅកម្ពុជា របាយការណ៍ចុងក្រោយរបស់ការិយាល័យសិទ្ធិមនុស្ស ( អ៊ុនតាក់ ) ខែកញ្ញា ១៩៩៣ ភ្នំពេញ ទំព័រ ១៤

2. ក្នុងរបាយការណ៍ដដែល ទំព័រ ១៩

ដំណើរដែលនៅតែមានអ្នកទោសច្រើនលើសលុបដដែល ហើយនិងមិនអាចរាំងស្កាត់បាននូវការខ្វះការគិតគូរដល់ជំនួយខាងសិទ្ធិតាមផ្លូវច្បាប់ ។

៨. ក្នុងខែមករា ១៩៩៣ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) បានចាប់ផ្តើមដំណើរការកម្មវិធីទឹក និងអនាម័យ (WATSAN) នៅតាមពន្ធនាគារនៃកម្ពុជា ។ ពន្ធនាគារ ១៤ ដែលគេបានចុះទៅមើលមានអណ្តូងថ្មីៗ មានបន្ទប់ទឹក និងអាងទទួលទឹកសំអុយដែលគេបានរៀបចំឲ្យមានតាមទីណាដែលចាំបាច់ និងដែលមានលទ្ធភាពអាចធ្វើបាន ។ ក្រៅពីនេះ នៅមានកម្មវិធីលាបថ្នាំពណ៌សនៅក្នុងបន្ទប់តូចៗជាគុកងងឹត ការព្យាបាលជម្ងឺកមរមាស់ ការចែកសាប៊ូ កន្ទេល និងមុង និងការរៀបចំឡើងវិញ នូវការចំអិនអាហារ និងទីកន្លែងចោលកាកសំណល់ ។ កម្មវិធីដ៏មានតម្លៃនេះ បានបញ្ចប់ក្នុងត្រឹមខែមិថុនា ១៩៩៤ ។

**កំណត់សំគាល់លើករណី I :**

រយៈកាលអ៊ុនតាក់ : នៅថ្ងៃទី ១ កក្កដា ១៩៩២ មន្ត្រីការិយាល័យសិទ្ធិមនុស្សបានចុះទៅមើលពន្ធនាគារក្រុង T3 នៅក្រុងភ្នំពេញ ។ ក្នុងពេលនិយាយជាមួយអ្នកទោស គេបានដឹងថា អ្នកទោសប្រាំនាក់បានស្លាប់ក្នុងទីឃុំឃាំង កាលពីពេលបីសប្តាហ៍កន្លងទៅហើយនេះ ដោយសំអាងថា ស្លាប់មកពីជម្ងឺផ្សេងៗ ផ្សំជាមួយនឹងចំណីអាហារមិនគ្រប់គ្រាន់ផង ។ អ្នកទោសម្នាក់បានស្លាប់ទាំងនៅជាប់ខ្នោះ ដែលភ្ជាប់នៅនឹងស៊ីម៉ង់ក្រាលនៅក្នុងគុក ។ មនុស្សបួននាក់ទៀតស្លាប់នៅក្នុងមន្ទីរពេទ្យនៅនឹងពន្ធនាគារ ។ ការស្លាប់នេះ ត្រូវបញ្ជាក់អះអាងបន្ថែមដោយអាជ្ញាធរពន្ធនាគារ ។ អ្នកទោសបានអះអាងថា មនុស្សទាំងនោះមានខ្លួនប្រាណហើមព្រួលមុនពេលគេស្លាប់ ហើយថាយ៉ាងហោចណាស់ក៏មានម្នាក់ដែលនិយាយលែងរួចអស់ពេលបីសប្តាហ៍មុនស្លាប់ ។ ភាគច្រើននៃអ្នកទោសដែលនៅសល់ ១៤៣ នាក់ គឺសុទ្ធតែមានសុខភាពទ្រុឌទ្រោមហួសនិយាយ ។ អ្នកទោសទាំងអស់ សុទ្ធតែត្រូវដាក់ខ្នោះជើងរៀងរាល់យប់ចាប់ពីម៉ោង ៣:៣០ រសៀលដល់ម៉ោង ៧:០០ព្រឹក ។ នៅក្នុងអាគារមួយ អ្នកទោស ២៧ នាក់ លើ ៣៤ នាក់ បានត្អូញត្អែរអំពីកន្លែងផ្សេងៗនៃខ្លួនប្រាណរបស់គេដែលហើម ភាពស្ពឹកដែលឥតដឹងញាណ និងមានការលំបាកក្នុងការដកដង្ហើម ។ អ្នកទោស ១៩ នាក់ បានឲ្យដឹងថា គេបានក្អួតចង្អោរជានិច្ចកាលក្រោយពេលបរិភោគរួចហើយ ។ អ្នកទោស ៣៣ នាក់ បញ្ជាក់ថា ខ្លួន គេមានជម្ងឺគ្រុនចាញ់ប្រចាំកាយ ។ មន្ត្រីពន្ធនាគារបានបញ្ជាក់ប្រាប់អ៊ុនតាក់ថា អ្នកទោស ៣១ នាក់ ទើបតែត្រូវបញ្ជូនទៅកាន់កន្លែងព្យាបាលនាពេលថ្មីៗនេះ ប៉ុន្តែ ៤ នាក់ក្នុងចំណោម ៣១ នាក់ ត្រូវគេរាប់បញ្ចូលក្នុងចំនួនអ្នកស្លាប់ទៅហើយ ។ ក្រៅពីនេះទៀត ដោយផ្អែកលើលទ្ធ-ផលនៃការស៊ើបអង្កេតពីខាងដើមរបស់អ៊ុនតាក់ នៅក្នុងពន្ធនាគារ PJ នៅភ្នំពេញ គេបានគូស បញ្ជាក់ប្រាប់មន្ត្រីពន្ធនាគារថា អ្នកទោស ១៤ នាក់ លើ ២៧ នាក់ ដែលឈឺ ឥឡូវនៅក្នុង គុក PJ ដោយមានការសំអាងថា ត្រៀមទទួលការព្យាបាល ។

អ្នកទាំង ១៨ នាក់នោះ ត្រូវ បានវេជ្ជបណ្ឌិតអ៊ិនតាក់ពិនិត្យមើល ហើយឃើញថា គេមានសុខភាពធ្លាក់ក្នុងសភាពយ៉ាង ធ្ងន់ធ្ងរ[3] ។

៩. អនុសញ្ញា អ.ស.ប. ដែលប្រទេសកម្ពុជាបានរួមសច្ចាប័នក្នុងឆ្នាំ ១៩៩២ និងដែលចែងពីបទដ្ឋានពាក់ព័ន្ធនោះ គឺកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុសញ្ញាប្រឆាំងនឹងទារុណកម្ម និងអនុសញ្ញាស្តីពីសិទ្ធិរបស់កុមារ ។ បទដ្ឋានពាក់ព័ន្ធផ្សេងទៀតរបស់ អ.ស.ប. រួមមាន បញ្ញត្តិច្បាប់អប្បបរមាជាបទដ្ឋានសំរាប់ប្រព្រឹត្តចំពោះអ្នកទោស និងអង្គនៃគោលការណ៍សំរាប់កិច្ចការពារមនុស្សទាំងអស់ ដែលត្រូវស្ថិតក្នុងរូបភាពណាមួយនៃការឃុំឃាំង ឬការដាក់ពន្ធនាគារ[4] ។ មានការព្រមព្រៀងជាទូទៅ ហើយថានៅត្រឹមដំណាច់កំណត់ពេលអ៊ិនតាក់ ស្ថានភាពពន្ធនាគារបានប្រែប្រួលមានចំណុចល្អឡើងគួរឲ្យកត់សំគាល់ ។ ប្រការនេះ ឃើញមានជាពិសេសនៅក្នុងបញ្ហាសុខភាព ដែលការស្លាប់ដោយជម្ងឺ និងចំណីអាហារមិនគ្រប់គ្រាន់ បានធ្លាក់ចុះយ៉ាងច្រើន ។ អធិការកិច្ចទៀងទាត់ធ្វើដោយប៉ូលីសស៊ីវិលអ៊ិនតាក់ និងការិយាល័យសិទ្ធិមនុស្សបានបន្ថយចុះនូវការបំពានដ៏ធ្ងន់ធ្ងរបំផុត និងក្នុងករណីខ្លះ បានបង្កើតជាបរិយាកាសកែទម្រង់ ដែលបង្កលក្ខណៈឲ្យអ្នកគ្រប់គ្រងពន្ធនាគារមួយចំនួន អាចកែលំអរមធ្យោបាយសម្ភារៈសំរួលការងារបានជាពិសេស ។ យ៉ាងណាមិញ ការបោះឆ្នោតជ្រើសតាំងរដ្ឋាភិបាលថ្មីនៅឆ្នាំ ១៩៩៣ ក៏ឃើញមានការកែទំរង់ថ្មីៗដែរនៅថ្នាក់មជ្ឈិម រួមមានស្ថាប័ននៃអធិការកិច្ចទៀងទាត់ខាងពន្ធនាគារ ការបង្កើតប្រាក់ឧបត្ថម្ភប្រចាំថ្ងៃសំរាប់អ្នកទោសម្នាក់ៗ និងការរៀបចំឡើងវិញនូវប្រព័ន្ធគ្រប់គ្រងពន្ធនាគារ និងប្រព័ន្ធហិរញ្ញកិច្ច ។ ប៉ុន្តែ ទោះជាមានការកែលំអយ៉ាងនេះក្តី ក៏របាយការណ៍ចុងក្រោយនេះបានបញ្ជាក់ថា ស្ថានភាពនៅក្នុងពន្ធនាគារកម្ពុជា បានបន្តលក្ខណៈដែលគ្មានបទដ្ឋានអន្តរជាតិដែរ ។ របាយការណ៍នេះ ក៏បានបង្ហាញឲ្យឃើញពីការចាំបាច់ត្រូវធ្វើច្រើនថែមទៀត ។ រដ្ឋាភិបាលនិងមានសំណូមពរឲ្យជួយ បើសិនជាចំនួនដ៏លើសលុបជាទីបំផុតនៃអតីតកាល មិនមានកើតឡើងដដែលៗទៀត ។

១០. ចាប់តាំងពីខែវិច្ឆិកា ១៩៩៤ តទៅ មានអ្នកទោសជិត ១៩០០នាក់ នៅក្នុងពន្ធនាគារស៊ីវិលចំនួន ២៤ របស់កម្ពុជា ។ នេះជាចំនួនមួយដ៏ទាបខុសពីធម្មតា បើនិយាយតាមបទដ្ឋានអន្តរជាតិ (មើលជំពូក៣) ។ ចំនួនដ៏ទាបនេះ ឆ្លុះបញ្ជាំងឲ្យឃើញលក្ខណៈសំគាល់បីយ៉ាង ដែលជាប់ទាក់ទងរវាងគ្នានិងគ្នា នៃប្រព័ន្ធច្បាប់ព្រហ្មទណ្ឌកម្ពុជា ។ លក្ខណៈសំគាល់ទាំងនេះ មានជាសង្ខេបដូចតទៅនេះ ៖

3. មើលរបាយការណ៍ដដែល ទំព័រ ២០

4. មើល ៖ កម្រងឧបករណ៍អន្តរជាតិស្តីពីសិទ្ធិមនុស្ស មជ្ឈមណ្ឌល អ.ស.ប. ដើម្បីសិទ្ធិ មនុស្ស

១. ភាពទន់ខ្សោយស្រាប់របស់ប្រព័ន្ធជារូបមន្តនៃការតម្រូវឲ្យសាធារណៈជនប្រតិបត្តិតាមច្បាប់ និងការវិនិច្ឆ័យទោស ។
២. ការពឹងផ្អែកលើប្រព័ន្ធ"អត្តនោនាថោ"ក្រៅផ្លូវការ ដើម្បីដោះស្រាយជម្លោះ និង
៣. ជាលទ្ធផល គឺការខ្វះបទដ្ឋានសាធារណៈ និងដែលអាចមានកម្លាំងពង្រឹងដល់ការប្រតិបត្តិ ។

១១. ប្រជាពលរដ្ឋកម្ពុជា មិនចង់ទទួលទោសទណ្ឌកម្មតាមការដាក់ពន្ធនាគារទេ ពីព្រោះមធ្យោបាយដើម្បីដាក់ និងឃុំឃាំងគេទុកនៅទីនោះមានការខ្វះខាត និងពីព្រោះរូបភាពផ្សេងទៀតនៃការដាក់ទណ្ឌកម្ម និងការត្រួតត្រា ត្រូវបានគេយកមកប្រើ ។ លទ្ធផលមួយដែលលេចចេញមក គឺថាប្រព័ន្ធនៃការតម្រូវឲ្យប្រតិបត្តិច្បាប់ និងការវិនិច្ឆ័យទោស ត្រូវបានកែលំអ និងត្រូវបានធ្វើឲ្យមានប្រសិទ្ធភាពថែមទៀត ដោយហេតុនេះ គេឃើញហាក់បីដូចជាមានអ្នកទោសកាន់តែច្រើននៅក្នុងពន្ធនាគារនៅកម្ពុជា ។ ឧទាហរណ៍ តុលាការខេត្តសៀមរាបមកដល់ឥឡូវនេះ បានធ្វើសវនាការជំនុំជំរះទោសបានជិតហុកសិបករណីព្រហ្មទណ្ឌ ក្នុងមួយឆ្នាំ ។ បើសិនជាតុលាការនេះ បានកែលំអពង្រឹងសមត្ថភាពរបស់ខ្លួនរហូតដល់អាចធ្វើសវនាការបានមួយករណីក្នុងមួយឆ្នាំ ដោយបន្ថែមចំនួនអ្នកទោសសាមសិបនាក់ទៀតទៅក្នុងបញ្ជីនោះមានន័យថា ឥទ្ធិពលលើពន្ធនាគារខេត្ត ដែលបានល្អសមស្របតាមនោះ ប៉ុន្តែនៅមានចំនួនអ្នកទោសច្រើនកកកុញនៅឡើយ មុខជានឹងទទួលប៉ះពាល់មិនខាននៅទីបំផុត ។ ដូច្នេះរាល់ការកែលំអ និងការកែទំរង់ប្រព័ន្ធច្បាប់ព្រហ្មទណ្ឌនៅកម្ពុជា ត្រូវតែមានអមដោយការកែទំរង់ប្រព័ន្ធពន្ធនាគារ សំរាប់ជាការបំពេញបន្ថែម ។ និយាយម្យ៉ាងវិញ ប្រព័ន្ធពន្ធនាគារ គឺជាផ្នែកមួយទាំងស្រុងនៃប្រព័ន្ធច្បាប់ព្រហ្មទណ្ឌ ។ ពន្ធនាគារជាអ្នកឆ្លុះបញ្ចាំងឲ្យឃើញប្រព័ន្ធច្បាប់ព្រហ្មទណ្ឌទាំងអស់ ។ ការស៊ើបអង្កេត ការកំណត់ដាក់ទោស និងការតម្រូវឲ្យប្រតិបត្តិច្បាប់តុលាការ ទាមទារថា ជនណាដែលបានទទួលខុសត្រូវក្នុងការដាក់ឲ្យជាប់ពន្ធនាគារ មិនបានទទួលជោគវាសនានៃការបន្ទាបបន្ថោកទាំងស្រុងឡើយ ហើយដែលឥឡូវគេបានឃើញក្នុងពន្ធនាគារជាច្រើននៅកម្ពុជា ។

១២. របាយការណ៍នេះ សរសេរមកដើម្បីជាជំនួយដល់រដ្ឋាភិបាលកម្ពុជា ក៏ដូចជាដល់អ្នកធ្វើវិភាគទានទាំងឡាយដែលមានមកហើយ និងដែលអាចមាន និងអង្គការទាំងឡាយនោះដែលកំពុងតែបំពេញការងាររួចមកហើយនៅក្នុងពន្ធនាគារ ។ ជំពូកផ្សេងៗនៃរបាយការណ៍នេះ ក៏នឹងបញ្ជាក់ផងដែរអំពីវិស័យដែលអាចឲ្យកែទំរង់បាន ហើយនឹងមានបន្ថែមពីលើនេះ នូវបញ្ជីអនុសាសន៍លើគ្រប់វិស័យ ។ របាយការណ៍នេះ បានផ្តើមចេញនំពីកម្មវិធីជំនួយខាងពន្ធនាគារ (PAP) របស់ការិយាល័យនៃមជ្ឈមណ្ឌលដើម្បីសិទ្ធិមនុស្សនៅកម្ពុជា (UNCHR) ដោយមានជំនួយពីគណៈកម្មាធិការជនភៀសខ្លួនអាមេរិក (ARC) និងគ្រូពេទ្យសំរាប់សិទ្ធិមនុស្ស

(PHR) ។ គឺពិតជាកម្លាំងរបស់ក្រុមមួយ និងជាការបញ្ជាក់ពីតម្លៃនៃសហប្រតិបត្តិការ រវាងទីភ្នាក់ងារ និងរវាងផ្នែកវិន័យ ហើយនិងជាវិធីដោះស្រាយមួយ ដែលរួមបញ្ចូលការហ្វឹកហ្វឺន ការស្រាវជ្រាវ និងការធ្វើសកម្មភាពឲ្យនៅជាមួយគ្នា ។ វាក៏ជាកម្លាំងរួមសហការជាមួយនាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ (MI) និងក្រសួងយុត្តិធម៌ដែរ (MJ) ។ បុគ្គលិកដែលជាប់ពាក់ព័ន្ធ វិធីសាស្ត្រដែលប្រើប្រាស់ និងរឿងរ៉ាវផ្សេងៗទៀតបែបនេះ ក៏មានចែងក្នុងជំពូកខាងក្រោយដែរ ។

## ជំពូក ២

# កម្មវិធីជំនួយខាងពន្ធនាគារ (PAP) : ការហ្វឹកហ្វឺន ការស្រាវជ្រាវ និងការធ្វើសកម្មភាព

## សេចក្ដីផ្ដើម :

១៣. PAP ត្រូវបានគេផ្ដើមឡើងនៅក្នុងខែធ្នូ ១៩៩៣ ទុកដូចជាកម្មវិធីសំរាប់បង្វឹកហាត់មន្ត្រីពន្ធនាគារ និងមន្ត្រីឯទៀតដូចជា ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ ដែលមានមុខនាទីទទួលខុសត្រូវ ទាក់ទិននឹងពន្ធនាគារ ។ ប៉ុន្តែ បន្ទាប់ពីមានការពិគ្រោះយោបល់មក គេបានជ្រួតជ្រាបថា ចំពោះលទ្ធផលភាគច្រើនជាអតិបរមា កម្មវិធីនេះ គួរតែត្រូវពង្រីងបន្ថែមតាមវិធីសំខាន់ៗបីយ៉ាង ។ ទីមួយ គេបានសំរេចថា ត្រូវដាក់បញ្ចូលផ្នែកស្រាវជ្រាវទៅក្នុងកម្មវិធីនេះ ដើម្បីបញ្ជាក់ឲ្យពិតប្រាកដពីស្ថានភាពទាំងឡាយ ដែលមាននៅក្នុងពន្ធនាគារកម្ពុជា ។ ទីពីរ ARC ដែលជាអង្គការអន្តរជាតិក្រៅរដ្ឋាភិបាល (NGO) ដែលបានពង្រីងកោសល្យវិច័យយ៉ាងច្រើនក្នុងការហ្វឹកហ្វឺនសិទ្ធិមនុស្សខាងពេទ្យនៅថ្នាក់មូលដ្ឋាននោះ ត្រូវបានអញ្ជើញឲ្យចូលរួម ។ ប្រការនេះក៏បានជួយសំរួលដល់ការចូលរួមពីអន្តេវាសិក ដែលស្ថិតនៅក្នុង ARC គឺវេជ្ជបណ្ឌិត **ហ្គាប្រីយ៉ែល អត់តឺរម៉ែន** មកពី PHR ដែលជាក្រុមសិទ្ធិមនុស្សខាងពេទ្យ មានមូលដ្ឋានបង្អែកនៅអាមេរិក ។ អង្គការ NGO ទាំងនេះ នឹងទទួលខុសត្រូវជា



បន្ទប់តូចជាគុកងងឹត-ពន្ធនាគារព្រៃវែង

បឋមចំពោះការពិនិត្យស្ទាបស្ទង់សុខភាពរបស់អ្នកទោស ។ ទីបី"ធាតុផ្សំសំរាប់បញ្ចេញសកម្មភាព" ត្រូវបង្កើតឲ្យមាននៅក្នុងកម្មវិធីនេះ ។ ប្រការនេះ បានគ្រោងទុកឲ្យមានអ្នកគ្រប់គ្រងសំរាប់ផ្តល់យោបល់ដល់ពន្ធនាគារតាមមូលដ្ឋាន បុគ្គលិកតុលាការ និងប៉ូលីសខាងស្ថានភាពពន្ធនាគារក្នុងមូលដ្ឋានរបស់ខ្លួន វិស័យដែលត្រូវគិតគូរ និងដំណោះស្រាយ ដែលអាចមានព្រមទាំងធនធានដែលអាចរកបានផង ។ ប្រការនេះនឹងឡើងដល់កំរិតខ្ពស់បំផុត ក្នុងការចេញរបាយការណ៍ដោយការិយាល័យកម្ពុជា និងការធ្វើសិក្ខាសាលាដើម្បីជួបជុំសមាជិករបស់អាជ្ញាធររដ្ឋាភិបាល របស់រដ្ឋបាលពន្ធនាគារ ផ្នែកខាងគ្រប់គ្រងច្បាប់តុលាការ និងអង្គការ NGO ដែលមានបំណងចូលរួម ក៏ដូចជាទីភ្នាក់ងារផ្សេងៗរបស់ អ.ស.ប. ដែរ ។ PHR ក៏បានសំរេចធ្វើការរៀបចំរបាយការណ៍មួយដាច់ដោយឡែក ដើម្បីដាក់ជូនទៅការិយាល័យកម្ពុជាដែរ ។

១៤. ទិសដៅរបស់ PAP មានដូចតទៅនេះ គឺ :

១. ជួយមន្ត្រីកម្ពុជាក្នុងការពង្រីកផែនការមួយមានរូបភាពគ្រប់វិស័យ សំរាប់ការកែទំរង់ពន្ធនាគារ.

២. ជួយកែលំអការងារសំរបសំរួល និងសហប្រតិបត្តិការរវាងមន្ត្រីពន្ធនាគារ ប៉ូលីស និងតុលាការនានា និង

៣. ជួលដល់ការបង្កើតចំណុចពិសេសៗអាចវាស់ស្ទង់បាន សំរាប់កម្មវិធីហ្វឹកហ្វឺនបន្តទៅទៀត ដល់មន្ត្រីពន្ធនាគារ ។

<table>
<tr><th><u>កម្មវិធីជំនួយខាងពន្ធនាគារ</u> (PAP)</th></tr>
<tr><td><u>ការហ្វឹកហ្វឺន</u><br>កម្មវិធីហ្វឹកហ្វឺនមានរយៈពេលម្ភៃបួនម៉ោងនៅក្នុងពន្ធនាគារ ដែលគេបានជ្រើសរើសក៏ជាការអនុវត្តន៍ដូចជាដំណើរការមួយ នៃការពិគ្រោះយោបល់ដែរ ។ គឺដើម្បីប្រមូលផ្តុំលើច្បាប់កម្ពុជាដែលមានស្រាប់ ឧបករណ៍អន្តរជាតិ និងចំណាំងទាក់ទងរវាងឧបករណ៍ ទាំងនេះ និងស្ថានភាពនៅមូលដ្ឋាន ។</td></tr>
<tr><td><u>ការស្រាវជ្រាវ</u><br>អ្នកទោសប្រហែល ១០% ជ្រើសរើសតាមចៃដន្យនៅក្នុងពន្ធនាគារទាំងអស់ ដែលគេបានចុះទៅមើល ។ ចំនួនពាក់កណ្តាល គឺសំរាប់"សម្ភាសន៍ខាងពេទ្យ" និងពាក់កណ្តាល សំរាប់"សម្ភាសន៍ទូទៅ" ។ ការពិគ្រោះជាមួយនាយកពន្ធនាគារ ប៉ូលីសតុលាការ និងជួន កាលខ្លះជាមួយនឹងមន្ត្រីរដ្ឋាភិបាល ។</td></tr>
</table>

## សកម្មភាពជាក់ស្តែង

ការពិគ្រោះយោបល់តាមមូលដ្ឋាន ការផ្តល់យោបល់ណែនាំ និងជួយទ្រទ្រង់ យុទ្ធនាការផ្តល់ព័ត៌មាន ដើម្បីសង្កត់ធ្ងន់លើបញ្ហាសំខាន់ៗ លើការធ្វើសិក្ខាសាលាជាបន្តបន្ទាប់ ។

១៥. ការជួយគាំទ្រពីក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ គឺជាចំណុចដ៏មានសារសំខាន់ណាស់ ។ ល្អដែរ ដែលក្រសួងទាំងពីរនេះបានជួយជ្រោមជ្រែងយ៉ាងច្រើន ។ ការរៀបចំឲ្យមាននិស្សិតចូលរួមជាមួយ មានមន្ត្រីភ្ជាប់ទំនាក់ទំនង ដើម្បីរួមដំណើរជាមួយក្រុម PAP និងការជួយជ្រោមជ្រែងបន្តទៅទៀត ត្រូវបានព្រាងទុករួចអស់ហើយ ។

## ការហ្វឹកហាត់

១៦. ជារួម មានមន្ត្រីពន្ធនាគារ ៣១៣ នាក់ និងមន្ត្រី ៣៨ នាក់ផ្សេងទៀត បានចូលរួមក្នុងកម្មវិធីម្តែបួនម៉ោង ដូចដែលមានគ្រោងក្នុងឧបសម្ព័ន្ធ I ។ អ្នកចូលរួមម្នាក់ៗ ត្រូវបានផ្តល់ឲ្យនូវឯកសារ ស្តីពីបញ្ញត្តិច្បាប់អប្បបរមាជាបទដ្ឋាន អ.ស.ប. សំរាប់ប្រព្រឹត្តចំពោះអ្នកទោស ក៏ដូចជាអត្ថបទសង្ខេបនៃច្បាប់ និងនីតិវិធីដែលមានជាប់ពាក់ព័ន្ធនៅកម្ពុជា ។ កម្មវិធីដូចដែលគ្រោងក្នុងឧបសម្ព័ន្ធ I មានការកែសំរួលដោយមកពីបញ្ហាសន្តិសុខ ពេលដែលពន្ធនាគារខេត្តកំពតត្រូវផាត់ចេញ ហើយដាក់ជំនួសដោយគុក T5 នៅខេត្តកំពង់ចាមវិញ ។ ខេត្តពោធិសាត់ក៏ត្រូវតែមានការពិនិត្យស្ទាបស្ទង់ដែរ ប៉ុន្តែគ្មានកម្មវិធីហ្វឹកហ្វឺនណាត្រូវអនុវត្តឡើយ ។

១៧. ពន្ធនាគារដែលបានចុះទៅមើល និងចំនួនអ្នកចូលរួមក្នុងកម្មវិធីនីមួយៗ មានចុះក្នុងតារាង ២.១ ដូចមានខាងក្រោម ។

| តារាង ២.១ ពន្ធនាគារដែលបានចុះទៅមើល និងចំនួនអ្នកចូលរួម | | | |
|---|---|---|---|
| ឈ្មោះពន្ធនាគារ | ចំនួនភ្នាក់ងារពន្ធ-នាគារជាអ្នកចូលរួម | ចំនួនសរុបរបស់ភ្នាក់ងារពន្ធនាគារក្នុងពន្ធនាគារនីមួយៗ | ចំនួនមន្ត្រីតុលាការជាអ្នកចូលរួម |
| បាត់ដំបង | ២២ | ៥៥ | ១ |
| កំពង់ចាម | ២៦ | ៤៥ | ៣ |
| កំពង់ចាម (T5) | ៤៤ | ៤៤ | ៣ |
| កំពង់ឆ្នាំង | ១៣ | ២៩ | ១៧ |
| កំពង់សោម | ១០ | ២៥ | ៣ |
| PJ | ៣៧ | ៤៤ | ៣ |
| ព្រៃវែង | ១៩ | ២៧ | ២ |
| ព្រៃស | ២៦ | ៦៧ | ២ |
| ពោធិសាត់ | ២៦ | ៣០ | ២ |
| ស្វាយរៀង | ១៨ | ៣២ | ២ |
| សៀមរាប | ៣៥ | ៥៤ | ៥ |
| T3 | ៣០ | ៧៤ | ៥ |
| តាខ្មៅ | ៣៣ | ៣៣ | ២ |
| សរុប | ៣១៣ | ៦០៣ | ៣៤ |

១៨. កម្មវិធីហ្វឹកហាត់មានបីចំណែកសំខាន់ៗ គឺ :

១. សេចក្ដីផ្ដើមអំពីច្បាប់ និងនីតិវិធី ដែលមានជាប់ពាក់ព័ន្ធនៅកម្ពុជាទាក់ទងដល់ការឃុំឃាំង និងការដាក់ពន្ធនាគារ

២. សេចក្ដីផ្ដើមចូលបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ដែលជាប់ពាក់ព័ន្ធ

៣. ការពិគ្រោះយោបល់លើស្ថានភាពពន្ធនាគារក្នុងមូលដ្ឋាន ។

១៩. ចំណែកពីរខាងដើម ត្រូវបំពេញបង្គ្រប់តាមរយៈបាឋកថា ការពិភាក្សាតាមក្រុមតូចៗ ការធ្វើតាមលំហាត់ធ្វើនៅផ្ទះ និងការប្រកួតប្រជែង ។ ចំណែកទីបី ត្រូវបំពេញបង្គ្រប់ដោយវិធីប្រើសំណួរតូចៗមានការរៀបចំពិសេស ដែលត្រូវផ្ដល់ទៅឲ្យនិស្សិតទាំងអស់ ដែលបញ្ចប់វាដោយចាត់ទុកដូចជាផ្នែកមួយនៃលំហាត់ធ្វើនៅផ្ទះ និងលំហាត់ធ្វើតាមក្រុមតូចៗ ។ ក្រុមនីមួយៗ នៅពេលដែលក្រុមមានការផ្ដល់ចម្លើយឯកភាពគ្នាហើយ ត្រូវកត់ត្រារាល់

"មេគំនិត" ទុកនៅក្នុងក្រជាសមួយ ។ មើលឧបសម្ព័ន្ធ2 សំរាប់ជាគំរូនៃឧបករណ៍មួយដែលគេពិនិត្យស្ទាបស្ទង់ ។ វិធីដំណើរការពិគ្រោះយោបល់នេះ (ព្រមជាមួយនឹងការតាមដានពិនិត្យមើលអ្នកទោសផង-មើលខាងក្រោម) ក៏ជួយសំរួលដល់ការរៀបចំឲ្យមាន "ចាងហ្វាងគុក" សំរាប់ពន្ធនាគារនីមួយៗ ដែលមានប្រមូលផ្តុំនៅក្នុងឧបសម្ព័ន្ធ3 ។

## ការស្រាវជ្រាវ

២០. ត្រូវមានការអនុញ្ញាតពីក្រសួងមហាផ្ទៃ ដើម្បីដំណើរការធ្វើសម្ភាសន៍ជាមួយអ្នកទោស ។ មានការព្រមព្រៀងថា ទីណាដែលអាចធ្វើបាន អ្នកទោសប្រហែល ៥% នៅក្នុងពន្ធនាគារនីមួយៗ គួររៀបចាត់ទុកជាគំរូ ដោយប្រើមធ្យោបាយ"ការពិនិត្យស្ទាបស្ទង់ជាទូទៅ" (មើលឧបសម្ព័ន្ធ4) ។ ចំនួន ៥% ទៀតគួរត្រូវបានពិនិត្យស្ទាបស្ទង់ដោយប្រើវិធី"ចោទសំណួរតូចៗស្តីពីការថែទាំសុខភាពនៅពន្ធនាគារក្នុងប្រទេសកម្ពុជា"ដឹកនាំធ្វើដោយ PHR និង ARC (មើលឧបសម្ព័ន្ធ5) ។ តារាង ២.២ បង្ហាញពីតំពេងធ្វើការ"ស្ទាបស្ទង់ទូទៅ" ។

**តារាង ២.២ : ចំនួនអ្នកទោសបានសម្ភាសន៍ជាផ្នែកនៃ"ការស្ទាបស្ទង់ទូទៅ"**

| ឈ្មោះពន្ធនាគារ | ចំនួនដងចុះទៅមើល | ចំនួនសរុបនៃអ្នកទោស | % នៃអ្នកទោសបានធ្វើសម្ភាសន៍ |
|---|---|---|---|
| បាត់ដំបង | ១០ | ២០៥ | ៤,៨៧% |
| កំពង់ចាម | ៦ | ៩៣ | ៦,៤៥% |
| កំពង់ចាម (T5) | ១៣ | ២៥១ | ៥,១៧% |
| កំពង់ឆ្នាំង | ៥ | ៤៧ | ១០,៦៣% |
| កំពង់សោម | ៣ | ៥៩ | ៥,០៨% |
| PJ | ៩ | ២១៦ | ៤,១៦% |
| ព្រៃវែង | ៦ | ៩៥ | ៦,៣១% |
| ពោធិសាត់ | ៦ | ៥៦ | ១០,៧១% |
| ស្វាយរៀង | ៣ | ៣១ | ៩,៦៧% |
| សៀមរាប | ៥ | ៦៩ | ៧,២៤% |
| T3 | ៥ | ៩៨ | ៥,១០% |
| តាខ្មៅ | ៨ | ១៥៤ | ៥,១៩% |
| | ៦ | ១០១ | ៥,៩៥ |
| សរុប : | **៨៥** | **១៤៧៥** | **៥,៧៦** |

២១. PHR បានសរសេររៀបចំរបាយការណ៍មួយ ដោយប្រើឧបករណ៍ស្ទាបស្ទង់ជាមូលដ្ឋាន និងដាក់ជូនរបាយការណ៍នោះដោយឡែកពីគ្នា ទៅការិយាល័យកម្ពុជា ។

២២. ការធ្វើវិភាគលើទិន្នន័យដែលទទួលបានពីការពិនិត្យស្ទាបស្ទង់ទាំងពីរយ៉ាងនេះ ត្រូវធ្វើឡើងដោយប្រើកម្មវិធី EPI INFO ពង្រីកដោយការិយាល័យកម្មវិធីរោគរាតត្បាត មជ្ឈមណ្ឌលសំរាប់ត្រួតពិនិត្យជម្ងឺ និងកម្មវិធីរួមសុីពីរោគអេដស៍ អង្គការសុខភាពពិភពលោក ដែលនៅក្នុងវិស័យសាធារណៈ ។ ទោះបីការពិនិត្យស្ទាបស្ទង់ទូទៅ មានការទាក់ទងបានតែមួយផ្នែកនៃទិន្នន័យសុខភាពក៏ដោយចុះ ក៏កម្មវិធី EPI INFO មានលក្ខណៈសមស្របណាស់ ចំពោះតំរូវការរបស់ PAP ដូចដែលវាបានបញ្ចូលលក្ខណៈពិសេសៗនៃកម្មវិធីបែបនេះ ដូចជា SAS SPSS និងកម្មវិធីជាមូលដ្ឋាន នៃទិន្នន័យដូចជា dBase.

**កំណត់សំគាល់លើករណីទី ២**

**មនុស្សថ្លង់ផង គផង**

ការិយាល័យកម្ពុជា បានផ្ដើមបើកដំណើរការពិនិត្យស្ថានភាពពន្ធនាគារ នៅក្នុងខែមីនា ១៩៩៤ ។ ដោយប្រើសំណួររៀបចំហើយ អ្នកទោសទីមួយ (ជ្រើសយកតាមចៃដន្យ) បានបង្ហាញឲ្យគេស្គាល់ ។ ឆ្ងល់ណាស់ គេឥតអាចឆ្លើយសំណួរណាមួយបានសោះ ! គេទំនងដូចជាគ ហើយប្រហែលជាថ្លង់ផង ឬក៏មិនអាចឆ្លើយនឹងសំណួរបាន ។ ចំពោះសំណួរជាលាយលក្ខណ៍អក្សរ ក៏គេមិនចេះឆ្លើយ ។ បញ្ហាដែលប្រការនេះបានចោទឡើងភ្លាមគឺ បើសិនជាអ្នកជំនាញបកប្រែរបស់យើង មិនអាចនិយាយឆ្លើយឆ្លងគ្នាបានទៅហើយ តើនៅមាននរណាទៀតដែលអាចនោះ ? តើមានការគិតគូរពិចារណាយ៉ាងណាដែរ ចំពោះរឿងនេះ ក្នុងរយៈពេលឆ្លងកាត់របស់គេ តាមរយៈប្រព័ន្ធច្បាប់កម្ពុជានោះ ? តើមានប៉ុន្មាននាក់ទៀត ដូចមនុស្សនេះនៅក្នុងប្រព័ន្ធនេះ ?

## ការធ្វើសកម្មភាព

២៣. រាល់ការចុះពិនិត្យពន្ធនាគារ ត្រូវតែផ្ដើមដោយការពិគ្រោះដោយសង្ខេបជាមួយនាយកពន្ធនាគារពាក់ព័ន្ធ និង / ឬស្នងការរងប៉ូលីសមូលដ្ឋាន-មន្ត្រីប៉ូលីសទទួលខុសត្រូវលើពន្ធនាគារ ។ ក្នុងរយៈពេលកំពុងមានកម្មវិធីហ្វឹកហ្វឺន និងកម្មវិធីស្រាវជ្រាវបញ្ហាមូលដ្ឋាន ក៏ដូចជាបញ្ហាទូទៅ និងចម្លើយដែលអាចមាន ត្រូវបានលើកយកមកពិភាក្សា ។ ឧទាហរណ៍ ក្នុងករណីជាច្រើន អ្នកទោសដែលឈឺ និងរបួស ត្រូវគេបញ្ជូនទៅមន្ទីរពេទ្យនៅមូលដ្ឋាន ខ្នោះឃ្នាងត្រូវគេដោះចេញ បន្ទប់ឃុំឃាំងដ៏តូចនៅឯកោដាច់ពីគេត្រូវគេបិទទ្វារ កម្មវិធីកីឡាត្រូវផ្ដើមឲ្យមាន អ្នកទោសត្រូវបំបែកចេញដោយឡែកពីគ្នា ច្បាប់បញ្ញត្តិ ពន្ធនាគារត្រូវប្រែប្រួល

អ្នកទោសត្រូវដោះលែង និងសន្តិសុខចំពោះគេក៏មានការធានា ។ ចំណុចគួរជាទីកត់សំគាល់ជាពិសេស គឺការសំរលស្ថានភាពដែលមានលក្ខណៈគួរឲ្យសោកស្តាយ នៅពន្ធនាគារ PJ នៅភ្នំពេញ ដែលគេបានចុះទៅមើលលើកដំបូងនៅថ្ងៃទី ២២ មេសា ១៩៩៤ ។ អន្តរាគមន៍នេះ បាននាំឲ្យមានការចូលរួមអំពីតំណាងពិសេសរបស់អគ្គលេខាធិការ អ.ស.ប. ខាងសិទ្ធិមនុស្សនៅកម្ពុជា លោក Jistice Michael Kirby និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួននៅក្នុងស្រុក និងអន្តរជាតិ ។ លទ្ធផល គឺការជួសជុលកែលំអផ្នែកសំខាន់ៗនៃពន្ធនាគារ និងការបន្ថយចំនួនមនុស្សក្នុងពន្ធនាគារជាងពី ២០០ ក្នុងពេលចុះទៅមើលលើកដំបូង មកនៅត្រឹម ១៥ នាក់ នៅពេលសរសេរនេះ ។ ជំពូកទីប្រាំពីរ បានចែងពីការគិតគូរបានកាន់តែលំអិតទៀត ដល់ឧបករណ៍ (ហេតុការណ៍បន្ទាប់បន្សំ) វិសាមញ្ញនេះ ។ ប្រហែលជាមានក្នុងទិដ្ឋភាពរបស់ PAP នេះដែរ គឺការបន្តជួយជ្រោមជ្រែងដោយក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ។ ទំនុកទុកចិត្ត និងការសម្ងាត់របស់ក្រសួងទាំងពីរនេះនៅក្នុងកម្មវិធី គឺជាការចាំបាច់ ហើយដែលត្រូវសំរួលដោយគោលការណ៍ច្បាស់លាស់ នៃការចែកចាយពត៌មានមិនមែនជារឿងសម្ងាត់ ។ ជាពិសេស គឺវាសំខាន់ជាទីបំផុតដែលត្រូវបញ្ជូនដំណឹងទៅឲ្យអ្នកគ្រប់គ្រងពន្ធនាគារ និងបុគ្គលិក ដែលជាបញ្ហាដ៏ធ្ងន់ធ្ងរប្រឈមមុខដោយប្រព័ន្ធពន្ធនាគារ (និងប្រព័ន្ធច្បាប់តុលាការជារួម) មុខជាដោះស្រាយមិនបាន បើសិនជាបញ្ហាទាំងនេះនៅកប់បាត់ ។

## សន្និដ្ឋាន

២៨. ការប៉ិនប្រសប់ក្នុងការបញ្ចូលកម្មវិធីហ្វឹកហ្វឺនជាមួយកម្មវិធីស្រាវជ្រាវ និងកម្មវិធីធ្វើសកម្មភាព បានជួយឲ្យ PAP អាចដំណើរការបានក្នុងរបៀបម្យ៉ាងដែលរស់រវើក និងដូចជាយានមួយសំរាប់ឈានទៅដល់ការប្រែប្រួលបន្តខាងផ្ទាល់ខ្លួន ខាងមូលដ្ឋាន និងប្រព័ន្ធសរីរាង្គកាយទាំងមូល ដោយសេចក្តីសង្ឃឹម ។

## ជំពូក ៣

# ចំនួនពន្ធនាគារ : តើពន្ធនាគារពាំងអស់នៅឯណា ?

## សេចក្ដីផ្ដើម

២៥. អាជ្ញាធរពន្ធនាគារកម្ពុជា មិនដូចជាអាជ្ញាធរពន្ធនាគារជាច្រើនក្នុងពិភពលោក ឥតមានគំនិតលាក់លៀមពីចំនួនអ្នកទោស ដែលជាប់នៅក្នុងពន្ធនាគារស៊ីវិលទាំងម្ភៃបួន ។ នាយកដ្ឋានពន្ធនាគារ និងក្រសួងមហាផ្ទៃ ក៏នៅបានរក្សាឯកសារកំណត់ចំនួនពន្ធនាគារ បានសមស្របតាមពេលវេលា ។ អ្វីដែលតួលេខទាំងនេះបានបង្ហាញឲ្យដឹង, និយាយជារួម គឺលក្ខណៈពិសេសពីរយ៉ាងដ៏មានសារៈសំខាន់ ។

២៦. លក្ខណៈពិសេសទីមួយ គឺថាមានលេចឡើងនូវកំណើនជាលំដាប់ នូវចំនួនពន្ធនាគារ បន្ទាប់ពីមានការថយចុះយ៉ាងខ្លាំង ដែលកើតមានជាសំខាន់ ដោយសារការដោះលែងអ្នកទោសនយោបាយ និងអន្តោគមន៍របស់អ៊ុនតាក់ ក្នុងរយៈពេលពីរឆ្នាំក្រោយកិច្ចព្រមព្រៀងសន្តិភាពនាទីក្រុងប៉ារីសក្នុងឆ្នាំ ១៩៩១ ។ នៅថ្ងៃទី ២០ មករា ១៩៩៤ នាយកដ្ឋានពន្ធនាគារបានរាយការណ៍ឲ្យដឹងថា មានអ្នកទោសសរុបទាំងអស់ចំនួន ១៧៧៩ រួមទាំងអ្នកទោសស្រី ៨១ នាក់ផង ។ តួលេខចុងក្រោយចេញដោយប្រភពដដែល នៅថ្ងៃទី ៧ កញ្ញា ១៩៩៤ បញ្ជាក់ថាមានអ្នកទោសចំនួន ១៩៨១ នាក់ រួមទាំងស្រី ៩៣ នាក់ផង ។ ចំនួននេះតំណាងឲ្យកំណើន ១២% នៃចំនួនពិតក្នុងរយៈពេលមិនដល់មួយឆ្នាំ ។ មានមតិអាចឲ្យសន្និដ្ឋានបានពីការទាក់ទងជាមួយអាជ្ញាធរពន្ធនាគារ តុលាការ និងអាជ្ញាធររដ្ឋាភិបាល ថានិន្នាការនេះ នឹងមានបន្តទៅទៀត (មើលតារាង ៣.១ ខាងក្រោម) ។



ការរៀបចំអ្នកទោសតាមលំដាប់លំដោយ-ពន្ធនាគារកំពង់សោម

តារាង ៣.១ អ្នកទោសក្នុងពន្ធនាគារស៊ីវិល-ថ្ងៃទី ៧ កញ្ញា ១៩៩៤

| លេខរៀង | ឈ្មោះពន្ធនាគារ | ចំនួនអ្នកទោស | អ្នកទោសស្រី |
|---|---|---|---|
| ១ | បាត់ដំបង | ២១៣ | ១០ |
| ២ | បន្ទាយមានជ័យ | ៩២ | ១ |
| ៣ | កំពង់ចាម | ១២៣ | ១៣ |
| ៤ | កំពង់ឆ្នាំង | ៥៧ | ២ |
| ៥ | កំពត | ៥៧ | ៤ |
| ៦ | កំពង់ស្ពឺ | ៥៩ | ០ |
| ៧ | កំពង់ធំ | ៤៩ | ១ |
| ៨ | កណ្តាល (តាខ្មៅ) | ៩៦ | ៦ |
| ៩ | កោះកុង | ៤៦ | ៣ |
| ១០ | ក្រចេះ | ២៣ | ១ |
| ១១ | មណ្ឌលគិរី | ១៥ | ០ |
| ១២ | P.J. | ៣៦ | ១០ |
| ១៣ | ព្រះវិហារ | ៥ | ០ |
| ១៤ | ព្រៃស | ១៥៧ | ០ |
| ១៥ | ព្រៃវែង | ៧២ | ១ |
| ១៦ | ពោធិសាត់ | ៤៤ | ២ |
| ១៧ | រតនៈគិរី | ១៩ | ០ |
| ១៨ | សៀមរាប | ៩៧ | ៣ |
| ១៩ | ក្រុងព្រះសីហនុ | ៦០ | ៣ |
| ២០ | ស្ទឹងត្រែង | ២៦ | ២ |
| ២១ | ស្វាយរៀង | ៦៤ | ២ |
| ២២ | តាកែវ | ៧៥ | ៥ |
| ២៣ | T.1 (អតីត T3) | ២៣៧ | ២០ |
| ២៤ | T.5 (ត្រពាំងផ្លុង) | ២៥៥ | ០ |
| | សរុប | ១៩៤១ | ៩៣ |

• តួលេខរាយការណ៍ត្រឹមតែខែមិថុនា ១៩៩៤ ប៉ុណ្ណោះ

២៧. លក្ខណៈពិសេសទីពីរ គឺចំនួនអ្នកទោស បើប្រៀបធៀបជាមួយប្រទេសដទៃទៀត ។ អត្រាអ្នកទោស ប្រៀបទៅបណ្តាប្រជាពលរដ្ឋ (គិតចំនួនអ្នកទោសក្នុងចំនួនប្រជាពលរដ្ឋ ១០០.០០០ នាក់) ក្នុងប្រទេសកម្ពុជា គឺប្រហែល ២២ ។ វគឺ ខាងសិទ្ធិមនុស្សបានប៉ាន់ស្មានថា ក្នុងឆ្នាំ ១៩៨៦ អនុបាតជាមធ្យមនៃអ្នកទោស ប្រៀបទៅបណ្តាប្រជាពលរដ្ឋនៅគ្រប់តំបន់ក្នុងពិភពលោក មានប្រហែល ១០៦[5] ។ គេបានសន្និដ្ឋានថា តួលេខអំពីការដាក់ពន្ធនាគារក្នុងប្រទេសជាច្រើន មិនបានថយចុះ ចាប់តាំងពីពេលនោះមក ហើយប្រហែលជាមានការបញ្ជាក់មិនបានច្បាប់លាស់ទៀតផង[6] ។

២៨. ហេតុផលបញ្ជាក់ពីចំនួនដ៏ទាបនេះ ដោយបទដ្ឋានអន្តរជាតិមានការស្មុគ្រស្មាញ ប៉ុន្តែទាក់ទិននឹងការរួមបញ្ចូលកត្តាទាំងឡាយ រួមមានដំណោះស្រាយរឿងព្រហ្មទណ្ឌជាច្រើន (និងជម្លោះផ្នែករដ្ឋប្បវេណី) តាមរយៈមធ្យោបាយក្រៅផ្លូវការ និងការផ្អែកលើប្រព័ន្ធ"អត្តនោនាម៉េ" ។ ជាមួយនេះដែរ ក៏មានភស្តុតាងគួរឲ្យចាប់អារម្មណ៍មួយចំនួនធំ ដើម្បីបង្ហាញថា ប្រជាពលរដ្ឋកម្ពុជាភាគច្រើន ខ្វះទាំងមធ្យោបាយ ទាំងទំនុកទុកចិត្ត ឬជាធម្មតា ខ្វះទាំងអំណាចដើម្បីធ្វើបណ្តឹងតវ៉ា ។ គេតែងតែមានការភ័យខ្លាចជាប់ថា បើនឹងធ្វើយ៉ាងនោះមុខជាឥតបានផល ឬនឹងទទួលការផ្ចាល់តបអំពីសំណាក់អ្នកដែលអាចមានការប៉ះពាល់លើខ្លួន ។ ប្រជាពលរដ្ឋកម្ពុជារស់នៅក្នុងសង្គមមួយ ដែលសំរាប់គោលបំណងច្រើនយ៉ាង ( មានការលើកលែងដែលអាចធ្វើបាននូវការលែងលះ និងរឿងផ្នែករដ្ឋប្បវេណីខ្លះៗ) ពុំមានលក្ខណៈជិតជាប់ដោយប្រព័ន្ធច្បាប់ ឬដំណោះស្រាយខាងផ្លូវច្បាប់ដ៏មានប្រសិទ្ធភាពឡើយ ។ ការបង្កើតឲ្យមានប្រព័ន្ធបែបនេះ តម្រូវឲ្យរដ្ឋាភិបាលប្រើពេលរាប់ឆ្នាំ និងតស៊ូប្តេជ្ញាពិតប្រាកដ ។

២៩. ប៉ុន្តែ មានការបង្ហាញថា ស្នាដៃ និងការរីកចំរើនខ្លះ ត្រូវបានសំរេចក្នុងវិស័យនេះ ។ តុលាការកំពូល និងសាលាឧទ្ធរណ៍ ត្រូវបានបង្កើតហើយ ។ អ្នកការពារក្តី ត្រូវបានបណ្តុះបណ្តាល ហើយកំពុងតែឈរតំណាងឲ្យកូនក្តីកាន់តែច្រើនឡើងៗ យ៉ាងទៀងទាត់ ។ ប៉ូលីស ព្រះរាជអាជ្ញា និងចៅក្រម កំពុងទទួលការបណ្តុះបណ្តាល ។ សាលាច្បាប់មួយដែលទើបតែរៀបចំជាថ្មីឡើងវិញ នឹងចាប់ផ្តើមក្នុងពេលឆាប់ៗនេះ ដើម្បីចែកសញ្ញាប័ត្រឲ្យនិស្សិត ហើយឯក្រុមសិទ្ធិមនុស្សក៏ជាសេចក្តីត្រូវការ ដែលមានការកំណត់ច្បាស់ហើយ ។ ដោយមានជំនួយឧបត្ថម្ភដល់ប៉ូលីស តុលាការ និងមន្ត្រីតុលាការដែលបានរីកចំរើនដល់កំរិតកាលពីពីរបីឆ្នាំកន្លងមកនេះ គេអាចមានការរំពឹងទុកថា ប្រព័ន្ធច្បាប់ព្រហ្មទណ្ឌនឹងកាន់តែមានប្រសិទ្ធភាព និងកាន់តែឲ្យផលល្អ ។ ប៉ុន្តែ ការកែលំអទាំងនេះ នឹងចោទជាទុក្ខគ្រោះតទៅទៀតដល់ប្រព័ន្ធពន្ធនាគារ ពីព្រោះស្ថានភាពវានឹងធ្លាក់ចុះយ៉ាប់យ៉ឺនថែមទៀត ដោយពុំមាន

---

5. របាយការណ៍រួមរបស់វគឺ និយាយពីសិទ្ធិមនុស្សនៅតាមពន្ធនាគារ វគឺនិយាយពីសិទ្ធិ មនុស្ស ខែមិថុនា ១៩៩៣ ទំព័រ ១២៥-១២៧ ។

6. របាយការណ៍ដដែល ទំព័រ ១២៧.

កំណើនស្មើគ្នាក្នុងបញ្ហាធនធាន ។ រដ្ឋាភិបាលទាំងឡាយជាអ្នកធ្វើអំណោយនិងទីភ្នាក់ងារផ្តល់ជំនួយជាទូទៅ នៅស្ទាក់ស្ទើរក្នុងការរួមវិភាគទានផ្តល់ទុនសំរាប់ប្រព័ន្ធពន្ធនាគារ តាមហេតុផលមួយចំនួន រួមមានភាពនៃការមិននិយមជំនួយឧបត្ថម្ភបែបនេះដែលគេបានដឹងហើយនៅក្នុងប្រទេសរបស់ខ្លួនផ្ទាល់ ។ ប៉ុន្តែ ប្រព័ន្ធពន្ធនាគារត្រូវចាត់ទុកជាផ្នែកមួយនៃប្រព័ន្ធច្បាប់តុលាការ ។ បើពុំមានប្រព័ន្ធពន្ធនាគារមួយសមស្របទេ គឺមានសង្ឃឹមតិចណាស់ក្នុងការពង្រឹកប្រព័ន្ធច្បាប់ព្រហ្មទណ្ឌមួយសមស្របពិតប្រាកដ ។ ការកាត់ទោសមនុស្សឲ្យទទួលទោសតាមដំណើរការវិនិច្ឆ័យទោស កាន់តែមានប្រសិទ្ធភាពចំពោះពន្ធនាគារដែលមានមនុស្សច្រើនហួស និងកំពុងតែមានស្ថានភាពធ្លាក់ចុះ គឺជាបាតុភូតអាក្រក់ដែលកម្ពុជា (និងប្រទេសដទៃច្រើនទៀត) ត្រូវប្រឈមមុខ ។ ការប៉ុនប្រសប់របស់រដ្ឋាភិបាលកម្ពុជា ក្នុងការផ្គត់ផ្គង់លុយកាក់សំរាប់ការកែលំអចាំបាច់ៗ និងការពង្រឹកបន្ថែមប្រព័ន្ធពន្ធនាគារគឺមានកំរិត ហើយត្រូវការឲ្យមានជំនួយឧបត្ថម្ភ ។

## ការពិនិត្យស្ទាបស្ទង់របស់ PAP : ទិដ្ឋភាពអ្នកទោស

៣០. ក្នុងចំណោមអ្នកទោសប៉ែតសិបប្រាំនាក់ ដែលពិនិត្យតាមចៃដន្យ មាន ៣,៥%(3) ជានារីភេទ ។ ចំនួននេះ ទាបជាងបន្តិចនៃចំនួនប៉ាន់ស្មានរបស់នាយកដ្ឋានពន្ធនាគារ ដែលក្នុងខែមករា ១៩៩៩ បានបង្ហាញពីចំនួន ៤,៥%(81) នៃចំនួនស្ត្រី និង ៤,៦%(93) នៅក្នុងខែកញ្ញា ។ ចំនួនកុមារ (ក្រោមអាយុ ១៨ ឆ្នាំ) គឺលំបាកនឹងប៉ាន់ស្មានបាន ពីព្រោះនាយកដ្ឋានពន្ធនាគារគ្មានតួលេខគួរឲ្យទុកចិត្តបាន ។ ឌីយ៉ាក្រាម ៣.១ ដូចតទៅនេះ ចង្អុលប្រាប់ពីដំណើរធ្លាក់ចុះនៃក្រុមអាយុ ។ វាបង្ហាញថា ៣,៥%(3) នៃមនុស្សជាតំណាង មានអាយុរវាងពី ១០ និង ១៩ ឆ្នាំ ។ លើតួលេខទាំងនេះ គេអាចប៉ាន់ស្មានបានថា មានកុមារប្រហែលពី ៦០ ដល់ ៩០ នាក់នៅក្នុងពន្ធនាគារកម្ពុជា ។ ចំនួននេះ មិនបានបញ្ចូលកុមារដែលបច្ចុប្បន្ននេះ កំពុងរស់នៅជាមួយម្តាយរបស់គេ ដែលក្នុងនោះមានមួយចំនួនតូច ។

**ទីយ៉ាក្រាមរង្វង់មូល ៣.១ ៈ ក្រុមអាយុរបស់អ្នកទោសជាសំណាក**




ក្រុមតែមួយដ៏ធំបំផុត គឺក្រុមអាយុ ២០-២៩ ឆ្នាំ ដែលមាន ៥០,៦% (43) នៃចំនួនសំណាកសរុប ។

៣១. ៤២% (36) នៃចំនួនអ្នកទោសដែលគេចាត់ក្នុងក្រុមសំណាក មិនត្រូវបានកាត់ទោសទេ (ហៅថាអ្នកជាប់ឃុំ) ម្នាក់ៗរង់ចាំពេលជាមធ្យម ចំនួនជាង ៣០ ខែ (អ្នកទាំងនេះសំរាប់បង្គ្រប់ឲ្យទៅខែណាដែលនៅជិតបំផុត) ។ ទីយ៉ាក្រាម ៣.១ ខាងក្រោមបញ្ជាក់ថា តើអ្នកជាប់ឃុំម្នាក់ៗបានចំណាយពេលអស់ប៉ុន្មាន ដើម្បីរង់ចាំការជំនុំជំរះកាត់ទោស ។ អ្នកទោសពីរនាក់បានរង់ចាំអស់ពេល ១០៨ ខែ ! ចំនួនជាង ១០% កំពុងតែបានរង់ចាំអស់ពេលជាងពីរឆ្នាំហើយ ។

**ទីយ៉ាក្រាមបន្ទាត់ផ្តេក ៣.១ : រយៈពេលរង់ចាំការជំនុំជំរះកាត់ទោស**



តារាង ៣.២ ខាងក្រោមបញ្ជាក់ប្រាប់ការរីកធំនៃតួលេខទាំងនេះ ។

**តារាង ៣.២ : ការរង់ចាំការជំនុំជំរះទោស**

| រយៈពេលរង់ចាំ (ជាខែ) | ចំនួនរាប់ដង | ភាគរយ | ចំនួនដែលកើនឡើង |
|---:|---:|---:|---:|
| ១ | ៦ | ១៦,៧% | ១៦,៧% |
| ២ | ២ | ៥,៦% | ២២,២% |
| ៣ | ៥ | ១៣,៩% | ៣៦,១% |
| ៤ | ៤ | ១១,១% | ៤៧,២% |
| ៥ | ៤ | ១១,១% | ៥៨,៣% |
| ៧ | ៣ | ៨,៣% | ៦៦,៧% |
| ៨ | ១ | ២,៨% | ៦៩,៤% |
| ៩ | ៣ | ៨,៣% | ៧៧,៨% |
| ១២ | ១ | ២,៨% | ៨០,៦% |
| ១៩ | ១ | ២,៨% | ៨៣,៣% |
| ២០ | ១ | ២,៨% | ៨៦,១% |
| ២១ | ១ | ២,៨% | ៨៨,៩% |
| ៣២ | ១ | ២,៨% | ៩១,៧% |
| ៣៦ | ១ | ២,៨% | ៩៤,៤% |
| ១០៨ | ២ | ៥,៦% | ១០០,០% |
| សរុប | ៣៦ | ១០០,០% | |

៣២. តាមការពិត ភាគរយនៃចំនួនមនុស្សជាប់ឃុំក្នុងពន្ធនាគារ ដែលរង់ចាំការជំនុំជំរះទោស មានលក្ខណៈកាន់តែធ្ងន់ធ្ងរចំពោះប្រព័ន្ធទាំងមូល ជាងភាគរយដែលបញ្ជាក់នៅទីនេះ ។ ពន្ធនាគារ T5 ដែលត្រូវបញ្ចូលក្នុង PAP គឺជាទីកន្លែងមួយទុកសំរាប់អ្នកទោសជាទណ្ឌិត ។ គ្មានអ្នកជាប់ឃុំទេ នៅក្នុងចំនួនអ្នកទោសដប់បីនាក់ដែលសម្ភាសន៍នៅទីនោះ ។ បើសិនជាយើងដកគុក T5 ចេញពីសំណាក នោះភាគរយនៃជនជាប់ឃុំឡើងដល់ ៥០% ។ ជាការពិតហើយដែលប្រការនេះជាការបញ្ជាក់ពីប្រព័ន្ធមួយដែលស្ថិតក្នុងភាពច្របូកច្របល់ ។ តួលេខទាំងអស់

នេះ គឺជាដីកាចោទប្រកាន់បណ្ដោះអាសន្ន ពីប្រព័ន្ធច្បាប់ព្រហ្មទណ្ឌកម្ពុជា ។ នេះគឺជាចំនួនដ៏តូចនៃជនជាប់ឃុំ ដែលគេបានផ្ដល់ឲ្យ ជាពិសេសដូចយ៉ាងនេះ ។

៣៣. អ្នកទោសចំនួន ៥៨% (49) ដែលត្រូវជំនុំជំរះកាត់ទោសហើយនៅក្នុងតួលេខជាសំណាក មានការរង់ចាំជាមធ្យមក្នុងការឃុំឃាំងមុនពេលវិនិច្ឆ័យទោស អស់រយៈពេលជាងដប់ពីរខែ ។ ការបែងចែកចំណុចនេះ ត្រូវបង្ហាញនៅក្នុងឌីយ៉ាក្រាមបន្ទាត់ផ្ដេក ៣.២ ខាងក្រោម ។ តួលេខនេះ អាចបញ្ជាក់ប្រាប់ថា មានការធ្លាក់ចុះខាងការប៉ិនប្រសប់ក្នុងការរៀបចំដើម្បីដំណើរការលើអ្នកជាប់ឃុំ ។ ការបង់ប្រាក់ធានា ឬការដោះលែងស្របតាមលក្ខខណ្ឌមុនពេលជំនុំជំរះ កម្រមានគេយកមកប្រើណាស់នៅក្នុងប្រទេសកម្ពុជា ។

**ឌីយ៉ាក្រាមបន្ទាត់ផ្ដេក ៣.២ : ការឃុំឃាំងមុនពេលវិនិច្ឆ័យទោស**




## ស្ត្រី និងកុមារ

៣៤. ស្ត្រីបីនាក់ក្នុងការពិនិត្យសិក្សានេះ ស្ថិតនៅក្នុងគុកខេត្តកំពង់ចាម ព្រៃវែង និងសៀមរាប ។ ស្ត្រីពីរនាក់បានទទួលការវិនិច្ឆ័យទោសរួចហើយ ។ ម្នាក់ទៀតបានរង់ចាំប្រាំខែក្នុងទីឃុំឃាំង មុនពេលជំនុំជំរះទោស ។ ក្នុងចំនួនអ្នកទោសបីនាក់ដែលមានអាយុក្រោម ដប់

ប្រាំបួនឆ្នាំ មានម្នាក់បានទទួលការវិនិច្ឆ័យទោសហើយ រីឯពីរនាក់បានរង់ចាំអស់ពេលតាមរៀងម្នាក់ៗ គឺប្រាំបួនខែ និងបីខែ នៅក្នុងទីឃុំឃាំង មុនពេលជំនុំជំរះទោស ។

**កំណត់សំគាល់លើករណីទី៣**

**ការឃុំឃាំងអនីតិជនចំនួន ៧ ខែ**

ក្នុងពេលចុះទៅមើលពន្ធនាគារ PJ មួយ នារីម្នាក់អាយុ ១៧ ឆ្នាំ ត្រូវឃើញជាប់ឃុំអស់រយៈពេលជាង ៧ ខែហើយ ។ នៅពេលសាកសួរពត៌មានទើបគេបានដឹងថា នាងត្រូវគេឃាត់ខ្លួនដោយជាមួយនឹងស្ត្រីជាប់ឃុំម្នាក់អាយុ ២៨ ឆ្នាំ ក្នុងបទត្រូវគេចោទថា បានឃុំអនីតិជនក្នុងបំណងលក់នាងទៅឲ្យពេស្យាស្ថាន ។ នៅពេលចុះទៅមើលពន្ធនាគារនោះក្រោយទៀត គេបានប្រាប់យើងថា អ្នកទាំងពីរនោះត្រូវបានតុលាការក្រុងដោះលែងនៅពេលវិនិច្ឆ័យទោស ។

ចៅក្រមបានឲ្យដឹងថា អ្នកទាំងពីរនេះត្រូវគេឃុំឃាំងតាមបញ្ជារបស់ចៅក្រមស៊ើបអង្កេតម្នាក់ ក្នុងពេលរង់ចាំការវិនិច្ឆ័យទោស គឺបទត្រូវចោទប្រកាន់តាមមាត្រា ៣៥ ពីការបង្ខាំងមនុស្សទុកខុសច្បាប់ ។ នៅពេលសវនាការ ព្រះរាជអាជ្ញាបានចោទអ្នកទាំងពីរតាមមាត្រា ៤២(3) អំពីបទជើរកស្រីក្មេងទុកសំរាប់គោលបំណងពេស្យាចារ ។ ចៅក្រមបាននិយាយថា លោកបានដោះលែងអ្នកទាំងពីរឲ្យរួចទោស ព្រោះគ្មានភស្តុតាង ។ លោកបានបន្តទៀតថា ជនរងគ្រោះត្រូវចោទប្រកាន់នោះមានអាយុ ២១ ឆ្នាំ ។ បើតាមចៅក្រម ជនជាប់ចោទទីមួយ គឺម្ចាស់ផ្ទះដែលបានជួលបន្ទប់សំរាប់ដាក់ស្រីពេស្យា ។ ជនជាប់ចោទទីពីរ គឺស្រីពេស្យាម្នាក់ដែលបានជួលបន្ទប់ក្នុងផ្ទះនេះ ហើយជនរងគ្រោះត្រូវចោទប្រកាន់ក៏បានជួលបន្ទប់ក្នុងផ្ទះតែមួយនេះដែរ ។

ទោះបីជាចៅក្រមបាននិយាយថា លោកបានដោះលែងឲ្យអ្នកទាំងពីររួចទោស ព្រោះតែគ្មានភស្តុតាងជាក់ស្តែងក៏ដោយ ក៏ការចោទប្រកាន់តាមមាត្រា ៤២ មិនអាចត្រូវការពារបានដែរ ដោយហេតុថា ជនរងគ្រោះត្រូវគេចោទនោះមានអាយុ ២១ ឆ្នាំ ហើយមិនមែនជាអនីតិជនទៀត ។ ចៅក្រមស៊ើបអង្កេតក៏បានឲ្យគេឃុំឃាំងអនីតិជនម្នាក់ (អ្នកជាប់ចោទទីពីរ អាយុ ១៧ ឆ្នាំ) អស់រយៈ ពេលជាង ៧ ខែ ក្នុងបទបានប្រព្រឹត្តល្មើស (បទលហុ) ត្រង់មាត្រា ១៤(4) នៃបញ្ញត្តិច្បាប់ ព្រហ្មទណ្ឌជាបណ្តោះអាសន្ន ដែលបានកំណត់រយៈពេលអតិបរមាត្រឹមពីរខែសំរាប់ការឃុំ ឃាំងអនីតិជនមុនពេលជំនុំជំរះ ។

## បញ្ជីពន្ធនាគារ

៣៥. ពន្ធនាគារនីមួយៗត្រូវមានបញ្ជីពន្ធនាគារមួយ ។ តាមធម្មតាបញ្ជីនេះ គឺជាសៀវភៅមួយធំ ដោយមានពត៌មានមួយឬពីរបន្ទាត់អំពីអ្នកទោសម្នាក់ៗ ។ ដោយត្រូវមានលក្ខណៈ

សមស្របជានិច្ច ជាមួយនឹងបញ្ញត្តិអប្បបរមាជាបទដ្ឋាន សំរាប់ប្រព្រឹត្តចំពោះអ្នកទោស បញ្ជីនេះជាធម្មតា គឺគ្រាន់តែជាពត៌មានទាក់ទងនឹងអ្នកទោស ដែលនៅជាប់ពន្ធនាគារ ។ អ្នកទោសជាញឹកញាប់ក៏ត្រូវឃុំឃាំងដោយមិនសមស្របដែរ ជួនកាលក៏ត្រូវស្ថិតក្រោមបញ្ជាមិនត្រឹមត្រូវ ហើយដោយពុំមានពត៌មានសំខាន់ៗ ដូចជាញាតិសាលោហិតជិតជាងគេ ។ គ្មានពន្ធនាគារណាមួយបានរក្សាកំណត់ត្រាគ្រប់យ៉ាង ស្តីពីអ្នកទោសរបស់ខ្លួនឡើយ ។

## ជំពូក ៤

## ការគ្រប់គ្រងពន្ធនាគារ និងបុគ្គលិកពន្ធនាគារ ៖ រមើលរំព្រៃដើម្បីរកឈើ

### សេចក្តីផ្តើម

៣៦. ការគ្រប់គ្រងពន្ធនាគារស៊ីវិលទាំងម៉្លេះមួន ក្នុងប្រទេសកម្ពុជា មានការស្មុគ្រស្មាញណាស់ ។ នោះគឺជាប្រព័ន្ធមួយ ដែលគេឃើញមានរវាងក្រសួងបី និងស្រទាប់នៃការិយាធិបតេយ្យ គឺជាប្រព័ន្ធដែលត្រូវការកែលំអទាំងស្រុង ។ ទោះបីវាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងមហាផ្ទៃលើវិស័យច្រើនយ៉ាងក្តី ក៏ពន្ធនាគារជាច្រើន ហាក់បីដូចជាអង្គភាពស្ទើរតែស្វយ័ត ក្រោមការត្រួតត្រារបស់ស្នងការប៉ូលីសនៅមូលដ្ឋានទៅហើយ ។ គឺជាប្រព័ន្ធមួយដែលត្រូវតែមានជាប់ទាក់ទិននឹងបញ្ហាជាច្រើនដោយជៀសមិនរួច ដូចជាទំនាក់ទំនងយ៉ាងតឹងតែងជាទូទៅជាមួយពន្ធនាគារ និងការផ្តល់ស័ក្តិយ៉ាងត្បិតត្បៀតទៅឲ្យពន្ធនាគារ ភវិតសីលធម៌យ៉ាងទាបរបស់ភ្នាក់ងារពន្ធនាគារ និងការហូកហ្វីនស្អូចស្តើងដែលគេបានទទួល ។

#### កំណត់សំគាល់លើករណីទី ៤

**កុមារ និងសេចក្តីដោះសារ ៖ ករណីសំរាប់សហការរវាងខាងពេទ្យ និងខាងច្បាប់**

នៅពន្ធនាគារខេត្តកំពង់ឆ្នាំងក្មេងប្រុសតូចម្នាក់ និងម្តាយរបស់វា ត្រូវគេឃាត់ខ្លួនពីបទត្រូវជាប់ក្នុងការសង្ស័យក្នុងរឿងចោរកម្ម ។ ក៏នៅមានក្មេងប្រុសម្នាក់អាយុបីឆ្នាំ រស់នៅជាមួយអ្នកទាំងពីរនេះ ដូចជាសមាជិកគ្រួសាររបស់គេដែរ ។ គេមិនឃើញមានការចោទប្រកាន់ជាផ្លូវការណាមួយត្រូវបានដាក់មកទេ ។ ផ្អែកតាមការស៊ើបអង្កេតផ្សេងទៀត ដែលបានរាប់បញ្ចូលទាំងសម្ភាសន៍ជាមួយក្មេងប្រុសនោះ ព្រមទាំងម្តាយរបស់វា និងអង្គការក្រៅរដ្ឋាភិបាលខាងសិទ្ធិមនុស្សនៅមូលដ្ឋាន ដែលបានរួមពាក់ព័ន្ធក្នុងករណីនេះ ការបញ្ជាក់ថា អ្នកទាំងពីរនេះមានអ្នកការពារក្តីម្នាក់យ៉ាងល្អ ក្នុងករណីក្នុងពេលដែលចោរកម្មត្រូវគេចោទនោះ គឺមានរបាយការណ៍ជាច្រើនរបស់កសិណាគួរឲ្យទុកចិត្ត ដែលតាមការពិតពួកគេបាននៅទីផ្សេងទៀតសោះ ។ ម្យ៉ាងទៀត ព្រះរាជអាជ្ញា និងចៅក្រមដែលមានភារៈក្នុងរឿងនេះ គ្មានភ័ស្តុតាងរឹងមាំដើម្បីការពារការចោទប្រកាន់ទេ ។ គ្រាន់តែមានបណ្តឹងពីម្ចាស់តូបដែលជាប្រភពកើតមានចោរកម្មជាប់ក្នុងការចោទប្រកាន់ អមដោយការផ្តល់ពត៌មានទៅតុលាការ ដោយមន្ត្រីឃោជាទាក់ទងទៅនឹងអ្នកកាន់កាប់តូប ។

ស្របតាមនោះ ក្នុងខណៈដែលចុះទៅពិនិត្យមើលតុលាការ យើងបានឃើញថាករណីនេះ ត្រូវបានលើកយកមកពិចារណា ។ ជាពិសេសគេបានគូសបញ្ជាក់ថា ៖

១. អាយុរបស់ក្មេងប្រុសនោះ មិនអនុញ្ញាតឲ្យវាជាប់ពន្ធនាគារទេ ដោយអនុលោមតាមមាត្រា ១៨(4) នៃបញ្ញត្តិច្បាប់ទាក់ទងនឹងតុលាការ និងច្បាប់ព្រហ្មទណ្ឌ និង

នីតិក្រម ដែលចូលជាធរមាននៅកម្ពុជាក្នុងរយៈអន្តរកាល ។

២. ភស្តុតាងប្រឆាំងទៅលើអ្នកទាំងពីរប្រហែលជាមិនគ្រប់គ្រាន់ ហើយមានភស្តុតាងជាប់ទាក់ទិនផ្សេងទៀត ដែលអាចត្រូវផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្ស ។

ចៅក្រមស៊ើបអង្កេតបានសួរថា តើគេអាចបញ្ជាក់ពីអាយុរបស់ក្មេងនេះបានដែរឬទេ ។ យើងបាននិយាយថា គឺពិតជាអាចបាន ហើយការពិនិត្យសុខភាពត្រូវបានរៀបចំតាមរយៈគ្រូពេទ្យខាងសិទ្ធិមនុស្ស ដែលបានបញ្ជាក់ពីអាយុរបស់ក្មេងនោះ ។ ចៅក្រមបាននិយាយថា លោកបានពិនិត្យសាកសួរទៅឯសាលារៀននៅក្នុងមូលដ្ឋាន អំពីថាតើវាបានរៀននៅថ្នាក់ណា ។ បន្តិចក្រោយមកគេក៏បានដោះលែងក្មេងនោះទៅ ។ ឯម្តាយត្រូវគេឃាត់ទុកមួយរយៈតមកទៀត ក៏ប៉ុន្តែ ត្រូវដោះលែងដោយថាហេតុ បន្ទាប់ពីមានការបង្ហាញហេតុផលក្នុងនាមរបស់ស្រីជាម្តាយនោះ ដោយអ្នកការពារក្តីម្នាក់ ដែលបំពេញការនៅក្នុងអង្គការក្រៅរដ្ឋាភិបាលខាងសិទ្ធិមនុស្សមួយទៀត ។

## ក្រសួងមហាផ្ទៃ និងសន្តិសុខជាតិ

៣៧. ក្រសួងមហាផ្ទៃគឺជាមជ្ឈមណ្ឌលគ្រប់គ្រងពន្ធនាគារ ។ នាយកដ្ឋានពន្ធនាគាររបស់ក្រសួងដែលមានបុគ្គលិកជិតចិតសិបនាក់ មានការទទួលខុសត្រូវជារួម រួមមានការផ្គត់ផ្គង់ភស្តុភារ បុគ្គលិកពន្ធនាគារ (រួមមានការដោះស្រាយសំរាប់ស្បៀងប្រចាំថ្ងៃឲ្យទៅអ្នកទោស) និងការអនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាល ។ ក្រសួងមានការគ្រប់គ្រងផ្ទាល់លើ T3 ពន្ធនាគារព្រៃស និង T5 (កំពង់ចាម) និងបុគ្គលិក ៣៤៧ នាក់របស់ពន្ធនាគារទាំងនេះ ។ នាយកដ្ឋាននេះ ចែកចេញជាការិយាល័យបីតាមលំដាប់រៀងៗគ្នា ប្រាក់ខែនិងការតម្លើងឋានន្តរសក្តិ ការប្រមូលឯកសារសំរាប់ពន្ធនាគារ និងការគ្រប់គ្រងពន្ធនាគារ ។ ប៉ុន្តែនិយាយតាមពិតអំពីពន្ធនាគារទាំងបីនេះ ពន្ធនាគារម្តែមួយទៀតនៅក្រោមការគ្រប់គ្រងដ៏មានប្រសិទ្ធិភាព ពីមួយថ្ងៃទៅមួយថ្ងៃ ពីអនុស្នងការនគរបាលមូលដ្ឋាន ដែលនាយកពន្ធនាគារត្រូវមានការទទួលខុសត្រូវ ហើយរាយការណ៍ចំពោះមកខ្លួន ។ ប្រព័ន្ធនៃការគ្រប់គ្រងនេះ ត្រូវពង្រឹងតាមរយៈការយល់ឃើញក្នុងចំណោមបុគ្គលិករបស់ពន្ធនាគារ ដែលជាផ្នែកមួយនៃកម្លាំងនគរបាលដែរ ។ ឯកសណ្ឋានរបស់គេ ប្រព័ន្ធលំដាប់ថ្នាក់ និងការកំណត់រដ្ឋបាលរបស់នាយកដ្ឋានពន្ធនាគារក្នុងក្របខណ្ឌក្រសួងមហាផ្ទៃជាអ្នកពង្រឹងការយល់ដឹងនេះ ។ ការគ្រប់គ្រងពន្ធនាគារដោយអាជ្ញាធរនគរបាល គឺជាប្រការមួយគួរឲ្យស្តាយ ជាពិសេសនៅពេលដែលអ្នកទោសជាច្រើនជាប់ឃុំ គឺនៅក្នុងការឃុំឃាំងមុនពេលជំនុំជំរះវិនិច្ឆ័យទោស ។ ជាពិសេស វានាំឲ្យកើតមាននិន្នាការពីរយ៉ាងដែលគេមិនចង់បាន ។ ទីមួយ គឺជាការមើលទៅអ្នកទោសដូចជា" ការដាក់គុកនគរបាល " ហើយដោយហេតុនេះ វាគ្រាន់តែជាការពង្រីកបន្ថែមការគ្រប់គ្រងច្បាប់

របស់នគរបាល ផ្តើមចេញអំពីដំណាក់កាលឃាត់ខ្លួន និងការឃុំខ្លួនជាដំបូង ។ ទីពីរ គឺការខ្វះការសំរុះសំរួលនៃកម្លាំងនគរបាល តាមរយៈវត្តមាននៃប្រព័ន្ធពន្ធនាគារ ដែលមានភាពខុសគ្នាទាំងស្រុង ។

៣៨. ក្រៅពីតួនាទីរបស់អាជ្ញាធរនគរបាលមូលដ្ឋាន ការគ្រប់គ្រងពន្ធនាគារនៅមានភាពស្មុគ្រស្មាញទៀត ដោយតួនាទីរបស់ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល និងតាមខ្លឹមសារនៃបញ្ញត្តិ ៣១ នាពេលថ្មីៗនេះ (មើលកថាខណ្ឌ៨២) ។



មហាផ្ទៃ-ពន្ធនាគារ T3

## ក្រសួងយុត្តិធម៌ និងប្រព័ន្ធអធិការកិច្ច

៣៩. ក្រសួងយុត្តិធម៌ អនុវត្តតួនាទីមួយមានលក្ខណៈជាអធិការត្រួតពិនិត្យមើល និងស្របតាមរដ្ឋមន្ត្រី"អនុវត្តច្បាប់ ត្រួតពិនិត្យមើលបញ្ជី និងស្ថានភាពពន្ធនាគារ"[7] ។ តួនាទីនេះត្រូវដើរដោយឆ្លងតាមរយៈអាជ្ញារបស់រាជអាជ្ញាមូលដ្ឋានអមតុលាការ ។ រាជអាជ្ញាទាំងនេះ ក៏មានការត្រួតពិនិត្យមើលជាក់ស្តែងលើការផ្ទេរពន្ធនាគារដែរ ។ តួនាទីអធិការនេះ ត្រូវប្រកាសជាដំបូងដោយសេចក្តីថ្លែងការណ៍មួយរបស់ក្រសួងយុត្តិធម៌នៅថ្ងៃទី ៧ កក្កដា ១៩៩៣[8] ។ ពេលដែលឃើញថាក្រិត្យច្បាប់នេះ មិនមានការពិនិត្យឲ្យបានល្អិតល្អន់ទាំងស្រុង ដោយព្រះ

---

7. សម្ភាសន៍ជាមួយឯកឧត្តម ចែមស្គួន រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ៧/២/៩៤ ភ្នំពេញ

8. សេចក្តីថ្លែងការណ៍រួមលេខ ២៧៨ តំណាង ៩៣ ៧.៧.៩៣ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

រាជអាជ្ញា ទេនោះ ក៏មានសេចក្ដីថ្លែងការណ៍មួយទៀត ឈ្មោះហៅថា សេចក្ដីថ្លែងការណ៍ ៥០៩ ត្រូវប្រកាសនៅពាក់កណ្ដាលខែកញ្ញា ១៩៩៣ ដោយបញ្ជាក់ច្បាស់ពីភារកិច្ចជាអធិការរបស់រាជអាជ្ញា[១] ។ សេចក្ដីចម្លងនៃសេចក្ដីថ្លែងការណ៍នេះ មានជូនភ្ជាប់ជាមួយរបាយការណ៍នេះត្រង់ ឧបសម្ព័ន្ធ ៦ ។ សេចក្ដីថ្លែងការណ៍ ៥០៩ គឺជាព្រឹត្តិការណ៍ដ៏សំខាន់ក្នុងការគ្រប់គ្រងពន្ធនាគារកម្ពុជា ពីព្រោះវាបានគូសបញ្ជាក់ជាលើកទីមួយនូវចំនួនទស្សនកិច្ចដែលត្រូវធ្វើ (មួយខែពីរដង) ការបញ្ជាក់ចំនួនអ្នកជាប់ឃុំ ( ពួកអ្នកដែលឥតមានការជំនុំជំរះកាត់ទោស ) ស្ថានភាពរស់នៅ ការបំបែកឲ្យចេញដោយឡែកពីគ្នា អនាម័យ និងផ្នែកសុខភាព ។ PAP បានបញ្ជាក់ថា អ្នកទោសដប់មួយនាក់ នៃចំនួនដប់បីនាក់ ត្រូវបានត្រួតពិនិត្យមើលពីរដងក្នុងមួយខែ ។ មានករណីលើកលែងមួយគឺ ពន្ធនាគារ T5 ក្នុងខេត្តកំពង់ចាម ដែលព្រោះតែវានៅឯកោដាច់ពីគេ ហើយផ្លូវថ្នល់ចេញចូលទៅទីនោះមានការលំបាកជាទីបំផុត ធ្វើឲ្យការចុះធ្វើអធិការកិច្ចជួបការលំបាកក្រៃលែង ។ មួយទៀត គឺពន្ធនាគារ T3 (ភ្នំពេញ) ដែលគេមិនបានចុះទៅមើលឲ្យបានទៀងទាត់ ពីរដងក្នុងខែទេ ប៉ុន្តែបានធ្វើអធិការកិច្ចទៀងទាត់យ៉ាងតិចបំផុតមួយខែម្ដង ។ មានបញ្ហាជាច្រើនចំពោះប្រព័ន្ធអធិការកិច្ចនេះ រួមមាន :

១. របាយការណ៍របស់ព្រះរាជអាជ្ញា កម្រនឹងបានឃើញ (បើសិនជាមាន) ដោយបុគ្គលិកក្រសួងមហាផ្ទៃ ឬនាយកពន្ធនាគារណាស់ ។ ប៉ុន្តែ វាទៅជាលេចចេញជាទំនាក់ទំនងផ្ទៃក្នុងរបស់ក្រសួងយុត្តិធម៌ទៅវិញ,
២. ព្រះរាជអាជ្ញាច្រើនតែខកខានមិនបានជួបជាមួយនឹងអ្នកទោសទេ ហើយបែរជាចូលចិត្តទាររកសេចក្ដីលំអិតពីនាយកពន្ធនាគារទៅវិញ ។ លើសពីនេះទៀត ព្រះរាជអាជ្ញាក៏មិនឃើញចេញមុខជាទូទៅ ថាមានទំនាក់ទំនងជាសម្ងាត់ ជាមួយអ្នកទោសក៏ទេដែរ ហើយសម្ភាសន៍ភាគច្រើនជាមួយអ្នកទោស ច្រើនតែធ្វើនៅចំពោះមុខនាយកពន្ធនាគារ ។ ប្រការនេះជាធម្មតា ធ្វើឲ្យអ្នកទោសរាមិនហ៊ានរៀបរាប់អ្វីជាបញ្ហាពិតរបស់ព្រះរាជអាជ្ញាឡើយ ។
៣. ក្រសួងយុត្តិធម៌មិនបានបញ្ជូនលទ្ធផលរកឃើញពីរបាយការណ៍ទាំងនេះ ទៅឲ្យក្រសួងមហាផ្ទៃ,
៤. របាយការណ៍មានការប្រែប្រួលយ៉ាងច្រើន ខាងគុណភាពរបស់វា,
៥. ព្រះរាជអាជ្ញា និងក្រសួងយុត្តិធម៌គ្មានអំណាច ឬធនធាន ដើម្បីកែតម្រូវរឿងរ៉ាវណាមួយ ដែលត្រូវរកឃើញតាមរយៈអធិការកិច្ច,
៦. ពុំមានការពាក់ព័ន្ធខាងតុលាការចូលក្នុងប្រព័ន្ធរបាយការណ៍ឡើយ,

ប្រព័ន្ធធ្វើរបាយការណ៍ ដោយហេតុនេះ វាទៅជាគ្មានប្រសិទ្ធភាពមួយចំណែកធំ ។

---

[១]. សេចក្ដីថ្លែងការណ៍រួមលេខ ៥០៩ តំណាង៦១០៦-៩៣ ១៣.៩.៩៣ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

៤០. មិនយូរប៉ុន្មាន ក្រោយពេលបោះឆ្នោតនាខែឧសភា ១៩៩៣ និងការបង្កើតរដ្ឋាភិបាល ការរួមបញ្ចូលនាយកដ្ឋានពន្ធនាគារទៅក្នុងក្រសួងយុត្តិធម៌ ត្រូវបានពិភាក្សាក្នុងក្របខណ្ឌឋានៈជាន់ខ្ពស់នៃផ្នែកគ្រប់គ្រងរដ្ឋបាល និងខាងរដ្ឋាភិបាល ។ ប្រការនេះ ក៏ត្រូវបានអនុម័តយល់ព្រមនៅក្នុងសិក្ខាសាលារួមមួយ រវាងក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ នាខែ មករា ១៩៩៤ រៀបចំឡើងដោយមជ្ឈមណ្ឌល ។ គ្មានអ្វីបានលេចចេញបានទាន់ពេល អំពីការពិភាក្សានេះឡើយ ។

## ក្រសួងសុខាភិបាល

៤១. ក្រសួងសុខាភិបាល តាមរបាយការណ៍ គឺទទួលខុសត្រូវក្នុងការផ្តល់សេវាខាងពេទ្យដល់ពន្ធនាគារ ។ ក៏ប៉ុន្តែ នៅតាមពន្ធនាគារទាំងឡាយដែលចុះទៅមើល ពុំឃើញមានភស្តុតាងណាមួយនិយាយពីរឿងនេះទេ ។ នៅតាមឱកាសដែលគេបានពិនិត្យមើលការផ្ទេរអ្នកទោសទៅឲ្យមន្ទីរពេទ្យ គេឃើញថា ការចុះឈ្មោះទទួលពួកគេ ត្រូវធ្វើដោយផ្អែកលើមូលដ្ឋានដូចៗគ្នានឹងមូលដ្ឋានរបស់អ្នកឯទៀតៗដូច្នោះដែរ ពោលគឺគេបានតម្រូវឲ្យអ្នកជំងឺ ឬគ្រួសាររបស់ថ្លៃថ្នាំ ថ្លៃរំដំបៅ និងថ្លៃសេវាដទៃទៀត និងមន្ទីរពេទ្យផ្លូវការដែលគេផ្ទេរអ្នកទោសឈឺទៅទីនោះ ។ ក្រសួងមហាផ្ទៃខ្លួនឯង បានលៃតម្រូវថវិកាសំរាប់ផ្គត់ផ្គង់ថ្នាំសង្កូវដល់ស្ថាប័ន ដែលខ្លួនបានតម្រូវឲ្យផ្តល់សេវាមកឲ្យអ្នកទោស ។ គ្មានឃើញភស្តុតាងណាថា ប្រការនេះកំពុងកើតមានទេ ។

## បញ្ញត្តិ៣១

៤២. ភាពច្របូកច្របល់ដែលមានក្នុងប្រព័ន្ធនៃការគ្រប់គ្រងពន្ធនាគារនាបច្ចុប្បន្នមានកើតកាន់តែធ្ងន់ឡើងៗ ដោយបញ្ញត្តិ៣១ ចេញដោយក្រសួងយុត្តិធម៌នៅថ្ងៃទី១៥ កុម្ភៈ ឆ្នាំ ១៩៩៤[10] ។ បញ្ញត្តិនេះមានបំណងកំណត់មុខងាររបស់អភិបាល និងអភិបាលរងរបស់ ខេត្ត-ក្រុង ។ ភារៈទទួលខុសត្រូវមួយដែលប្រគល់ទៅឲ្យអភិបាល ដោយអនុលោមតាមបញ្ញត្តិនេះគឺ "ត្រួតមើលពន្ធនាគារ និងធ្វើសហការជាមួយក្រសួងយុត្តិធម៌ ក្រសួងសុខាភិបាល និងក្រសួងពាក់ព័ន្ធដទៃទៀតដើម្បីអនុវត្តកិច្ចការនេះឲ្យបានត្រឹមត្រូវស្របតាមច្បាប់" ។ បញ្ញត្តិជាទូទៅនេះ គឺត្រូវរៀបចំថែមទៀតដោយការបង្កើតឲ្យមាន" ការិយាល័យសាលាក្តី និងកិច្ចការពន្ធនាគារ" ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យដោយផ្ទាល់ពីសំណាក់អភិបាលរងទី២ ។ ការិយាល័យនេះ គឺក្នុងចំណោមបញ្ហាឯទៀតត្រូវ :

---

10. បញ្ញត្តិ ៣១ លើតួនាទីនៃអភិបាល និងអភិបាលរងរបស់បណ្តាខេត្ត-ក្រុង

- ទទួលរបាយការណ៍ស្តីពីសភាពការណ៍អ្នកទោស និងអ្នកត្រូវកាត់ឲ្យជាប់ទោសក្នុងពន្ធនាគារ និងត្រូវរាយការណ៍បញ្ហាទាំងនេះទៅអគ្គលេខា (របស់ការិយាល័យ)
- ទទួលរបាយការណ៍ពីឆ្មាំពន្ធនាគារអំពីពន្ធនាគារ និងទណ្ឌិត ដែលបានលួចរត់ចេញពីពន្ធនាគារ និង
- ប្រមូលផ្តុំរបាយការណ៍ស្តីពីកិច្ចការទាំងអស់របស់ខណ្ឌ ស្រុក សង្កាត់ ឃុំ ទាក់ទង នឹងកិច្ចការរបស់តុលាការ និងពន្ធនាគារសំរាប់អគ្គលេខា ។

៤៣. ការសាកសួរអំពីការអនុវត្តន៍បញ្ញត្តិនេះជាមួយអភិបាលរង និងរដ្ឋអំណាចពន្ធនាគារបានគូសបញ្ជាក់ថា មានបញ្ហាស្មុគ្រស្មាញខ្លះក្នុងរឿងដំណើរការនៃបញ្ញត្តិនេះ ។ ក្នុងខណៈដែលតាមរបាយការណ៍វាជាបំណងមួយដើម្បីបង្វែរការគ្រប់គ្រងពន្ធនាគារ (និងស្ថាប័នឯទៀតៗ) ឲ្យទៅជាប្រព័ន្ធមួយដូចដែលមានដំណើរការនៅក្នុងទសវត្សរ៍ឆ្នាំ ៥០ និងឆ្នាំ ៦០ គេពុំបានលៃទុកមូលនិធិណា ដើម្បីជួយសំរួលឲ្យគំរោងការដំណើរការទៅមុខរួចបានច្រើនគួរសម ។ ប៉ុន្តែ តាមធាតុពិតរបស់វា បញ្ញត្តិនេះពិតជាផ្តល់មកការិយាល័យរបស់អភិបាលមូលដ្ឋាននូវតួនាទី ព្រមជាមួយនឹងតួនាទីរបស់មន្ត្រីឯទៀតៗផង ។ តាមនាយកពន្ធនាគារ បញ្ហាលុយកាក់ទាំងអស់ក្រៅពីប្រាក់ខែរបស់ភ្នាក់ងារពន្ធនាគារ ឥឡូវត្រូវអនុម័តដោយការិយាល័យរបស់អភិបាល ។ ប្រការនេះរួមមានការកសាង និងកែប្រែពន្ធនាគារឲ្យបានថ្មីឡើងវិញ ។ តាមមន្ត្រីថ្នាក់ខ្ពស់របស់ក្រសួងមហាផ្ទៃ ឥទ្ធិពលរបស់បញ្ញត្តិបានផ្អែកយ៉ាងច្រើនលើអត្តចរិតរបស់អភិបាលខេត្តនៅមូលដ្ឋាន ប៉ុន្តែ បើពុំមានការផ្តល់លុយកាក់ គំរោងនេះមួយភាគធំគឺពិតជាមិនអាចដំណើរការបាន ។ អភិបាលរងដែលយើងបានប្រាស្រ័យទាក់ទង ក្នុងពេលដែលបានដឹងច្បាស់ពីបញ្ញត្តិនេះ ហាក់ដូចជាមិនពិតពីតួនាទីរបស់ខ្លួនឡើយ ។

## បុគ្គលិកពន្ធនាគារ

៤៤. ដោយមិនគិតពីបុគ្គលិកថ្នាក់ខ្ពស់ ភ្នាក់ងារពន្ធនាគារភាគច្រើនឥតបានដឹងឮអំពីរបៀបរៀបចំរដ្ឋបាលស្មុគ្រស្មាញ ដែលដាក់ចុះដើម្បីគ្រប់គ្រងពន្ធនាគារទេ ។ ភាគច្រើនរួមមានឋានៈខ្ពស់ មានត្រឹមតែគំនិតទូលំទូលាយនៃតួនាទីរបស់ប្រព័ន្ធផ្សេងៗ នៃការគ្រប់គ្រងពន្ធនាគារ ។

៤៥. កាលបើភ្នាក់ងារថ្នាក់ខ្ពស់ខ្លះបានទទួលការហ្វឹកហ្វឺនជារយៈៗរហូតដល់ ៦ ខែ ដោយក្រសួងមហាផ្ទៃ ភ្នាក់ងារភាគច្រើនឥតបានទទួលទេ ។ ស្ទើរតែពុំមានការលើកលែង គឺគ្មានការហ្វឹកហ្វឺនណាត្រូវផ្តល់ឲ្យទៅថ្នាក់ក្រោមទេ ។ ក្នុងខណៈដែលក្រសួងមហាផ្ទៃមាននាយកដ្ឋានអប់រំហ្វឹកហ្វឺន គេមើលឃើញដូចជាពុំមានការហ្វឹកហ្វឺនជំនាញ ឬតាមបែបប្រព័ន្ធណាដល់ភ្នាក់ងារពន្ធនាគារទេ ។ ចំណុចនេះជាការសរបញ្ជាក់ឲ្យឃើញកម្លាំងនគរបាលមួយជា

រួម ប៉ុន្តែមានលក្ខណៈកាន់តែធ្ងន់ធ្ងរឡើង ក្នុងករណីរបស់ភ្នាក់ងារពន្ធនាគារ ពីព្រោះគេជាផ្នែកមួយតូចនៃកម្លាំង ហើយមានស្ថានភាពទន់ទាបផងទៀត ។ ដូច្នេះ កត្តាដ៏សំខាន់មួយនៃប្រព័ន្ធដែលអាចកើតឡើងបាន នៃការគ្រប់គ្រងពន្ធនាគារ ពោលគឺកម្លាំងការងារដែលមានការអប់រំហ្វឹកហ្វឺន គឺពុំឃើញមាន ។ ពេលដែលសួរឲ្យរៀបរាប់ចាត់លំដាប់ថ្នាក់សីលធម៌របស់ពួកគេសមាជិកក្រុមដែលបានចូលរួមប្រាំបីនាក់ លើដប់បីនាក់ បានចាត់ថ្នាក់វាថា"ល្អ" ហើយឯប្រាំនាក់ទៀតបាននិយាយថា "គ្រប់គ្រាន់ល្មម" ។(មើល<u>ឧបសម្ព័ន្ធ ២</u> សំណួរ M) ក៏ប៉ុន្តែក្រុមទាំងអស់បានត្អូញត្អែរអំពីប្រាក់ខែមិនគ្រប់គ្រាន់ ខ្វះសម្ភារៈប្រើប្រាស់ និងធនធានសំរាប់អនុវត្តភារកិច្ចរបស់គេ និងខ្វះការអប់រំហ្វឹនហ្វឺន ។ ប្រការនេះបានលេចឲ្យឃើញច្បាស់ នៅពេលទៅពិនិត្យពន្ធនាគារណាមួយ ។ គ្មានប្រដាប់ប្រដា សម្ភារៈ សមស្របសំរាប់ប្រើក្នុងការិយាល័យទេ ។ អ្នកជួយធ្វើការផ្សេងៗ សូម្បីបឋមវិធានក៏គ្មានដែរ ។ លើសពីនេះទៀតគេក៏ឃើញមានកង្វះដ៏សំខាន់មួយនៃបុគ្គលិក ដែលខ្វះសមត្ថភាពការងារ ។ ក្នុងដំណើរចុះពិនិត្យភាគច្រើនគេឃើញមានភ្នាក់ងារពន្ធនាគារតែមួយចំនួនតូចដែលបានបំពេញភារកិច្ចជាក់ស្តែង ។ គេអាចរំពឹងទុកថា ប្រហែលមានបុគ្គលិកក្នុងបញ្ជីតែមួយភាគបីទេដែលកំពុងបំពេញភារកិច្ចក្នុងពេលម្តងណាដែលគេចុះទៅមើល ប៉ុន្តែការពិតគឺករណីដូចគិតទុកនេះ គ្មានទេនៅតាមពន្ធនាគារជាច្រើន ។ ឯប្រព័ន្ធចាត់តាំងវេនបំពេញភារកិច្ចនៅតាមពន្ធនាគារភាគច្រើនវិញក៏ហាក់ដូចជាគ្មានរបៀប ឬមិនសមហេតុសមផល ។ ជារឿយៗ តាមរបាយការណ៍ គេបានដឹងថាមានបុគ្គលិកមួយចំនួនតូចបំពេញភារកិច្ចនៅម៉ោងរាត្រី ។ តំបន់សន្តិសុខគន្លឹះ ហាក់ដូចជាពុំសូវមានការយាមកាមឲ្យបានម៉ឺងម៉ាត់ទេ នៅតាមពន្ធនាគារភាគច្រើន ។ លក្ខណៈពិសេសមួយ នៃពន្ធនាគារទាំងអស់ដែលយើងបានចុះទៅពិនិត្យ លើកលែងតែសៀមរាប និងបាត់ដំបងចេញ គឺទម្លាប់ទុកទ្វារធំ ឬទ្វារមុខនៃពន្ធនាគារឲ្យនៅចំហរ ទោះបីជាមានទំហំធំនៃការងារលើក្រដាសស្នាមនៅក្នុងតំបន់ផ្សេងៗ ទៀតនៃការគ្រប់គ្រងពន្ធនាគារយ៉ាងណាក៏ដោយ ក៏វាហាក់ដូចជាមានឯកសារតែបន្តិចបន្តួច និងយាយពីចលនារបស់មនុស្សចូល ឬចេញពីពន្ធនាគារ ។

## <u>ការបិទទ្វារពន្ធនាគារ</u> T3 <u>និងការផ្ទេរទៅព្រៃស</u>

៤៦. ការលំបាកដែលនាយកដ្ឋានពន្ធនាគារបានប្រឈមមុខមានបង្ហាញច្បាស់ ដោយផែនការជ្រោមជ្រែងដោយរដ្ឋាភិបាលដើម្បីបិទពន្ធនាគារ T៣ ដែលស្ថិតនៅចំកណ្តាលទីក្រុងភ្នំពេញនៅលើដីមួយដុំដ៏ល្អ ហើយនិងផ្ទេរអ្នកទោសទៅកាន់ពន្ធនាគារព្រៃស ដែលមានលក្ខណៈពាក់កណ្តាលជនបទស្ថិតនៅប្រហែលដប់ប្រាំគីឡូម៉ែត្រពីមណ្ឌលទីក្រុង ។ ផែនការនេះគ្រោងពង្រីកអាគារមួយថ្មីនៅព្រៃសសំរាប់អ្នកទោសជាង ១០០០ នាក់ ។ តែគួរឲ្យស្តាយទីតាំងភូមិសាស្ត្រព្រៃស ជាតំបន់មួយដែលខ្វះទឹកជាប្រចាំ ដោយមកពីមានលក្ខណៈពុំអាចឲ្យ

គេរកទឹកល្អ សំរាប់ហូបចុកបានដោយយកទឹកពីអណ្តូង ។ ទោះបីជាទីនោះមានប្រជាពលរដ្ឋតិចក៏ដោយ ក៏អ្នកទោស ត្រូវតែជាធម្មតាទៅរែកទឹកពីកន្លែងមួយដែលស្ថិតនៅចម្ងាយជាងប្រាំរយម៉ែត្រអំពីអាងទឹកមួយដ៏ធំល្អល្មេរ នៅជាប់ក្បែរវត្តមួយ ។ លើសពីនេះទៀតការផ្ទេរទៅកាន់ព្រៃស និងនាំមកនូវការលំបាកយ៉ាងខ្លាំងខាងផ្នែកភស្តុភារ ជាពិសេសក្នុងការផ្ទេរអ្នកទោសទៅ និងមកពីទីក្រុង ។ ពន្ធនាគារគ្មានយានជំនិះសំរាប់ដឹកជញ្ជូនទេ ហើយពឹងផ្អែកលើយានជំនិះរបស់នគរបាល ឬយានជំនិះឯកជន សំរាប់គោលបំណងនេះ ។ ឯលទ្ធភាពរបស់គ្រួសារដើម្បីទៅសួរសុខទុក្ខញាតិមិត្តរបស់គេនៅឯពន្ធនាគារនោះ ក៏មានការលំបាកច្រើនជាងឯពន្ធនាគារ T៣ ដែរ ។ មើលទៅទំនងដូចជាអ្នកជាប់ក្នុងពន្ធនាគារជាមួយគ្នាពិតជាមិនអាចទទួលបាននូវកំរិតដូចគ្នានៃការគាំទ្រ និងការបន្ថែមបង្គ្រប់ភស្តុភារខាងស្បៀង ដូចដែលគេអាចទទួលបាននាពេលនេះនៅឯ T៣ ។ លទ្ធភាពដើម្បីដឹកជញ្ជូនអ្នកទោសទៅ និងមកពីតុលាការ គឺជាការលំបាកមួយទៀតជាពិសេស ។ នៅទីបំផុត ក៏គ្មានលុយកាក់សំរាប់អនុវត្តកិច្ចការនេះដែរ ។ បើសិនជាចំណូលបានមកពីការលក់ពន្ធនាគារ T៣ មិនបានយកទៅបំរើដោយផ្ទាល់ក្នុងគំរោងទេនោះ គេមិនសូវរំពឹងថាគំរោងនេះនឹងបានទទួលជោគជ័យទេ ។ មិនតែប៉ុណ្ណោះ ចំណូលបានមកពីការលក់នេះ ប្រហែលជាមិនអាចឆ្លើយតបបាននឹងតម្លៃសំរាប់គ្រប់គ្រងកិច្ចការនេះក្នុងរយៈពេលយូរបានឡើយ ។

## មណ្ឌលសំរាប់អ្នកប្រព្រឹត្តបទល្មើស

៤៧. ឧទាហរណ៍មួយទៀតនៃបញ្ហាប្រឈមមុខចំពោះរដ្ឋបាលពន្ធនាគារ គឺអនុក្រឹត្យ ១៧ ចុះថ្ងៃ ១៩ មេសា ១៩៩៤ ។ បន្ទាប់ពីមានសំណូមពរពីគណៈកម្មការសិទ្ធិមនុស្សរបស់សភាជាតិ រាជរដ្ឋាភិបាលបានអនុញ្ញាតឲ្យបង្កើត "មណ្ឌលសំរាប់យុវជនដែលបានប្រព្រឹត្តល្មើស" ដែលតាមមាត្រា ១ នៃអនុក្រឹត្យ ត្រូវ :

> "មានសមត្ថកិច្ចក្នុងការគ្រប់គ្រងកុមារពីអាយុ ៧ ដល់ ១៧ ឆ្នាំ ដែលបានប្រព្រឹត្តអំពើចាកកន្លងធម៌ដូចជា អំពើមានៈខុសសីលធម៌ អំពើចោរកម្ម និងឆក់ប្លន់ នៅទូទាំងប្រទេស ហើយនិងមានភារកិច្ចត្រូវពង្រីកធនធានខាងវិស័យមនុស្ស ទាំងការចិញ្ចឹមជីវិតខាងស្មារតី និងសម្ភារៈ កែប្រែមនុស្សដែលគ្មានវិន័យ និងគ្មានសីលធម៌ឲ្យប្រែជាមនុស្សសុចរិត មានវិន័យល្អត្រឹមត្រូវ" ។

ក្នុងខណៈដែលអនុក្រឹត្យបានចែងបន្ថែមទៀតពីទិសដៅ និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់មណ្ឌលនេះ គេពុំឃើញមានការលែតំរូវមូលនិធិបែបណាមួយសំរាប់គំរោងនេះឡើយ ។ បើពុំមានមូលនិធិ ឬជំនួយឧបត្ថម្ភពីអន្តរជាតិទេ យុវជននៅក្នុងពន្ធនាគារកម្ពុជា នឹងបន្តនៅជាប់គុកជាមួយមនុស្សចាស់ៗ ក្នុងករណីច្រើនយ៉ាង ។

ជំពូក៥

## លក្ខខណ្ឌ : ចាប់ឲ្យបាច់កុំឲ្យទាធ្លាក់ធាន់

### សេចក្ដីផ្ដើម

៤៨. ពន្ធនាគារស៊ីវិលទាំងម្ភៃបួន ជាសំខាន់គឺជាសំណង់តាមបែបផែនរចនាសម្ព័ន្ធចំរុះតាមលំដាប់ពេលវេលានៃយុគសម័យត្រូវកាន់កាប់នាពេលថ្មីៗ ដោយអាណានិគមនិយមបារាំង និងវៀតណាម (ទសវត្សរ៍ឆ្នាំ ៨០)។ ពន្ធនាគារទាំងអស់សុទ្ធតែចាំបាច់ត្រូវមានកែឆ្នៃឲ្យថ្មីតាមកំរិតខ្លះ ។ សំណង់ខ្លះបានបាក់ស្រុតរលំទៅតែម្តង ។ ការត្អូញត្អែរម្យ៉ាងក្នុងចំណោមការត្អូញត្អែរដែលគេឮញឹកញាប់ជាគេពីនាយកពន្ធនាគារ និងអភិបាលរងទី២ គឺនៅត្រង់គេគ្មានមូលនិធិសំរាប់ការជួសជុលជាមូលដ្ឋានលើរបស់អស់ទាំងនេះដូចជាដំបូលលិចទ្វារបែកបាក់ចង្ក្រានពុក និងប្រព័ន្ធលូទឹកស្អុយត្រូវស្ទះ ។



ចង្ក្រាន - ពន្ធនាគារស្វាយរៀង

៤៩. កំណត់អាយុកាលគិតជាមធ្យម នៃពន្ធនាគារទាំងដប់បីដែល PAP បានចុះទៅពិនិត្យមើលគឺ ៤០ ឆ្នាំប្លាយហើយ ។ ប៉ុន្តែ អាយុកាលនេះមិនសូវជាទាក់ទងសំខាន់ប៉ុន្មានទៅនឹងស្ថានភាពរបស់ពន្ធនាគារទេ ។ ឧទាហរណ៍ពន្ធនាគារតាខ្មៅ ដែលត្រូវសាងសង់ក្នុងឆ្នាំ ១៩៨០ នៅលើទីកន្លែងនៃរោងចក្រផលិតក្រណាត់អំបោះកប្បាស់មួយដ៏ចាស់ ឥឡូវស្ថិតក្នុងស្ថានភាពមួយគួរឲ្យស្ដាយ ។ បញ្ហានេះបណ្តាលមកយ៉ាងខ្លាំងពីប្លង់ និងសំណង់ដែលគេមិនបានយកចិត្តទុកគិតគូរឲ្យបានដិតដល់ ហើយព្រមទាំងគ្មានកម្មវិធីថែទាំផង ។ ម្យ៉ាងវិញទៀត ពន្ធនាគារបាត់ដំបងសង់ឡើងប្រហែលនៅឆ្នាំ ១៩៣០ ដោយពួកបារាំង គឺស្ថិតនៅក្នុង

ស្ថានភាពដ៏ល្អគួរឲ្យកត់សំគាល់ លើកលែងតែស្រទាប់ជញ្ជាំងពីខាងក្រៅប៉ុណ្ណោះ ។ គេអាចមានមតិស្របគ្នាទាំងស្រុងទៅលើតម្រូវការជួសជុលតូចតែបន្តិចបន្តួចប៉ុណ្ណោះ ។ នៅពន្ធនាគារខ្លះដូចជា T៣ និងពន្ធនាគារព្រៃស បន្ទប់ឃុំឃាំងតូចៗដែលអាចមានចំនួនមួយភាគមិនអាចឲ្យប្រើប្រាស់បានដោយជួសជុលមិនកើត ។

៥០. ស្ថានភាពយ៉ាប់យ៉ឺនខាងរូបវន្តនៃពន្ធនាគារកម្ពុជា មានផលប៉ះពាល់ដល់សុខភាពរបស់មនុស្សដែលរស់នៅក្នុងទីនោះជាពិសេស និងសុខុមាលភាពជាទូទៅរបស់គេ ។ វាក៏មានចំណែកមួយរួមក្នុងការខ្វះសន្តិសុខ មិនបានគ្រប់គ្រាន់ ។ ដោយជញ្ជាំង និងដំបូលពុក ហើយក្នុងករណីខ្លះ ត្រូវបែកបាក់រលំដួលតែម្តង លទ្ធភាពដើម្បីធានាសន្តិសុខដល់ពន្ធនាគារកាន់តែមានការលំបាកខ្លាំងឡើងៗ ។ បញ្ហានេះកាន់តែធ្ងន់ធ្ងរថែមទៀតកាលបើមនុស្សរស់នៅក្នុងពន្ធនាគារកាន់តែមានចំនួនកើនឡើងៗ ។

## ទំហំរបស់ក្រុមបន្ទប់តូចៗ

៥១. ចំនួនភាគច្រើននៃអ្នកទោសខ្មែរក្នុងពន្ធនាគារត្រូវគេដាក់ឃុំក្នុងបន្ទប់តូចៗ ជាក្រុមៗ ដែលមានជាងសែសិបភាគរយរស់នៅក្នុងបន្ទប់តូចៗច្រើន ដោយមានមនុស្សពីដប់ទៅសាមសិបនាក់ ( មើលតារាង ៥.១ ) ។

តារាង ៥.១ : ទំហំរបស់ក្រុមបន្ទប់តូចៗ

| ក្រុមបន្ទប់តូចៗ | ចំនួនអ្នកនៅ | ភាគរយ | CUM. |
|---|---|---|---|
| ០ ដល់ ៩ | ១៧ | ២០,០% | ២០,០% |
| ១០ ដល់ ១៩ | ១៥ | ១៧,០% | ៣៧,៦% |
| ២០ ដល់ ២៩ | ២០ | ២៣,៥% | ៦១, ២% |
| ៣០ ដល់ ៣៩ | ៨ | ៩,៤% | ៧០,៦% |
| ៤០ ដល់ ៤៩ | ៨ | ៩,៤% | ៨០,០% |
| ៦០ ដល់ ៦៩ | ១២ | ១៤,១% | ៩៥,១% |
| ៧០ ដល់ ៧៩ | ៥ | ៥,៩% | ១០០,០% |
| សរុប | ៨៥ | ១០០,០% | |

៥២. ប៉ុន្តែ ចំនួននៅក្នុងបន្ទប់តូចៗបានធ្លាក់ចុះ ។ ចំនួនត្រួសៗ គិតជាមធ្យមនៃទំហំក្រុមបន្ទប់តូចៗ ជារួមបាយថយចុះរហូតដល់ចំនួនម្ភៃមួយនាក់ ពីចំនួនសែសិបប្រាំបីជាមធ្យមក្នុងក្របខ័ណ្ឌនៃស្មារតីរបស់អ្នកដែលត្រូវគេរើសជាសំណាក់ ។ ចំនួនហាសិបប្រាំបីនៃអ្នក

ឆ្លើយតបបានបញ្ជាក់ថា ឥឡូវនេះមានមនុស្សនៅក្នុងបន្ទប់តូចៗច្រើនជាងពីពេលមុនដែលនៅក្នុងដំណាក់របស់គេ ជាប់ពន្ធនាគារ ។

## ពេលម៉ោងនៅបន្ទប់តូចៗ

៥០. អ្នករស់នៅក្នុងគុកត្រូវគេបង្ខាំងចាក់សោទុកក្នុងបន្ទប់តូចៗ ជាមធ្យម ២១ ម៉ោងក្នុងមួយថ្ងៃ ។ លំដាប់លំដោយនៃពេលវេលានេះមានបង្ហាញក្នុងតារាង ៥.២ ។

តារាង ៥.២ : ពេលម៉ោងនៅក្នុងបន្ទប់តូច

| ពេលម៉ោងក្នុងបន្ទប់តូចៗ | អ្នកនៅ | ភាគរយ | CUM- |
|---|---|---|---|
| ០ | ១ | ១,២% | ១,២% |
| ១៤ | ១ | ២,៤% | ២,៤% |
| ១៥ | ៣ | ៣,៥% | ៥,៩% |
| ១៦ | ៣ | ៣,៥% | ៩,៤% |
| ១៨ | ១ | ១,២% | ១០,៦% |
| ១៩ | ១៣ | ១៥,៣% | ២៥,៩% |
| ២០ | ១០ | ១១,៦% | ៣៧,៦% |
| ២១ | ៨ | ៩,៤% | ៤៧% |
| ២២ | ១១ | ១២,៩% | ៦០,០% |
| ២៣ | ១៨ | ២១,២% | ៨១,២% |
| ២៤ | ១៦ | ១៨,៨% | ១០០,០% |
| សរុប | ៨៥ | ១០០,០% | |

៥៤. ពន្ធនាគារខ្លះមានភាពធ្ងន់ធ្ងរជាងពន្ធនាគារឯទៀតៗ ក្នុងរឿងនេះ ។ ឧទាហរណ៍ អ្នកទោសទាំងអស់នៅក្នុងពន្ធនាគារតាខ្មៅ និងពន្ធនាគារ PJ ត្រូវបង្ខាំងទុកចាក់សោក្នុងបន្ទប់តូចចំនួនម្ភៃបួនម៉ោងក្នុងមួយថ្ងៃ គេមានឱកាសបានរួចខ្លួនពីបន្ទប់នោះតែក្នុងពេលទៅរកទឹក និងបន្ទោរបង់លាមកតែប៉ុណ្ណោះ ។ បើសិនជាយើងចាត់ទុកការបង្ខាំងអ្នកទោសចាក់សោជាប់ក្នុងបន្ទប់តូចចំនួនម្ភៃម៉ោង ឬលើសពីនេះថាច្រើនហួសហេតុនោះ នោះចំនួនហុកសិបបី (៧៤%) នៃអ្នកទោសសំណាក ត្រូវទទួលរងការឈឺចាប់ពីអំពើនេះ ។ ជាពិសេសពន្ធនាគារអាក្រក់ៗក្នុងវិស័យនេះ ត្រូវបានបង្ហាញក្នុងតារាង ៥.៣ ។

តារាង ៥.៣ : ពន្ធនាគារដែលអនុវត្តម៉ោងបន្ទប់តូចច្រើនហួសហេតុ

| ឈ្មោះពន្ធនាគារ | ចំនួនអ្នកទោស > ១៩ ម៉ោងក្នុងបន្ទប់តូច | ចំនួនអ្នកទោស ត្រូវធ្វើសម្ភាសន៍ |
|---|---|---|
| បាត់ដំបង | ៤ | ១០ |
| កំពង់ចាម | ៦ | ៦ |
| កំពង់ចាម (T5) | ១០ | ១៣ |
| កំពង់សោម | ៣ | ៣ |
| P.J. | ៩ | ៩ |
| ព្រៃវែង | ៤ | ៦ |
| ពោធិសាត់ | ២ | ៣ |
| ស្វាយរៀង | ៥ | ៥ |
| T3 | ៧ | ៨ |
| តាខ្មៅ | ៦ | ៦ |

៥៥. ពន្ធនាគារដប់នៃចំនួនដប់បីដែលត្រូវត្រួតពិនិត្យបានបង្ខាំងអ្នកទោសចាក់សោចោលក្នុងរយៈពេលមួយហួសហេតុក្នុងមួយថ្ងៃ ។ តាមពិត ចំនួនសាមសិបបួន (៨៤%) នៃក្រុមជាសំណាក ត្រូវចាក់សោជាប់ពីម្ភៃបីទៅម្ភៃបួនម៉ោងក្នុងមួយថ្ងៃ ហើយការធ្វើបែបនេះកើតមានចំពោះអ្នកទោសនៅពន្ធនាគារប្រាំបីដែលបានត្រួតពិនិត្យមើលដូចមានបង្ហាញក្នុងតារាង៥.៤ ។

តារាង៥.៤ ៖ ពន្ធនាគារដែលអ្នកជាប់ឃុំត្រូវបង្ខំងទុកចាក់សោជាប់ជាងម្ភៃពីរម៉ោង

| នាមពន្ធនាគារ | ម៉ោងពេល | | សរុប |
|---|---|---|---|
| | ២៣ | ២៤ | |
| បាត់ដំបង | ៣ | ០ | ៣ |
| កំពង់ចាម | ២ | ១ | ៣ |
| កំពង់ចាម (T5) | ៤ | ០ | ៤ |
| កំពង់សោម | ២ | ០ | ២ |
| P.J. | ០ | ៩ | ៩ |
| ព្រៃវែង | ២ | ០ | ២ |
| T3 | ៥ | ០ | ៥ |
| តាខ្មៅ | ០ | ៦ | ៦ |
| សរុប | ១៤ | ១៦ | ៣៤ |

## ស្ថានភាពអនាម័យ

៥៦. ស្ថានភាពអនាម័យនៅក្នុងពន្ធនាគារកម្ពុជាមានការខុសៗគ្នាយ៉ាងច្រើន ។ នៅពន្ធនាគារ P.J. ករណីដែលធ្ងន់ធ្ងរបំផុតគឺ ប្រព័ន្ធលូទឹកស្អុយលិចហូរហៀរ និង/ឬ ស្ទះ មានការខ្វះទឹក ហើយគ្មានសាប៊ូ ។ នៅខេត្តព្រៃវែង ពួកអ្នកទោសត្រូវគេបង្ខំឲ្យជុះនោមលើទីកំរាលនៃបន្ទប់តូចទុកឲ្យវាហូរទៅតាមបំពង់បង្ហូរទឹកដែលហូរចុះទៅខាងក្រោមទ្វារចូលធំ ។ ប៉ុន្តែ អ្នកទោសនៅសៀមរាបមានសិទ្ធិអាចទៅបន្ទប់ទឹកដែលដើរ ហើយការផ្គត់ផ្គង់ទឹកក៏មានការធានាបានជាទូទៅ ។ នៅព្រៃស បន្ទប់តូចត្រូវសំអាតបានស្អាតបាន ។

៥៧. ជាទូទៅ ការផ្តល់សាប៊ូប្រើប្រាស់មិនបានគ្រប់គ្រាន់ ឯភ្នាក់ងារបោសសំអាតក៏មិនសូវមានដែរ ។ បន្ទប់តូចភាគច្រើនគ្មានបន្ទប់ទឹកបង្គន់ទេ ឬក៏មានគ្រប់គ្រាន់ ។ លាមកជាធម្មតាត្រូវប្រមូលដាក់ក្នុងថង់ប្លាស្ទិក ហើយចាក់វាចោលម្តង ឬពីរដងក្នុងមួយថ្ងៃ ។ អ្នកទោសទាំងអស់ត្រូវគេតំរូវជាទូទៅឲ្យហូបចុកក្នុងបន្ទប់តូចរបស់គេជាញឹកញយ ត្រូវរួមគ្នាប្រើសម្ភារៈសំរាប់ហូបចុក និងចានជាមួយគ្នាដោយសម្ភារៈ និងចានត្រូវខ្វះទូទាំងប្រព័ន្ធ ។ ក៏មានការខ្វះជាទូទៅនូវសំលៀកបំពាក់សំរាប់ពន្ធនាគារ (ខោខ្លីក្រណាត់អំបោះទេសឯកពណ៌ខៀវទឹកសមុទ្រ និងអាវកាក់) ភួយ កន្ទេល និងមុង ។ អ្នកទោសភាគច្រើនដេកលើកន្ទេលផ្ទាល់លើកម្រាលស៊ីម៉ង់ ។ កន្លែងរៀបចំម្ហូបអាហារច្រើនតែគ្មានអនាម័យ និងទ្រុឌទ្រោម ។

ពន្ធនាគារភាគច្រើនៗ តែគ្មានរបបស្តារប្រព័ន្ធលូទឹកស្អុយ និងកើបកាកសំណល់ចោល ។ នេះមិនមែនគ្រាន់តែជាបញ្ហានៃធនធានប៉ុណ្ណោះទេ តែក៏ជាបញ្ហានៃអត្តចរិត និងចំណេះដឹងផងដែរ ។ កម្មវិធីសិក្សាក្នុងវិស័យសុខាភិបាល អាចទប់ស្កាត់ជម្ងឺដម្កាត់ និងមរណភាពបានមួយចំនួនធំក្នុងពន្ធនាគារកម្ពុជា ។

៥៨. អ្នកទោសភាគច្រើនអាចងូតទឹកបានទៀងទាត់ ។ ពីរភាគនៃអ្នកដែលគេចាត់ជាសំណាក ងូតទឹកពីរដង ឬលើសពីរដងក្នុងមួយថ្ងៃ ។ តាមការពិតប្រការនេះគឺជា"សកម្មភាពលំហែកំសាន្ត" ដ៏សំខាន់ ។ ប៉ុន្តែ គួរឲ្យស្តាយអ្នកទោសជាច្រើនឥតបានទទួលសាប៊ូ ឬគ្រឿងសំអិតសំអាងសំអាតកាយទេ ។ មានតែពន្ធនាគារនៅឯបាត់ដំបង T3 កំពង់សោម ព្រៃសពោធិសាត់ សៀមរាប និងពន្ធនាគារ T3 ទេ ដែលគេបានផ្តល់សាប៊ូបានទៀងទាត់ ។ ដោយហេតុនេះ អ្នកទោសជាច្រើនត្រូវទុកចោលដោយមានតែទឹក (ច្រើនតែទឹកកខ្វក់) សំរាប់តែសំអិត សំអាតខ្លួនប៉ុណ្ណោះ ។ អ្នកសួរសុខទុក្ខគ្រួសារ បានផ្តល់វត្ថុចាំបាច់ៗ ដូចយ៉ាងនេះបានត្រឹមតែចំនួនក្រោម ៥% ប៉ុណ្ណោះ ។ សំណាកនៃការត្អូញត្អែររបស់អ្នកទោសដូចមាននៅក្នុងតារាង ៥.៥ ស្តីពីស្ថានភាពអនាម័យបានក្លោបបញ្ហាជាច្រើនដែលប្រឈមមុខចំពោះអាជ្ញាធរពន្ធនាគារ ។ ពាក្យត្អូញត្អែរ ដែលគេតែងតែឮច្រើនជាងគេបំផុត គឺខ្លិនស្អុយ កណ្តុរមួយឬពីរ និងកន្ទាត គ្មានសាប៊ូ និងខ្វះទឹក ។

| តារាង ៥.៥ : ពាក្យត្អូញត្អែររបស់អ្នកទោសអំពីស្ថានភាពអនាម័យ |
|---|
| កណ្តុរ/កូនមាន់ក្នុងបន្ទប់តូច |
| ក្លិនស្អុយ គ្មានបង្គន់ |
| គ្មានថ្នាំសង្កូវសំរាប់រមាស់ |
| គ្មានកន្សែងអនាម័យ |
| គ្មានសាប៊ូ |
| ជួនកាលគ្មានទឹកប្រើប្រាស់ ក្លិនស្អុយ |
| សាប៊ូមិនគ្រប់គ្រាន់ |
| ទឹកមិនគ្រប់គ្រាន់ |
| ចំណីអាហារជួនកាលចំអិនមិនបានត្រឹមត្រូវ កន្លែងមុជទឹក-បង្គន់មិនស្អាត |
| មានមូសច្រើន ហើយអ្នកទោសគ្មានមុង |
| មានកណ្តុរ និងកន្លាតច្រើន |
| មានសត្វល្អិតចង្រៃ ដូចជាសង្កើច ស្រមើលយ៉ាងច្រើន ទឹកមិនគ្រប់គ្រាន់ |
| សំរាប់ងូតជុសលាងខ្លួនប្រាណ |
| ពេលវេលានៅខាងក្រៅបន្ទប់តូចមិនគ្រប់គ្រាន់សំរាប់ជុសលាងខ្លួន |
| មិនអាចប្រើបង្គន់ បន្ទប់ទឹក ក្នុងពេលត្រូវចាក់សោឃុំជាប់ក្នុងបន្ទប់ |
| គ្មានបន្ទប់ទឹក-បង្គន់នៅក្នុងបន្ទប់តូច/អ្នកទោសនោមដាក់លើទីដែលខ្លួនដេកនៅ |
| គ្មានបន្ទប់ទឹក-បង្គន់ ឬធុង សំរាប់ជុះនោម |

៥៩. អ្នកទោស ៧៨ នាក់ដែលគេបានជួបសម្ភាសន៍បានឲ្យដឹងថាស្ថានភាព បន្ទប់តូចបានផ្លាស់ប្តូរទៅតាមរដូវ ភាគច្រើនបានបកស្រាយថា បន្ទប់តូចរបស់ខ្លួនបានក្លាយទៅជាក្តៅជាពិសេសក្នុងរដូវក្តៅ ។

## កម្មវិធីទឹក និងអនាម័យរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ ( ICRC )

៦០. កម្មវិធីទឹក និងអនាម័យ ( WATSAN ) អនុវត្តជាក់ស្តែងដោយ ICRC គឺជាឧទាហរណ៍មួយដ៏ល្អនៃការប្រើប្រាស់បុគ្គលិក និងមូលនិធិតាមរបៀបថ្មី ដើម្បីបង្កើតឲ្យបាននូវការកែលំអពិតនៅក្នុងពន្ធនាគារកម្ពុជា ហើយទីបំផុតបានសង្គ្រោះអាយុជីវិតមនុស្ស ។ ICRC បានជួលវិស្វករម្នាក់ និងបុគ្គលិកជាច្រើនសំរាប់ជួយជ្រោមជ្រែងក្នុងរយៈពេលលើសពីដប់ពីរខែបន្តិចក្នុងឆ្នាំ ១៩៩៣-១៩៩៤ និងចាត់ចែងការកែលំអឡើងវិញ ( ទាំងស្រុង ឬជាផ្នែក ) នូវ

ហេដ្ឋារចនាសម្ព័ន្ធទាំងទឹក និងអនាម័យនៅពន្ធនាគារដប់ប្រាំបី ។ ការធ្វើអន្តរាគមន៍តាមបែបនេះអាចមានម្តងហើយម្តងទៀតនៅតំបន់ផ្សេងៗទៀតដែលទាមទារការយកចិត្តទុកដាក់បន្ទាន់ដូចប្រក់ដំបូល ចង្ក្រាន ។ល។

## ចំណីអាហារ

៦១. អ្នកទោសកម្ពុជាភាគច្រើនមានការអត់ឃ្លានជានិច្ចកាល ។ គេបានលៃប្រាក់ ១.០០០រៀល សំរាប់អ្នកទោសកម្ពុជាម្នាក់ៗ ក្នុងមួយថ្ងៃ ភាគច្រើននៃចំនួនទឹកប្រាក់នេះធ្លាក់ទៅលើតម្លៃអាហារ អុសដុត/ធ្យូងថ្ម សំរាប់ចំអិនអាហារ ។ អ្នកទោសស្ទើរតែទាំងអស់ហូបចុកចំណីអាហារនៅក្នុងបន្ទប់តូចរបស់គេចំនួនពីរពេលក្នុងមួយថ្ងៃ ជាធម្មតានៅម៉ោង ប្រហែល ១០.៣០នាទី និង ៣.៣០នាទី ។ មានការប្រែប្រួលបន្តិចបន្តួច ។ ម្ហូបចំណីជាធម្មតាមានសម្ល ម្ជូរ ឬបាយ ដោយមានបន្លែដូចជាស្ពៃ ខាត់ណា ជួនកាលមានត្រី មាន់ សាច់គោ ។ នៅឯពន្ធនាគារ P.J. អ្នកទោសទទួលបានអាហារក្នុងមួយថ្ងៃតែមួយពេលទេ ។ ប្រការនេះត្រូវបញ្ជាក់ បានដោយឈរលើមូលដ្ឋានដែលវាជាអាហារមួយពេលទេ ។ ប្រការនេះត្រូបញ្ជាក់បានដោយ ឈរលើមូលដ្ឋានដែលវាជាអាហារមួយពេលដ៏ធំហូបសំរាប់ឆ្អែតមួយថ្ងៃ ។ ពាក្យសំដីត្អូញត្អែរ សំខាន់ៗរបស់អ្នកទោសគឺការខ្វះអាហារ ដែលផ្តល់មិនបានគ្រប់គ្រាន់ ។ អ្នកទោសហុកសិបប្រាំមួយ (៧៨%) បានត្អូញថាគេហូបមិនឆ្អែត ដោយអាហារមិនគ្រប់គ្រាន់ ។ ពេលដែលគេហៅអ្នកទោសឲ្យប្រាប់បញ្ហាដ៏ធំបំផុតនៅក្នុងពន្ធនាគារ" ម្ហូបចំណី" ក៏ត្រូវបានដោះស្រាយមុនអ្វីៗទាំងអស់ (**មើលឌីយ៉ាក្រាមរង្វង់មូល ៥.១**)

**ទិយាក្រាមរង្វង់មូល ៥.១ សេចក្តីថ្លែងបញ្ជាក់បញ្ហាដោយពន្ធនាគារ**




៦២. សម្ភារៈចំអិនអាហារ ស្ទើរតែគ្រប់ករណីកាន់តែហោចទៅៗ ហើយជារបស់ចាស់អន់ថយ ។ ជាសំខាន់ វាមានតែខ្ទះធំៗ លើចង្ក្រានឥដ្ឋដុតខុស/ធ្យូង ។ ចំណីអាហារជាធម្មតាត្រូវបែងចែកជាពីរឆ្នាំងធំៗ ទៅតាមបន្ទប់ រួចហើយត្រូវបែងចែកបន្តទៅក្នុងបន្ទប់តូច ។ កន្លែងរៀបចំម្ហូបអាហារមិនបានដាក់សំណាញ់ឲ្យគ្រប់គ្រាន់ដើម្បីបញ្ចៀសការច្រៀតចូលដោយមាន់ទា និងជ្រូកទេ ។



ច្បារដំណាំ – ពន្ធនាគារកំពង់ចាម

## ផ្នែកពេទ្យ

ក្នុងឋានៈជាផ្នែករបស់ PAP ARC និង PHR ត្រូវបានស្នើឲ្យចូលរួម ( មើលជំពូក២ ) ។ គេបានធ្វើសម្ភាសន៍ជាមួយអ្នកទោសក្នុងពន្ធនាគារប្រហែលប្រាំភាគរយនៃពន្ធនាគារដប់បី ហើយបានធ្វើការត្រួតពិនិត្យស្ថានភាពដែលទាក់ទងជាពិសេសទៅនឹងការថែទាំសុខភាព ។ ( PHR កំពុងតែរៀបចំដាក់បញ្ជូនរបាយការណ៍មួយទៅកាន់ការិយាល័យកម្ពុជាស្តីពីលទ្ធផលដែលគេបានរកឃើញសំរាប់ជាជំនួយឧបត្ថម្ភដល់រាជរដ្ឋាភិបាល ) ។ ( ប៉ុន្តែ ការសរុបលទ្ធផលដោយសង្ខេបពីការត្រួតពិនិត្យអ្នកទោសជាទូទៅបានផ្តល់ឲ្យនូវទស្សនៈជារួមលើវិស័យទាំងនេះ ) ។ ពន្ធនាគារទាំងអស់នៅក្នុងកិច្ចការត្រួតពិនិត្យឃើញថាមានប្រដាប់ប្រដាប្រើប្រាស់ខាងពេទ្យមិនបានគ្រប់គ្រាន់ទេ ។ រីឯពន្ធនាគារដប់មួយដែលបានចុះទៅមើល បានរៀបចំចាត់ចែងឲ្យមានអ្នកជួយធ្វើការក្នុងកិច្ចការថែទាំសុខភាព ( លើកលែងតែស្វាយរៀង និងព្រៃសចេញ ) នោះវិញ ពុំឃើញពន្ធនាគារណាមួយមានសម្ភារៈបរិក្ខារ ឬសម្ភារៈប្រើប្រាស់បំរើកិច្ចការនេះទេ ។ ក្រៅពីនេះ អ្នកទាំងនេះបានទទួលការហ្វឹកហ្វឺនតិចតួចណាស់ ។ អ្នកទោសក្នុងពន្ធនាគារភាគច្រើន ច្រើនតែពឹងផ្អែកលើគ្រួសាររបស់គេដើម្បីរកថ្នាំសង្កូវជាមូលដ្ឋាន ។ អ្នកទោស តែងតែត្រូវបញ្ជូនទៅមន្ទីរពេទ្យមូលដ្ឋានពេលដែលគេឈឺធ្ងន់ ប៉ុន្តែកិច្ចការនេះមិនមែនមិនប្រែប្រួលទេ ។ ក្រុមរបស់ PAP បានរកឃើញករណីជាច្រើននៃអ្នកទោសឈឺធ្ងន់ ឬរបួសធ្ងន់ដែលទាមទារឲ្យសំរាកពេទ្យជាបន្ទាន់ រ៉ាំរ៉ៃ ក្នុងពន្ធនាគារ ។ ជាមួយគ្នានេះដែរ គេក៏បានឃើញថា អ្នកទោសដែលមានជម្ងឺឆ្លងដូចជាជម្ងឺរបេង ភាគច្រើនគឺមិនត្រូវធ្វើរោគវិនិច្ឆ័យ ឬបំបែកឲ្យនៅដោយឡែកពីគេទេ ។ អ្នកទោសហាសិបភាគរយបានរាយការណ៍ឲ្យដឹងថា សុខភាពរបស់គេមិនល្អ ( មើលឌីយ៉ាក្រាមរង្វង់មូល ៥.២ ) ។ អ្នកទោសចាត់ជាសំណាកចំនួនហាសិបនាក់ បានបញ្ជាក់ថាគេមានការឈឺចាប់ដោយមានជម្ងឺ ។ បញ្ហាទាំងនេះត្រូវសរុបក្នុងតារាង ៥.៦ ។

## ទីយ៉ាក្រាមរង្វង់មូល ៥.២ សុខភាពរបស់អ្នកទោសតាមការរាយការណ៍




៦៥. ក្រសួងមហាផ្ទៃបានដាក់ឲ្យដំណើរការនូវ "មន្ទីរពេទ្យនគរបាលមួយ" នៅទីក្រុងភ្នំពេញ ប៉ុន្តែមន្ទីរពេទ្យខ្វះធនធានយ៉ាងច្រើន ហើយមានសម្ភារៈប្រើប្រាស់តែបន្តិចបន្តួច ។ ការផ្គត់ផ្គង់អគ្គិសនីដល់មន្ទីរពេទ្យនេះគឺស្ទើរតែគ្មាន ។ មានផ្នែកផ្សេងៗជាច្រើនសំរាប់បំរើអ្នកទោសក្នុងមន្ទីរពេទ្យនេះ ប៉ុន្តែមានតែអ្នកទោសមួយចំនួនទេ ដែលត្រូវទទួលជាក់ស្តែង ព្រោះតែបញ្ហាខ្វះសម្ភារៈប្រើប្រាស់នេះឯង ។ អ្នកទោសភាគច្រើននៅទីក្រុងភ្នំពេញមានសុខភាពល្អ បើសិនជាគេស្នាក់នៅក្នុងពន្ធនាគាររៀងៗរបស់គេ ហើយទទួលការព្យាបាលពីក្រុមគ្រូពេទ្យ លីកាដូ និងក្រុមគ្រូពេទ្យពិភពលោកដែលបានចុះមកមើល ។

៦៦. អង្គការ លីកាដូ ជាអង្គការក្រៅរដ្ឋាភិបាលខាងសិទ្ធិមនុស្ស និងអង្គការគ្រូពេទ្យពិភពលោក ជាអង្គការក្រៅរដ្ឋាភិបាលខាងពេទ្យ បានទទួលត្រួតពិនិត្យសុខភាព និងចែកថ្នាំជាមូលដ្ឋានដល់អ្នកទោសក្នុងពន្ធនាគារនៅភ្នំពេញ PJ T3 ពន្ធនាគារព្រៃស ពន្ធនាគារតាខ្មៅ និងពន្ធនាគារ ( យោធា ) ទួលស្លែង ។ តែគួរឲ្យស្តាយ បើសិនជាមានវិញ គឺមានតិចពេកនូវជំនួយឧបត្ថម្ភដល់ពន្ធនាគារខេត្ត ។

តារាង ៥.៦ : ជម្ងឺរបស់អ្នកទោសតាមរាយការណ៍

| |
|---|
| ជម្ងឺស្អក |
| ភ្នែកស្រវាំង-ព្រិល ជម្ងឺវិលមុខ |
| ជម្ងឺស្អក ជម្ងឺត្រចៀកថ្លង់/ជម្ងឺភ្លក |
| ជម្ងឺប្ញសកញ្ជ្រឹងករវ៉ាំរ៉ៃ |
| ជម្ងឺឈឺទ្រូង |
| ឈឺទ្រូងបណ្តាលមកពីការវាយដំក្នុងពេលសួរចម្លើយ |
| ជម្ងឺគ្រុនរងា វិលមុខ ឈឺពោះ |

ជម្ងឺវិលមុខ ចំណែកគ្រាប់បែកជាប់នៅនឹងជើង
ជម្ងឺរាគរូស និងជម្ងឺគ្រុនចាញ់
ជម្ងឺហេវហត់
ជម្ងឺគ្រុន រាគរូស ត្រចៀកស្តាប់មិនបាន
ឈឺចង្កេះខ្នង ចុកដៃ ជួនកាលគ្រុនពេលយប់/ឈឺក្បាល
ឈឺគ្រពះ
ឈឺក្បាល និងគ្រុន
គ្រុនសន្និ កមរមាស់
ស្ពឹកជើងទាំងពីរ ជួនកាល
ប៉ះក្បាលខ្លាំង (ដោយត្រូវប៉ូលីស និងប្រជាជនវាយដំ)
ជម្ងឺបេះដូងខ្សោយ
ជម្ងឺឫសដូងបាត ក្លនលូន និងជម្ងឺបេះដូង
សម្ពាធឈាមឡើងខ្ពស់
ជម្ងឺគ្រុនចាញ់តាំងពីខែសីហា ១៩៩៣
ជម្ងឺស្ពឹក ឈឺសន្លាក់ឆ្អឹង ហេវហត់ជានិច្ចកាល
របួសចាស់នៅលើខ្លួនប្រាណ និងភ្នែកស្រវាំងមើលមិនច្បាស់
ជើងម្ខាងខ្សោយ
ឈឺចាប់ត្រង់របួសចាស់នៃក្បាល
ជម្ងឺហើមពងស្វាស
ជម្ងឺហើមជើង និងហើមពោះ
កមរមាស់
មិនអាចដេកផ្ងារបាន
មិនអាចដេកផ្អៀងទៅខាងឆ្វេងបាន
ឈឺទ្រូង
ឈឺទ្រូងក្រោយពេលត្រូវវាយដំដោយភ្នាក់ងារចាប់ខ្លួន
ក្អក និងគ្រុន
ដឹងថាខ្លួនចុះខ្សោយ
ដឹងថាក្តៅស្ទេញក្នុងក្បាល
ដឹងថាក្តៅស្ទេញក្នុងខ្លួនប្រាណ
ជម្ងឺស្វាយប្រមេះ
ជម្ងឺបេះដូង និងធ្លាក់ឈាមតាមយោនី

ឫសជ្ជិងបាត

មានប្រវត្តិក្អកធ្លាក់ឈាម

របួសនៅលើពោះបណ្តាលមកពីជម្ងឺគ្រុនចាញ់ របួសដោយមីន

ឈឺចាប់មួយចំហៀងខ្លួនខាងឆ្វេង ២-៣ ដងក្នុងមួយខែ

ឈឺចាប់ក្នុងទ្រូង និងស្មាស្តាំ

ឈឺចាប់ក្នុងទ្រូង ដោយត្រូវគេវាយដំក្នុងពេលចាប់ចង ស្រែង និងឈឺចាប់ក្នុងពោះ

ជម្ងឺសើស្បែក

ជួនកាលដឹងឈឺពេលដកដង្ហើម

ឈឺក្រពះ

## កំណត់សំគាល់លើករណីទី ៥
## អ្នកជាប់ឃុំមានរបួស

នៅពេលដំណើរការធ្វើសម្ភាសន៍នៅពន្ធនាគារខេត្តព្រៃវែង យើងបានឃើញគេនាំអ្នកជាប់ឃុំម្នាក់ទៅកាន់ពន្ធនាគារ ដឹកនាំដោយទាហានម្នាក់ ឬប៉ូលីសម្នាក់ក្នុងឯកសណ្ឋានយោធា ។ អ្នកជាប់ឃុំនោះមានរបួស ហើយបន្ទាប់ពីបានពិនិត្យដោយវេជ្ជបណ្ឌិត ជ. អុត្តិរម៉ាន់ និងជំនួយការរបស់លោកមកពី ARC យើងបានស្នើថា នៅម៉ោង ១.១៥ នាទីរសៀលនៃថ្ងៃនោះ ចាំបាច់ត្រូវតែយកជននោះទៅឲ្យសំរាកពេទ្យ ។ ជននោះត្រូវរបួសដោយគ្រាប់កាំភ្លើងដែលគេបាញ់ពីទីយ៉ាងជិតត្រូវចំម្ភុកជើងខាងស្តាំ ។ តាមជននោះ យើងបានដឹងថា គេបានចាប់ខ្លួនជននោះប្រាំមួយថ្ងៃមកហើយ ហើយបានចោទប្រកាន់ជននោះ ពីបទប្រើអាវុធខុសច្បាប់ ។ តាមជននោះឲ្យដឹង គឺគេស្រវឹង ហើយបានបាញ់កាំភ្លើង ១៧ គ្រាប់ចេញពីកាំភ្លើងរបស់ខ្លួនគេទៅលើអាកាសមុននឹងនគរបាលបានមកដល់ ។ នគរបាលបានឡោមព័ន្ធផ្ទះគេ ក្នុងពេលគេកំពុងងូតទឹក ។ នគរបាលបានស្រែកប្រាប់ឲ្យគេលើកដៃឡើងលើ ហើយឱនចុះទៅក្រោម ។ ក្នុងពេលដែលគេកំពុងធ្វើយ៉ាងនេះ គេក៏ត្រូវនគរបាលបាញ់ត្រង់កែងជើង នគរបាលបានបាញ់ទៅ លើជននេះពីក្រោយ និងពីលើបណ្តាលឲ្យមានរបួសយ៉ាងនេះ ។ គេមិនបានលាងសំអាតមុខរបួសនោះឲ្យបានត្រឹមត្រូវទេ ហើយបើតាមដែលយើងអាចដឹងច្បាស់ គឺមុននេះពុំមានក្បួនពេទ្យទេ ។ គឺជាយោបល់របស់វេជ្ជបណ្ឌិត អុត្តិរម៉ាន់ ដែលយល់ថាជននោះ ចាំបាច់ត្រូវការព្យាបាលពីពេទ្យជាបន្ទាន់ ។ សំណូមពរមួយបានលើកឡើងចំពោះនា យកពន្ធនាគារដើម្បីធ្វើការរៀបចំផ្ទេរអ្នកជម្ងឺទៅកាន់មន្ទីរពេទ្យព្រៃវែង ។ នាយកពន្ធនាគារបាននិយាយថា គាត់ត្រូវការសេចក្តីអនុញ្ញាតពីតុលាការព្រៃវែង ។ រាជអាជ្ញាមូលដ្ឋានត្រូវបានគេទាក់ទង ហើយបានចេញសេចក្តីបង្គាប់ឲ្យផ្ទេរដែលត្រូវប្រគល់ទៅពន្ធ នាគារនៅម៉ោងប្រហែល ២.៤៥ រសៀល ។ អ្នកទោសនោះក៏ត្រូវបានដោះលែងឲ្យទៅ មន្ទីរពេទ្យភ្លាមក្រោយពីនោះ ។

ការិយាល័យមូលដ្ឋានរបស់ ADHOC ដែលជាអង្គការក្រៅរដ្ឋាភិបាលខាងសិទ្ធិមនុស្សក៏ត្រូវគេជូនដំណឹងអំពីសភាពការណ៍នេះដែរ ហើយត្រូវបានគេសួរថាតើការិយាល័យនេះអាចធានាច្បាស់ថាជនជាប់ឃុំនោះបានទទួលការព្យាបាលនៅក្នុងមន្ទីរពេទ្យតាមដែលចាំបាច់មែន ឬមិនមែន ហើយនិងត្រូវការិយាល័យនេះទៅទាក់ទងនឹងគ្រួសារគេផងទៀត ។ មន្ត្រីអង្គការ ADHOC ពីរនាក់បានចុះទៅមើលអ្នកទោសនៅពន្ធនាគារព្រៃវែងមុនពេលគេបញ្ជូនជននោះទៅមន្ទីរពេទ្យ ។

ក្រោយមក ADHOC បានរាយការណ៍ថា នៅឯមន្ទីរពេទ្យជននោះបានទទួលថ្នាំគ្រាប់ខ្លះ ពីគ្រួសាររបស់គេ ។ ប្រពន្ធ និងម្តាយរបស់ជនជាប់ឃុំនោះបាននៅកំដរនៅពេលនេះ ហើយគេកំពុងតែគិតគូររកទៅទិញថ្នាំសង្កូវ ។ ប៉ុន្តែ ពុំមានឃើញការព្យាបាលតាមកាំរស្មី X ឬការព្យាបាលណាផ្សេងៗទៀតពីមន្ទីរពេទ្យទេ ។ បុគ្គលិកមន្ទីរពេទ្យបានទារយក ៥.០០០ រៀលដើម្បីទិញសាំងមកចាក់បញ្ឆេះម៉ាស៊ីនភ្លើង ដើម្បីចរន្តបំពេញកិច្ចការព្យាបាលតាមកាំរស្មី X ។ បុគ្គលិកនៅមន្ទីរពេទ្យក៏បានឲ្យមន្ត្រី ADHOC ដឹងថា ជើងរបស់ជននោះនឹងត្រូវកាត់ចោល ។ តមកទៀតជននោះត្រូវគេបញ្ជូនមកមន្ទីរពេទ្យកាល់ម៉ែតនៅភ្នំពេញ ។ នៅព្រៃវែងគេមិនបានធ្វើការព្យាបាលជននេះទេ លើកលែងតែការឲ្យថ្នាំផ្សះខ្លះៗ ដោយគ្រួសាររបស់គេ ។ មុខរបួសនៅតែមិនទាន់បានជុំសលាងសំអាត ឬរុំរបួសដដែល ។

អ្នកទោសនោះ តមក ក៏បានគេចខ្លួនចេញពីមន្ទីរពេទ្យកាល់ម៉ែត ពីព្រោះគ្មានឆ្មាំណាមួយត្រូវគេចាត់ឲ្យតាមឃ្លាំមើលខ្លួនគេ ។

## ការឈប់សំរាក និងការធ្វើការ

៦៦. ដោយអ្នកទោសជាច្រើនត្រូវដាក់បង្ខាំងចាក់សោជាប់ក្នុងបន្ទប់តូច អស់ពេលច្រើនម៉ោងក្នុងមួយថ្ងៃៗ គឺមានឱកាសតិចណាស់សំរាប់ការសំរាកលំហែនៅខាងក្រៅ ។ ទោះបី បើមានការអនុញ្ញាតឲ្យគេចេញក្រៅបន្ទប់តូចរបស់គេក៏ដោយ ក៏គ្មានសម្ភារៈ និង/ឬ ទីកន្លែងសំរាប់សំរាកលំហែដែរ ។ ពន្ធនាគារជាច្រើនមានធ្លាសំរាប់កីឡាបាល់ទះ ប៉ុន្តែធ្លាទាំងនេះ ហាក់បីដូចជាសំរាប់តែឆ្មាំប៉ុណ្ណោះ ។ ពន្ធនាគារនៅព្រៃវែង សៀមរាប និងបាត់ដំបងមានរោងជាងធ្វើកិច្ចការជាងឈើ ។ ពន្ធនាគារសៀមរាបមាន ម៉ាស៊ីនដេរមួយសំរាប់នារី ។ ប៉ុន្តែ ជាទូទៅ គឺគេឃើញថាស្ទើរតែគ្មានឱកាសសំរាប់ឈប់លំហែ ឬសំរាប់ធ្វើការទេ ។ ទោះបីចំនួនសាមសិបប្រាំ (៤១%) បានរាយការណ៍ថា គេអាចលេងកីឡាបានក៏ដោយ ក៏គ្មានកម្មវិធីរៀបចំសំរាប់លំហែកំសាន្តដែរ ។ ពន្ធនាគារជាច្រើនមានធ្វើការហាត់ប្រាណរយៈខ្លីៗ ។ "កីឡា" ជាធម្មតាត្រូវកំណត់នៅត្រឹមតែ ការទាត់សី ឬលេងបាល់ទះខ្លះ តែប៉ុណ្ណោះ ។ ពន្ធនាគារប្រាំមួយលើដប់បីដែលគេបានត្រួតពិនិត្យហើយ មិនអនុញ្ញាតឲ្យអ្នកទោសលេងកីឡាសោះឡើយនោះ គឺពន្ធនាគារបាត់ដំបង កំពង់ចាម PJ ស្វាយរៀង T3 និងតាខ្មៅ ។ ពន្ធនាគារពីរទៀតគឺ ព្រៃវែង និងពោធិសាត់ បានអនុញ្ញាតឲ្យអ្នកទោសតែមួយចំនួនប៉ុណ្ណោះលេងកីឡា ។ ផ្ទុយទៅវិញគេបំពេញ "ការងារ" របស់ពន្ធនាគារដូចជា ដាំស្ល កិច្ចការថែទាំបោសសំអាត ដើររកទឹក ។ល។ ភារកិច្ចទាំងនេះច្រើនតែជាការបន្ធូរបរិយាកាស ចំពោះអ្វីដែលជាការស្មុគ្រស្មាញនាំឲ្យធុញទ្រាន់ ។

## សាសនា

៦៧. ការគោរពប្រណិបត្តិសាសនាជាទូទៅ មិនមានកំហិតព្រំដែនទេនៅក្នុងពន្ធនាគារកម្ពុជានោះ ទោះបីជាភាគច្រើនគ្មានកន្លែងសំរាប់ការគោរពបូជាចំពោះសាសនាក៏ដោយ ។ លើកលែងតែខេត្តបាត់ដំបង ត្រង់ករណីដែលខេត្តនេះហាក់ដូចជាអនុម័តយកវិធីដោះស្រាយដោយបង្ខិតបង្ខំចំពោះការគោរពសាសនា ។ នៅក្នុងបន្ទប់តូចៗ នៅខេត្តបាត់ដំបងមានអាសនៈតូចៗខាងពុទ្ធសាសនា នៅពីមុខអាសនៈនេះអ្នកទោសទាំងអស់ត្រូវគោរពបូជាទាំងចិត្តទាំងស្មារតីឲ្យបានល្អ ។

## សេចក្តីសន្និដ្ឋាន

៦៨. ស្ថានភាពយ៉ាប់យ៉ឺនដែលស្ថិតនៅមានក្នុងពន្ធនាគារកម្ពុជា គឺច្រើនតែជារឿងខ្វះធនធាន ផែនការមិនគ្រប់គ្រាន់ និងគ្មានបើកការហ្វឹកហ្វឺនបណ្តុះបណ្តាលបុគ្គលិកទេ ។ បើសិនជាស្ថានភាពនេះមិនបានធូរស្រាលទេ គេប្រាកដជាអាចរំពឹងយ៉ាងសមស្របថា ចំនួនអ្នកទោសនៅក្នុងពន្ធនាគារនៅតែបន្តមានជម្ងឺឈឺចាប់ ដោយសុខភាពធ្លាក់ចុះទ្រុឌទ្រោមយ៉ាងខ្លាំង ។ អ្នកទោសជាច្រើនបានស្លាប់ក្នុងកាលដ៏មិនគួរស្លាប់ ។ ប៉ុន្តែ មានពន្ធនាគារមួយចំនួនតូចដែលការគ្រប់គ្រងមានការយល់ដឹងពីបច្ច័យទាក់ទងផ្ទៃក្នុងរវាងស្ថានភាពរូបកាយ ស្ថានភាពអនាម័យ សន្តិសុខធានាខាងសុខភាព និងទិដ្ឋភាពផ្សេងៗទៀតនៃការគ្រប់គ្រងពន្ធនាគារ ។ ឧទាហរណ៍ជាគំរូនៃខេត្តសៀមរាប ដូចមានចែងក្នុងជំពូក៩ គឺជាមតិណែនាំក្នុងវិស័យនេះ ។

## ជំពូក ៦

# ការគ្រប់គ្រងពន្ធនាគារ

## សេចក្ដីផ្ដើម

៦៩. មានលក្ខណៈពិសេសៗគួរឲ្យកត់សំគាល់បីយ៉ាងអំពីពន្ធនាគារកម្ពុជា ។ លក្ខណៈពិសេសទាំងនេះ គឺជាកិរិតទាបតាមលំដាប់នៃអំពើហិង្សាលើអ្នកទោស របបសន្តិសុខធូរស្រាលក្នុងបញ្ញត្តិច្បាប់ភាគច្រើន និងភាពងាយស្រួលដែលត្រួតដណ្ដប់លើអាកប្បកិរិយារបស់អ្នកទោសក្នុងពន្ធនាគារ ។



បន្ទប់តូចជាគុកងងឹត - ពន្ធនាគារស្វាយរៀង

## បញ្ញត្តិច្បាប់ពន្ធនាគារ

៧០. ការចែងពីបញ្ញត្តិច្បាប់ជាលាយលក្ខណ៍អក្សរលើគ្រប់វិស័យ និងដែលអាចទទួលយកបានចំពោះអ្នកទោសក្នុងពន្ធនាគារ គឺជាការចាំបាច់ដល់ការគោរពសិទ្ធិមនុស្ស ។ តែគួរឲ្យស្ដាយក្នុងខណៈដែលអ្នកទោសភាគច្រើនបានជ្រួតជ្រាបពីបញ្ញត្តិទាំងនេះ នៅក្នុងពន្ធនាគារកម្ពុជាហើយនោះ វាបែរជាបញ្ញត្តិពន្ធនាគារខ្លួនឯងទៅជាមិនត្រឹមត្រូវភាគច្រើនទៅវិញ ។

៧១. អ្នកទោសចាត់ជាសំណាកចំនួនចិតសិបប្រាំ (៨៨%) បានរាយការណ៍ថា គេបានដឹងពីបញ្ញត្តិច្បាប់ទាំងនេះជាធម្មតា ដោយការអប់រំណែនាំអំពីឆ្មាំពន្ធនាគារ ឬអ្នកទោសផ្សេងៗ ឬពីព្រោះតែគេត្រូវចាត់តាំងអោយនៅឈរតែក្នុងឋានៈមួយដែលគេស្គាល់ច្រើនដើម្បីឲ្យគេ

បានធ្វើការសិក្សាស្វែងយល់ ។ បញ្ញត្តិទាំងនេះ ដោយខ្លួនឯងត្រូវផ្អែកលើបញ្ញត្តិច្បាប់មួយ ចង្កោមផ្តើមបង្ហាញ ក្នុងឆ្នាំ ១៩៧៩-៨០ និងមានបញ្ញត្តិដប់ពីរយ៉ាងពីពន្ធនាគារស្វាយរៀង ដែលមានក្នុងឧបសម្ព័ន្ធ៦ ។ បញ្ញត្តិទាំងនោះមានន័យទូលំទូលាយពេក ហើយពុំមានសំណូមពរណាមួយទាមទារឲ្យពិនិត្យពិចារណាពីអំពើល្មើស ឬបណ្តឹងណាមួយឡើយ ។ លក្ខណៈពិសេសតែម្យ៉ាងរបស់បញ្ញត្តិដែលគួរទទួលយកនេះ គឺថាវាងាយយល់ និងងាយចាំ ។ គួរឲ្យយកចិត្តទុកដាក់ពិសេស គឺបញ្ញត្តិទី២ ដែលចែងថា អ្នកទោស"ត្រូវតែថ្លែងបញ្ជាក់ឲ្យបានច្បាស់ពីអ្វី (អំពើល្មើសច្បាប់) ដែលខ្លួនបានប្រព្រឹត្ត និងថ្កោលទោសក្នុងរឿងល្បិច អត្តចរិតនៃសេចក្តីលំអៀង និងមនុស្សដទៃទៀតដែលពាក់ព័ន្ធ ដែលខ្លួនអាចស្គាល់អាចដឹង" ។ ជាការល្អ នាយកដ្ឋានពន្ធនាគារ កំពុងស្នើបង្កើតបញ្ញត្តិច្បាប់មួយចង្កោមថ្មីទៀត ហើយបានទាក់ទងជាមួយការិយាល័យកម្ពុជាដើម្បីរកជំនួយឧបត្ថម្ភ ។ បញ្ញត្តិទាំងនេះ ឥឡូវកំពុងដំណើរការធ្វើពង្រាង ។

៧០. រដ្ឋធម្មនុញ្ញកម្ពុជាមានបញ្ញត្តិទូទៅមួយ ( មាត្រា៣១ ) ចែងពីការគោរពសិទ្ធិមនុស្ស និងឧបករណ៍សហប្រជាជាតិ[11] ។ វាក៏មានចែងពីការធានាជាក់ច្បាស់ថែមទៀតអំពីបូរណភាពខាងរូបកាយរបស់អ្នកទោស និងអ្នកជាប់ឃុំ[12] ។ ច្បាប់ព្រហ្មទណ្ឌដែលមានស្រាប់ ផ្តើម

---

11. មាត្រា ៣១ ព្រះរាជាណាចក្រកម្ពុជាត្រូវទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចដែលមានចែងក្នុងធម្មនុញ្ញ អ.ស.ប សេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញា និងអនុសញ្ញាទាក់ទងនិងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ ។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវស្មើភាពគ្នាចំពោះមុខច្បាប់ មានសិទ្ធិដូចៗគ្នា មានសេរីភាពដូចគ្នា និងបំពេញកាតព្វកិច្ចដូចៗគ្នា ដោយមិនគិតពីជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ស្ថានភាពសង្គម សុខុមាលភាព ឬស្ថានភាពផ្សេងទៀត ។ ការប្រើសិទ្ធិ និងសេរីភាពផ្ទាល់ខ្លួនដោយបុគ្គលណាមួយមិនត្រូវឲ្យប៉ះពាល់ដល់សិទ្ធិ និងសេរីភាពរបស់អ្នកដទៃឡើយ ។ ការប្រើសិទ្ធិ និងសេរីភាពបែបនេះ ត្រូវតែឲ្យស្របតាមច្បាប់ ។

12. មាត្រា៣៨ : ច្បាប់ធានាថា នឹងពុំមានការរំលោភលើរូបកាយរបស់បុគ្គលណាមួយឡើយ ។ ច្បាប់និងការពារអាយុជីវិត កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។ ការយកមកកាត់ទោស ការចាប់ចង ឬការឃុំឃាំងមនុស្សណាម្នាក់ មិនត្រូវឲ្យមាន លើកលែងតែមានការសមស្របតាមច្បាប់ ។ ការបង្ខិតបង្ខំ ការធ្វើទុក្ខទោសលើរូបកាយ ឬការប្រព្រឹត្តខុសឆ្គងបែបណាមួយដែលដាក់ទណ្ឌកម្មបន្ថែមលើជនជាប់ឃុំ ឬលើអ្នកទោសត្រូវតែហាមឃាត់ ។ ជនណាដែលប្រព្រឹត្តចូលដៃ ឬឃុបឃិតក្នុងអំពើបែបនេះត្រូវគេទទួលទណ្ឌកម្មតាមច្បាប់ ។ ការឆ្លើយ សារភាពបានមកពីការប្រើកម្លាំងធ្វើបាបលើរូបកាយ ឬស្មារតីមិនត្រូវទទួលយកបានជាភស្តុតាងបញ្ជាក់ទោសកំហុសទេ ។ ករណីណាដែលមានជាប់មន្ទិលសង្ស័យត្រូវតែដោះស្រាយអនុគ្រោះដល់ជនជាប់ចោទ ។ ជនជាប់ចោទត្រូវចាត់ទុកថាគ្មានទោសរហូតដល់តុលាការសំរេចជាចុងក្រោយលើករណីនេះ ។ ប្រជាពលរដ្ឋម្នាក់ៗត្រូវតែមានសិទ្ធិទទួលការពារក្តីតាមការពឹងប្រាស្រ័យតាមរយៈតុលាការ ។

បញ្ចូលដោយអ៊ុនតាក់ ក៏មានបញ្ញត្តិមួយចំនួនដ៏សំខាន់ដល់កិច្ចការពារអ្នកទោសដែរ[13] ។ ជាសំខាន់ ច្បាប់នេះដែលនឹងមានប្រសិទ្ធភាពរហូតដល់ពេលត្រូវបដិសេធចោលដោយច្បាប់ព្រហ្មទណ្ឌថ្មីដែលត្រូវដាក់ចេញនៅក្នុងឆ្នាំក្រោយ មានបញ្ញត្តិមួយដែលជាមូលដ្ឋានគ្រឹះដល់សុខុភាព និងសិទ្ធិមនុស្សរបស់អ្នកទោស និងដែលតំរែតំរង់ការចាប់ចង និងការឃុំឃាំងនោះបានកើតមានឡើងស្របតាមបញ្ញត្តិអប្បបរមាជាបទដ្ឋាន សំរាប់ប្រព្រឹត្តចំពោះអ្នកទោស ( SMRTP ) និងគោលការណ៍ជាមូលដ្ឋានសំរាប់ប្រព្រឹត្តចំពោះអ្នកទោស ( BPTP )[14] ។

## សន្តិសុខ

៧៣. សន្តិសុខក្នុងពន្ធនាគារលេចចេញឲ្យឃើញថាខ្សោយជាលំដាប់ ហើយការរត់គេចចេញពីពន្ធនាគារក៏មានជាញឹកញាប់ ។ នេះគឺបណ្តាលមកពីស្ថានភាពយ៉ាប់យ៉ឺនរបស់ពន្ធនាគារនោះឯង ក៏ដូចជារបស់សន្តិសុខទន់ខ្សោយយ៉ាងច្រើនក្នុងពន្ធនាគារជាច្រើន ។ ឧទាហរណ៍នៃការដាក់ខ្នោះឃ្នាងដែលគេមិនបានបង្ហាញគឺមានស្ទើរតែក្នុងគ្រប់ករណីដែលទាក់ទងដល់ការចាំបាច់ត្រូវបង្ខាំងអ្នកទោសឲ្យជាប់មានការធានាជាជាងការដាក់ទណ្ឌកម្ម ។ នៅគ្រប់ពន្ធនាគារទាំងអស់លើកលែងតែពីរចេញ ( បាត់ដំបង និងសៀមរាប ) ទ្វារធំសំរាប់ចូលពន្ធនាគារត្រូវទុកចោលចំហ យ៉ាងហោចណាស់ក៏ក្នុងពេលថ្ងៃ ហើយនៅគ្រប់ទីពន្ធនាគារទាំងអស់គ្មានឃើញការយកចិត្តទុកដាក់ត្រួតឃ្លាំមើលបរិមាត្រពន្ធនាគារឲ្យបានជិតដល់ទេ ។

### កំណត់សំគាល់លើករណីទី ៦
### ការរត់គេចពីពន្ធនាគារនៅកំពង់ចាម

នាថ្ងៃទី ២០ មេសា ១៩៩៤ អ្នកទោសមួយចំនួនធំ ( គ្មានការបញ្ជាក់ថា ប៉ុន្មានៗទេ ប៉ុន្តែ បើស្មានគឺប្រជាម្ភៃប្រាំ ) បានរត់ចេញតាមច្រកដំបូលដែលពុកពីពន្ធនាគារកំពង់ចាម ។

---

13. បញ្ញត្តិទាក់ទងនឹងច្បាប់តុលាការ និងច្បាប់ព្រហ្មទណ្ឌ និងនីតិក្រមដែលចូលជាធរមានហើយនៅកម្ពុជាក្នុងរយៈអន្តរកាល ថ្ងៃទី ១០ ធ្នូ ១៩៩២ : មើលជាពិសេស មាត្រា ៩ ១២ ដល់ ២២ ។

14. មាត្រា១២ (1) គ្មានជនជាប់ឃុំណាត្រូវដាក់ឲ្យទទួលការធ្វើទុក្ខទោស ឬការដាក់ទណ្ឌកម្ម ឃោរឃៅ ចោកទាប ឬត្រូវវាយដំ ឬធ្វើទារុណកម្មឡើយ ។ ជនជាប់ឃុំម្នាក់ត្រូវមានសិទ្ធិទទួលការថែទាំសុខភាពសមស្រប ។ មិនត្រូវដាក់ខ្នោះជើងដល់អ្នកទោស ឬមិនត្រូវទុកគេចោលឯកោទេ ទោះនៅក្នុងការឃុំឃាំងមុនការកាត់ទោស ឬកាត់ទោសរួចហើយក៏ដោយ ។ ទោះក្នុងករណីណាក៏ដោយមិនត្រូវគំរាមបំភ័យគ្រួសាររបស់ជនជាប់ឃុំ ឬអ្នកទោសដោយចាត់ទុកថាជាលទ្ធផលនៃអាកប្បកិរិយារបស់អ្នកទោសទេ ។

(2) ការចាប់ចង ឬការឃុំឃាំងត្រូវធ្វើឲ្យស្របទៅតាមបញ្ញត្តិអប្បបរមាជាបទដ្ឋានសំរាប់ប្រព្រឹត្តចំពោះជនជាប់ឃុំ ក៏ដូចជាស្របតាមគោលការណ៍ជាមូលដ្ឋានសំរាប់ប្រព្រឹត្តចំពោះអ្នកទោស អនុម័តដោយ អ.ស.ប. ។

ជាលទ្ធផល នាយកពន្ធនាគារត្រូវផ្លាស់ចេញ ហើយទាំងគាត់ទាំងប្រធានគាត់ ២ នាក់ ត្រូវបន្ថយឋានន្តរសក្តិយ៉ាងធ្ងន់ ។ តមក បុគ្គលិកម្ភៃប្រាំពីរនាក់នៃពន្ធនាគារនោះបានធ្វើញត្តិស្នើឡើងដើម្បីគាំទ្រចៅហ្វាយរបស់ខ្លួនដែលត្រូវទម្លាក់បុណ្យ ដោយទាមទារយ៉ាងទទូចថា គ្មានការឃុបឃិតរួមគំនិតគ្នាជាមួយអ្នកទោសដែលលួចរត់នោះទេ ។ ក្រោយមកទៀត អ្នកទោសភាគច្រើនត្រូវបានឃុំជាប់ក្នុងបន្ទប់តូចមួយច្រករបស់គេ ដោយមានការហាត់ប្រាណនៅខាងក្រៅបន្តិចបន្តួច ឬគ្មានសោះ ហើយអ្នកទោសយ៉ាងច្រើន (លើសពីហាសិបនាក់) ត្រូវគេដាក់ផ្ទុកចូលជាមួយគ្នាក្នុងបន្ទប់ឃុំឃាំងដ៏តូចសែនចង្អៀតហើយមានការយាមកាមយ៉ាងតឹងរ៉ឹង ។

## អំពើហិង្សានៅលើអ្នកជាប់គុក

៧៤. ការគ្រប់គ្រងពន្ធនាគារបានល្អ ច្រើនតែផ្អែកលើសមត្ថភាពអាចបន្ធូរបន្ថយលក្ខណៈបំបាត់សេរីភាពរហូតដល់កំរិតមួយដែលយ៉ាងហោចណាស់ ក៏អ្នកជាប់គុកមិនឈ្លោះវាយតប់គ្នាដែរ ។ ក្នុងរឿងនេះពន្ធនាគារកម្ពុជាបានរួចផុតពីអំពើហិង្សាបែបនេះបានគួរឲ្យកត់សំគាល់ ។ លើកលែងតែពន្ធនាគារបាត់ដំបងចេញដែលប្រព័ន្ធ "អ្នកត្រួតត្រា (ឬកាប៉ូ) មានកំហុសយ៉ាងខ្លាំង ហើយពន្ធនាគារ ៗ ដែលមានល័ក្ខខ័ណ្ឌតឹងរឹងជាទីបំផុតរហូតដល់បណ្តាលឲ្យកើតមានភាពតានតឹងជាប្រចាំក្នុងចំណោមអ្នកជាប់គុកជាមួយគ្នា (មើលជំពូក៤) ។ នៅឯពន្ធនាគារបាត់ដំបង ការគ្រប់គ្រងវិន័យត្រូវស្ថិតក្នុងដៃរបស់ "អ្នកទោសដែលគេប្រគល់ឲ្យត្រួតត្រា" ដែលបានកៀបសង្កត់អ្នកទោសជាប់គុកដូចគ្នា ដោយវាយដំយ៉ាងសាហាវព្រៃផ្សៃជាទីបំផុត ។ មានការវាយដំខ្លះ ត្រូវគេធ្វើចំពោះការរំលោភបន្តិចបន្តួចដូចជាមិនសំរុះសំរួលត្រឹមត្រូវក្នុងពេលធ្វើពិធីសក្ការៈប្រចាំថ្ងៃ ។ ទោះបីមានការណែនាំពីនាយកពន្ធនាគារ ក្នុងពេលទស្សនកិច្ចរបស់មជ្ឈមណ្ឌល អ.ស.ប. ដើម្បីសិទ្ធិមនុស្សដើម្បីបញ្ឈប់ការអនុវត្តន៍បែបនេះយ៉ាងណាក៏ដោយ ក៏នៅតែមានរបាយការណ៍លើកឡើងថា អំពើនេះនៅតែមានបន្ត ។ អ្នកឆ្លើយតបហាសិបនាក់ (៥៩%) បាននិយាយថា គ្មានអំពើហិង្សាប្រព្រឹត្តដោយអ្នកទោសទៅលើអ្នកទោសដូចគ្នាតាមកំរិតណាមួយគួរឲ្យកត់សំគាល់នេះទេ ។ មានចំនួន ២៥% (9) បានរាយការណ៍ថា នេះគឺគ្រាន់តែជាការជជែកតវ៉ា ឬឈ្លោះប្រកែកគ្នាប៉ុណ្ណោះ ។ កំរិតនៃរបួសក៏ថយចុះដល់កំរិត អប្បបរមាតាមការសង្កេតឃើញ និងការរាយការណ៍ដែលថា វាជាលទ្ធផលនៃការវាយតប់គ្នានេះ ។ អាវុធក៏ដូចជាពុំសូវឃើញប្រើដែរក្នុងការវាយតប់គ្នា គឺមានតែការវាយគ្នាដោយប្រើកញ្ឆប់ដៃ ។

## វិន័យ និងការដាក់ទណ្ឌកម្ម

៧៥. ដោយគ្មានប្រសិទ្ធភាពនៃច្បាប់ ទំរង់បែបបទពន្ធនាគារ បញ្ញត្តិ និងបទបញ្ជាសមត្ថភាពក្នុងការគ្រប់គ្រងពន្ធនាគារឲ្យមានវិន័យត្រឹមត្រូវ និងដាក់ទណ្ឌកម្មអ្នកជាប់ឃុំដែល

ប្រព្រឹត្តល្មើស ឬបំពានបញ្ញត្តិច្បាប់ពេលដែលនៅក្នុងពន្ធនាគារនោះមានកំរិត ។ និយាយផ្ទុយទៅវិញមានកំហិតបន្តិចបន្តួចលើភ្នាក់ងារពន្ធនាគារក្នុងការប្រកាន់អាកប្បកិរិយារបស់ខ្លួន ។ ទោះបីមានបញ្ហាធ្ងន់ធ្ងរទាំងនេះក៏ដោយ ក៏បញ្ហាចំបងក្នុងពន្ធនាគារកម្ពុជាត្រូវប្រមូលផ្តុំលើលក្ខខណ្ឌដូចដែលមានពិភាក្សាក្នុងជំពូក ៥ ។ អ្នកជាប់គុក ដូចជាគាត់តែងការលំបាកវេទនាខ្លាំងថែមទៀតព្រោះគ្មានសម្ភារៈប្រើប្រាស់ ខ្វះស្បៀង និងត្រូវគេទុកចោលច្រើនជាងតាមការធ្វើទណ្ឌកម្មដោយចេតនា តាមផ្លូវច្បាប់ក្តី ឬតាមផ្លូវផ្សេងៗពីនេះក្តី ។ ប៉ុន្តែ នេះមិនមែននិយាយថាទិដ្ឋភាពនៃជីវភាពក្នុងពន្ធនាគារកម្ពុជាមិនមែនជារឿងមួយដែលត្រូវតែគិតគូរយកចិត្តទុកដាក់នោះទេ ។ គឺជារឿងដែលត្រូវតែគិតគូរ ហើយពិតជាទាមទារឲ្យធ្វើជាបន្ទាន់ផងទៀត ។ របាយការណ៍បានពីអ្នកឆ្លើយតបបានបញ្ជាក់ពីអំពើរំលោភមួយចំនួនដែលនាំឲ្យឈឺក្បាល ។

៧៦. ចម្លើយបតពីការត្រួតពិនិត្យទូទៅបញ្ជាក់ថាការដាក់ទណ្ឌកម្មដូចតទៅ ត្រូវគេប្រើនាពេលនេះ :

- ៤៦% ( ៣៨ ) បានរាយការណ៍ពីការប្រើវិធីធ្វើទារុណកម្ម
- ៦៥% ( ៥៣ ) បានរាយការណ៍ពីការប្រើវិធីវាយដំ
- ៥២% ( ៤២ ) បានរាយការណ៍ពីការដាក់ឃុំឯកោដាច់ពីគេ
- ២៥% ( ២០ ) បានរាយការណ៍ពីការប្រើកម្លាំងកាយច្រើនហួសហេតុ
- ៤០% ( ៣២ ) បានរាយការណ៍ពីការបង្ខាំងលើរូបកាយ ( ឧទាហរណ៍ ច្រវាក់ ខ្នោះឃ្នាង ) ។

ការបំពានតាមការពោលអាងនេះ មានការប្រែប្រួលរវាងពន្ធនាគារ និងពន្ធនាគារដូចដែលមានបញ្ជាក់ក្នុងតារាង ៦.១ ។ ការដាក់ទណ្ឌកម្មផ្សេងទៀតដែលច្រើនប្រើដែរ គឺការផ្អាកមិនឲ្យមាននរណាមកសួរសុខទុក្ខ ( រាយការណ៍ដោយអ្នកឆ្លើយតប ៤៣ នាក់ ) និងមិនសូវមានញ៉ាំកញ្ចាប់ គឺការបន្ថយរបបចំណីអាហារ ។



ច្រវាក់ខ្នោះឃ្នាងពីឈើ - កំពង់ឆ្នាំង

តារាង ៦.១ : របាយការណ៍ស្តីពីការបំពានលើរូបកាយក្នុងពន្ធនាគារនីមួយៗ

| របាយការណ៍ពីការបំពានលើរូបកាយ* | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ឈ្មោះពន្ធនាគារ | ទារុណកម្ម | | ការវាយដំ | | ដាក់ឃុំឯកោ | | ការប្រើកម្លាំងកាយហួសហេតុ | | ការបង្ខាំងលើរូបកាយ | |
| | មែន | មិនមែន | មែន | មិនមែន | មែន | មិនមែន | មែន | មិនមែន | មែន | មិនមែន |
| បាត់ដំបង | ១ | ៩ | ១០ | ០ | ០ | ១០ | ៩ | ១ | ០ | ១០ |
| កំពង់ចាម | ៤ | ១ | ៤ | ១ | ២ | ៣ | ០ | ៥ | ៤ | ១ |
| កំពង់ចាម (T5) | ១០ | ៣ | ៩ | ៤ | ១១ | ២ | ២ | ១១ | ១២ | ០ |
| កំពង់ឆ្នាំង | ៤ | ១ | ៤ | ១ | ៤ | ០ | ០ | ៤ | ៣ | ២ |
| កំពង់សោម | ១ | ២ | ១ | ២ | ០ | ៣ | ០ | ៣ | ០ | ៣ |
| PJ | ៥ | ៤ | ៩ | ០ | ៦ | ៣ | ៣ | ៦ | ២ | ៧ |
| ព្រៃវែង | ០ | ៤ | ១ | ៣ | ២ | ២ | ០ | ៤ | ០ | ៤ |
| ព្រៃស | ០ | ៦ | ០ | ៦ | ១ | ៥ | ០ | ៦ | ០ | ៦ |
| ពោធិសាត់ | ២ | ១ | ១ | ២ | ០ | ៣ | ០ | ៣ | ៣ | ០ |
| ស្វាយរៀង | ៥ | ០ | ៥ | ០ | ៥ | ០ | ៥ | ០ | ៥ | ០ |
| សៀមរាប | ០ | ៥ | ០ | ៥ | ០ | ៥ | ០ | ៥ | ២ | ៣ |
| T3 | ២ | ៦ | ៤ | ៤ | ៥ | ៣ | ០ | ៤ | ០ | ៤ |
| តាខ្មៅ | ៤ | ២ | ៥ | ១ | ៦ | ០ | ១ | ៥ | ១ | ៥ |
| សរុប | ៣៤ | ៤៤ | ៥៣ | ២៩ | ៤២ | ៣៩ | ២០ | ៦១ | ៣២ | ៤៩ |

* ចំនួនសរុបនៃមនុស្សត្រូវសម្ភាសន៍បានមាន ៨៥ ។ មួយចំនួនក្នុងប្រភេទនីមួយៗ ឥតបានឆ្លើយទេ ព្រោះគេឥតបានដឹង ។

៧៧. ការដាក់ឲ្យឈរហាលថ្ងៃ (ជួនកាលឈរជើងម្ខាង នៅដៃមានកាន់វត្ថុមួយធ្ងន់ផង) អស់រយៈពេលយូរៗ គឺជាការធ្វើទារុណកម្មដែលមានញឹកញាប់ជាងគេ ។ ការប្រើឲ្យហាត់ប្រាណច្រើនហួសហេតុមានស្ទើរតែជានិច្ចកាល គឺឲ្យលូនទៅលូនមក រត់ជើងបួន ឬកាត់ស្មៅនឹងដៃ ។ តួលេខនេះក៏បានបញ្ជាក់ពីការបន្តប្រើប្រាស់យ៉ាងច្រើននៅគ្រប់កន្លែងនូវវិធីដាក់ឃុំឯកកោដាច់ពីគេ និងដាក់ច្រវាក់ខ្នោះឃ្នាង ។ ច្រវាក់ ខ្នោះឃ្នាង ត្រូវបានក្រុម PAP ទទួលបាននៅក្នុងពន្ធនាគារបួន-គឺ កំពង់ចាម T5 កំពង់ឆ្នាំង និងពោធិសាត់ ។

៧៨. អ្នកផ្ដល់ចម្លើយសាមសិបនាក់បានបញ្ជាក់ថា ការដាក់ទណ្ឌកម្មតាមបែបទាំងនេះម្យ៉ាង ឬច្រើនយ៉ាង គឺជាការធ្វើទណ្ឌកម្មលើខ្លួនគេនេះឯង ។ ប៉ុន្តែ មានតែនៅក្នុងពន្ធនាគារមួយ (ស្វាយរៀង) ដែលដូចជាមានការបំពានលើអ្នកទោស តាមការរៀបចំតាមបែបផែនរបស់វា ។ នៅទីនោះ អ្នកទោសថ្មីៗ គ្រប់ៗគ្នាសុទ្ធតែត្រូវវាយដំ ហើយមានទម្លាប់មួយដែលគេតែងតែប្រើញឹកញាប់ គឺដាក់ឲ្យអ្នកទោស "ឈរហាលថ្ងៃជាទារុណកម្ម" ហើយច្រើនតែឲ្យកាន់ដុំឥដ្ឋផង ឬឈរជើងមួយក្នុងរយៈពេលយូរៗ ។

៧៩. ក្នុងពន្ធនាគារដទៃទៀត ដោយមិននិយាយពី T5 ការដាក់ទណ្ឌកម្មទាំងនេះត្រូវប្រើដោយចៃដន្យទៅលើអ្នកទោសដែលបានរំលោភបញ្ញត្តិច្បាប់ ជាធម្មតាច្រើនតែការឈ្លោះប្រកែកគ្នា ឬវាយតប់គ្នា ។ ច្រវាក់ ខ្នោះ ឃ្នាង ច្រើនតែត្រូវគេប្រើដើម្បីរាំងស្កាត់អ្នកទោសកុំឲ្យគេចរួចពីគុក ឬជាឧបករណ៍សំរាប់ដាក់ទណ្ឌកម្ម និងសំរាប់ធានាសន្តិសុខផង ក្រោយពេលមានការលួចរត់ចេញ ។ ប៉ុន្តែ នៅក្នុងពន្ធនាគារមួយ (T5) គេបានប្រើឧបករណ៍ទាំងនេះតាមរបៀបម្យ៉ាងកាន់តែមានប្រព័ន្ធ ឬក៏ប្រើជាមធ្យោបាយសំរាប់ត្រួតពិនិត្យអ្នកទោសជាទូទៅ ។ ការដាក់ឃុំឯកោដាច់ពីគេ ត្រូវបានគេប្រើនៅទីណាក៏មាន ហើយជាបញ្ហាមួយជាពិសេសនៅគុកតាខ្មៅ និងគុកស្វាយរៀង ដែលបន្ទប់ដាក់ឃុំដ៏តូចចង្អៀត ងងឹតឈឹង និងខ្វះខ្យល់ចេញចូលត្រូវបានគេប្រើក្នុងគោលបំណងយ៉ាងនេះ ។

## ប្រព័ន្ធដោះលែងមុនពេល

៨០. ចំណុចមួយទៀតក្នុងការត្រួតត្រាអ្នកជាប់ពន្ធនាគារកម្ពុជា គឺការប្រើ " វិធីដោះលែងមុនពេល" ។ ផ្អែកលើក្រឹត្យច្បាប់មួយចេញក្នុងរបបមុន វិធីនេះអនុញ្ញាតឲ្យមានការបន្ថយឲ្យបានជាអតិបរមា នូវចំនួនដល់ទៅពីរភាគបីនៃការជំនុំជំរះទោស[15] ។ ជាការលំបាកក្នុងការរកឲ្យបានសេចក្ដីលំអិតជាក់ស្ដែងស្ដីពី ថាតើវិធីនេះដំណើរការដូចម្ដេច ប៉ុន្តែជាក់ស្ដែងការអនុវត្តន៍ការដោះលែងមុនពេលត្រូវធ្វើតាមរយៈនាយកពន្ធនាគារ ទៅក្រសួងយុត្តិធម៌ដែលបើសិនជាក្រសួងអនុម័តបញ្ហានេះ នឹងដាក់ផ្លូវរឿងនេះទៅព្រះមហាក្សត្រដើម្បីសូមរាជានុ

---

[15] ក្រឹត្យទី ២៨ រដ្ឋកម្ពុជា

ម័ត ។ បើសិនជាមានរាជានុម័តអ្នកទោសនឹងត្រូវដោះលែងតាម "ព្រះរាជឧង្ការ" តាមរយៈលិខិតបង្គាប់មួយចេញក្នុងនាមព្រះមហាក្សត្រដោយក្រសួងយុត្តិធម៌ទៅគុលាការមូលដ្ឋាន ។ វិធីនេះត្រូវប្រើដូចគ្នាទូទាំងប្រព័ន្ធ ។ នាយកពន្ធនាគារខ្លះហាក់ដូចជាឥតបានដឹងពីអត្ថិភាពរបស់វាទេ ។ ប៉ុន្តែ នៅពន្ធនាគារ ព្រៃស កំពង់ឆ្នាំង និងសៀមរាប គេបានប្រើវិធីនេះយ៉ាងទូលំទូលាយ ។ សេចក្តីចម្លងនៃលិខិតបង្គាប់នេះមានចុះក្នុងឧសបម្ព័ន្ធ៧ ។ មាត្រា ៧១ នៃ TCP អនុញ្ញាតដល់ "ការដោះលែងអ្នកទោសដោយមានល័ក្ខខ័ណ្ឌ" តាមរយៈលិខិតបង្គាប់ពីតុលាការ ។ លិខិតបង្គាប់នេះអាចត្រូវឲ្យក្រោយពេលគេបានទទួលទោសជាប់គុកពាក់កណ្ដាលពេលហើយ ចំពោះជនណាដែលបានប្រព្រឹត្តទោសលហុ និងក្រោយពីបានទទួលទោសពីរភាគបីនៃពេលត្រូវទទួលទោស ចំពោះជនណាដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋ ។ គ្មានភស្តុតាងអ្វីបញ្ជាក់ថាវិធីនេះកំពុងត្រូវប្រើប្រាស់ទេ ។ ប៉ុន្តែ នាយកពន្ធនាគារ T5 បានធ្វើលិខិតមួយទៅក្រសួងយុត្តិធម៌ និងទៅឲ្យតុលាមូលដ្ឋានរបស់ខ្លួន ក្នុងនាមរបស់អ្នកជាប់គុកហាសិបបីនាក់នាខែមិនា ១៩៩៤ ដោយស្នើសួរពីការដោះលែងគេទាំងនេះតាមមាត្រានេះ ។ តែគួរឲ្យស្តាយសំណូមពរនេះត្រូវបដិសេធដោយតុលាការដោយសំអាងថា"ការដោះលែងមានល័ក្ខខ័ណ្ឌ" នៅក្នុង TCP មានន័យដូចនឹងពាក្យ "សន្តោសលើកលែងទោស" ហើយថាការដោះលែងបែបនេះត្រូវតែដឹកនាំធ្វើដោយលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃប៉ុណ្ណោះ ។ មានទឡ្ហីករណ៍ទប់ទល់ទៅលើពួកគេថា ការដោះលែងមានល័ក្ខខ័ណ្ឌនេះ គឺសំរាប់តែអ្នកទោសឈឺ ដោយអនុលោមសេចក្តីណែនាំមួយរបស់រដ្ឋាភិបាលនាឆ្នាំ ១៩៩៤ ។

៧៧. ការដាក់ឲ្យឈរហាលថ្ងៃ (ជួនកាលឈរជើងម្ខាង នៅដៃមានកាន់វត្ថុមួយធ្ងន់ផង) អស់រយៈពេលយូរៗ គឺជាការធ្វើទារុណកម្មដែលមានញឹកញាប់ជាងគេ ។ ការប្រើឲ្យហាត់ប្រាណច្រើនហួសហេតុមានស្ទើរតែជានិច្ចកាល គឺឲ្យលូនទៅលូនមក រត់ជើងបួន ឬកាត់ស្មៅនឹងដៃ ។ តួលេខនេះក៏បានបញ្ជាក់ពីការបន្តប្រើប្រាស់យ៉ាងច្រើននៅគ្រប់កន្លែងនូវវិធីដាក់យ៉ុងឯកកោដាច់ពីគេ និងដាក់ច្រវាក់ខ្នោះឃ្នាង ។ ច្រវ៉ាក់ ខ្នោះឃ្នាង ត្រូវបានក្រុម PAP ទទួលបាននៅក្នុងពន្ធនាគារបួន-គឺ កំពង់ចាម TS កំពង់ឆ្នាំង និងពោធិសាត់ ។

៧៨. អ្នកផ្តល់ចម្លើយសាមសិបនាក់បានបញ្ជាក់ថា ការដាក់ទណ្ឌកម្មតាមបែបទាំងនេះម្យ៉ាង ឬច្រើនយ៉ាង គឺជាការធ្វើទណ្ឌកម្មលើខ្លួនគេនេះឯង ។ ប៉ុន្តែ មានតែនៅក្នុងពន្ធនាគារមួយ (ស្វាយរៀង) ដែលដូចជាមានការបំពានលើអ្នកទោស តាមការរៀបចំតាមបែបផែនរបស់វា ។ នៅទីនោះ អ្នកទោសថ្មីៗ គ្រប់ៗគ្នាសុទ្ធតែត្រូវវាយដំ ហើយមានទម្លាប់មួយដែលគេតែងតែប្រើញឹកញាប់ គឺដាក់ឲ្យអ្នកទោស "ឈរហាលថ្ងៃជាទារុណកម្ម" ហើយច្រើនតែឲ្យកាន់ដុំឥដ្ឋផង ឬឈរជើងមួយក្នុងរយៈពេលយូរៗ ។

៧៩. ក្នុងពន្ធនាគារដទៃទៀត ដោយមិននិយាយពី TS ការដាក់ទណ្ឌកម្មទាំងនេះត្រូវប្រើដោយចៃដន្យទៅលើអ្នកទោសដែលបានរំលោភបញ្ញត្តិច្បាប់ ជាធម្មតាច្រើនតែការឈ្លោះប្រកែកគ្នា ឬវាយតប់គ្នា ។ ច្រវាក់ ខ្នោះ ឃ្នាង ច្រើនតែត្រូវគេប្រើដើម្បីរាំងស្កាត់អ្នកទោសកុំឲ្យគេចរួចពីគុក ឬជាឧបករណ៍សំរាប់ដាក់ទណ្ឌកម្ម និងសំរាប់ធានាសន្តិសុខផង ក្រោយពេលមានការលួចរត់ចេញ ។ ប៉ុន្តែ នៅក្នុងពន្ធនាគារមួយ (TS) គេបានប្រើឧបករណ៍ទាំងនេះតាមរបៀបម្យ៉ាងកាន់តែមានប្រព័ន្ធ ឬក៏ប្រើជាមធ្យោបាយសំរាប់ត្រួតពិនិត្យអ្នកទោសជាទូទៅ ។ ការដាក់យ៉ុងកោដាច់ពីគេ ត្រូវបានគេប្រើនៅទីណាក៏មាន ហើយជាបញ្ហាមួយជាពិសេសនៅគុកតាខ្មៅ និងគុកស្វាយរៀង ដែលបន្ទប់ដាក់យ៉ុដ៏តូចចង្អៀត ងងឹតឈឹង និងខ្វះខ្យល់ចេញចូលត្រូវបានគេប្រើក្នុងគោលបំណងយ៉ាងនេះ ។

## ប្រព័ន្ធដោះលែងមុនពេល

៨០. ចំណុចមួយទៀតក្នុងការត្រួតត្រាអ្នកជាប់ពន្ធនាគារកម្ពុជា គឺការប្រើ " វិធីដោះលែងមុនពេល" ។ ផ្អែកលើក្រិត្យច្បាប់មួយចេញក្នុងរបបមុន វិធីនេះអនុញ្ញាតឲ្យមានការបន្ថយឲ្យបានជាអតិបរមា នូវចំនួនដល់ទៅពីរភាគបីនៃការជំនុំជំរះទោស[15] ។ ជាការលំបាកក្នុងការរកឲ្យបានសេចក្តីលំអិតជាក់ស្តែងស្តីពី ថាតើវិធីនេះដំណើរការដូចម្តេច ប៉ុន្តែជាក់ស្តែងការអនុវត្តន៍ការដោះលែងមុនពេលត្រូវធ្វើតាមរយៈនាយកពន្ធនាគារ ទៅក្រសួងយុត្តិធម៌ដែលបើសិនជាក្រសួងអនុម័តបញ្ហានេះ នឹងដាក់ឆ្លងរឿងនេះទៅព្រះមហាក្សត្រដើម្បីសូមរាជានុ

15. ក្រិត្យទី ២៨ រដ្ឋកម្ពុជា

ម័ត ។ បើសិនជាមានរាជានុម័តអ្នកទោសនឹងត្រូវដោះលែងតាម "ព្រះរាជឧង្ការ" តាមរយៈលិខិតបង្គាប់មួយចេញក្នុងនាមព្រះមហាក្សត្រដោយក្រសួងយុត្តិធម៌ទៅតុលាការមូលដ្ឋាន ។ វិធីនេះត្រូវប្រើដូចគ្នាទូទាំងប្រព័ន្ធ ។ នាយកពន្ធនាគារខ្លះហាក់ដូចជាឥតបានដឹងពីអត្ថិភាពរបស់វាទេ ។ ប៉ុន្តែ នៅពន្ធនាគារ ព្រៃស កំពង់ឆ្នាំង និងសៀមរាប គេបានប្រើវិធីនេះយ៉ាងទូលំទូលាយ ។ សេចក្ដីចម្លងនៃលិខិតបង្គាប់នេះមានចុះក្នុងឧសបម្ព័ន្ធ៧ ។ មាត្រា ៧១ នៃ TCP អនុញ្ញាតដល់ "ការដោះលែងអ្នកទោសដោយមានល័ក្ខខ័ណ្ឌ" តាមរយៈលិខិតបង្គាប់ពីតុលាការ ។ លិខិតបង្គាប់នេះអាចត្រូវឲ្យក្រោយពេលគេបានទទួលទោសជាប់គុកពាក់កណ្ដាលពេលហើយ ចំពោះជនណាដែលបានប្រព្រឹត្តទោសលហុ និងក្រោយពីបានទទួលទោសពីរភាគបីនៃពេលត្រូវទទួលទោស ចំពោះជនណាដែលបានប្រព្រឹត្តអំពើឧក្រិដ្ឋ ។ គ្មានភស្តុតាងអ្វីបញ្ជាក់ថាវិធីនេះកំពុងត្រូវប្រើប្រាស់ទេ ។ ប៉ុន្តែ នាយកពន្ធនាគារ T5 បានធ្វើលិខិតមួយទៅក្រសួងយុត្តិធម៌ និងទៅឲ្យតុលាមូលដ្ឋានរបស់ខ្លួន ក្នុងនាមរបស់អ្នកជាប់គុកហាសិបបីនាក់នាខែមិនា ១៩៩៤ ដោយស្នើសួរពីការដោះលែងគេទាំងនេះតាមមាត្រានេះ ។ តែគួរឲ្យស្ដាយសំណូមពរនេះត្រូវបដិសេធដោយតុលាការដោយសំអាងថា"ការដោះលែងមានល័ក្ខ-ខ័ណ្ឌ" នៅក្នុង TCP មានន័យដូចនឹងពាក្យ "សន្ដោសលើកលែងទោស" ហើយថាការដោះលែងបែបនេះត្រូវតែដឹកនាំធ្វើដោយលោករដ្ឋមន្ត្រីក្រសួងមហាផ្ទៃប៉ុណ្ណោះ ។ មានទឡ្ហីករណ៍ទប់ទល់ទៅលើពួកគេថា ការដោះលែងមានល័ក្ខខ័ណ្ឌនេះ គឺសំរាប់តែអ្នកទោសឈឺ ដោយអនុលោមសេចក្ដីណែនាំមួយរបស់រដ្ឋាភិបាលនាឆ្នាំ ១៩៨៤ ។

## ជំពូក ៧

# ការដាក់ឃុំឃាំង : ការចាំបាច់ត្រូវមានការបញ្ជាក់ច្បាស់

## សេចក្តីផ្តើម

៨១. ទោះបីជាត្រូវបិទទ្វារយ៉ាងណាក៏ដោយ ក៏ពន្ធនាគារតាមទិដ្ឋភាពភាគច្រើនចាំបាច់ត្រូវបើកចំហឲ្យបានគ្រប់គ្រាន់ដើម្បីធានាក្តាប់បាននូវការរំលោភលើសិទ្ធិមនុស្ស ។ ប្រព័ន្ធពន្ធនាគារទាំងនោះ ដែលត្រូវបិទបាំងដោយការសម្ងាត់ហាក់បីដូចជាធ្វើឲ្យគេដឹងពីការរំលោភលើសិទ្ធិមនុស្សយ៉ាងខ្លាំងបំផុត ។

៨២. ចាប់តាំងពីកិច្ចព្រមព្រៀងសន្តិភាពីទីក្រុងប៉ារីសឆ្នាំ ១៩៩១ មកអាជ្ញាធរពន្ធនាគារកម្ពុជាជាទូទៅបានបើកទ្វារចំហដល់អ្នកសង្កេតការណ៍អន្តរជាតិពីសហប្រជាជាតិ និងពីអង្គការក្រៅរដ្ឋាភិបាលខ្លះ ។ ប៉ុន្តែ ការចុះទៅពិនិត្យមើលពន្ធនាគារ ជាពិសេសដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក ហើយក្នុងករណីខ្លះ ការិយាល័យកម្ពុជាខ្លួនឯងជួនកាលត្រូវគេបដិសេធមិនឲ្យចូលទៅមើលទេ ។ មានការខ្វះគោលនយោបាយច្បាស់លាស់ក្នុងវិស័យនេះ ដែលចាំបាច់ត្រូវតែលើកមកបញ្ជាក់ជាការពិតហើយថាកម្ពុជាមុខជាមិនអាចរកទុនសំរាប់ស្ថាប័នច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន ឬកែទំរង់វាឲ្យបានសមស្របបានទេបើសិនជាវានៅតែមិនបើកចំហឲ្យបានសមហេតុសមផលដល់ពិភពលោកទេនោះ ។ នេះមានន័យជាសំខាន់ដល់ការចូលរួមពីសំណាក់ក្រុមសិទ្ធិមនុស្សក្នុងស្រុក ក៏ដូចជាក្រុមអន្តរជាតិដែរ ។

៨៣. ចំណុចត្រូវយកចិត្តទុកដាក់ជាពិសេសដែរ គឺចំនួននៃករណីទាំងឡាយដែលអ្នកទោសត្រូវដាក់ឃុំឯកោដាច់ពីគេពីឯង ។ ពោលគឺ ដោយគ្មានទំនាក់ទំនងជាមួយអ្នកណាបាន ឬក្នុងករណីនៃជនបរទេស ដោយពុំមានអ្វីជាការបញ្ជាក់ឲ្យស្ថានទូតរបស់គេបានដឹងទេ ។ នេះក៏ជាបញ្ហាមួយធ្ងន់ធ្ងរដែរ ចំពោះការធ្វើមិនដឹងមិនឮយ៉ាងនេះ ហើយក៏ជាប្រព័ន្ធទាក់ទងអាក្រក់ដូចជាការបំពានមួយមានការគ្រោងទុកដែរ ។ គឺជាស្ថានភាពមួយដែលចាំបាច់ត្រូវតែកែលំអ ។ ទិដ្ឋភាពមួយទៀតនៃបញ្ហានេះគឺសិទ្ធិ ដែលអ្នកទោសខ្លួនឯងអាចទាក់ទងបានពីមជ្ឈដ្ឋានខាងក្រៅតាមរយៈវិទ្យុ កាសែត ។ល។ សិទ្ធិទទួលបានប្រភពព័ត៌មានបែបនេះ គឺជាការសំខាន់ដល់ការបន្ថយគំនិតដាក់ឲ្យឯកោ និងគំនិតដែលមិនរវល់គិតដល់បទដ្ឋានសង្គមរបស់ក្រុម ដែលអ្នកទោសជាច្រើនធ្លាប់បានឆ្លងកាត់ជាធម្មតាទៅហើយ ។

**កំណាត់សំណាល់លើករណីទី ៧**

**អ្នកទោសថៃក្នុងពន្ធនាគារក្រុងព្រះសីហនុ**

ក្នុងពាក់កណ្ដាលខែមិនា ១៩៩៤ គេបានឃាត់ខ្លួនអ្នកទោសថៃចំនួនម្ភៃនាក់ក្នុងដែនទឹកកម្ពុជាពីបទនេសាទខុសច្បាប់ ។ គេពុំបានធ្វើការចោទប្រកាន់ណាមួយជាផ្លូវការទេ ។ គេត្រូវដាក់ឃុំអស់បួនថ្ងៃមក ហើយពេលដែលប្រធានថៃរបស់គេ បានចូលមកដល់ពន្ធនាគារ ។ ក្រោយមកគេបានដោះលែងអ្នកទាំងនេះចេញពីពន្ធនាគារ ។ ពួកគេប្រាំនាក់ត្រូវទុកឲ្យនៅមើលទូកដែលត្រូវគេរឹបអូសនៅកំពង់ផែក្រុងព្រះសីហនុ ឯដប់បួននាក់ ទៀតបានវិលត្រឡប់ទៅលំនៅដ្ឋានវិញ នៅឯប្រទេសថៃ ។ ពីរថ្ងៃក្រោយមកថៃប្រាំនាក់ដែលនៅសល់ ត្រូវបានគេចោទប្រកាន់ម្ដងទៀត ហើយត្រូវដាក់ឃុំនៅឯពន្ធនាគារទៀត ។ ឯការចោទប្រកាន់ក៏នៅតែគ្មានធ្វើដដែល ។ ស្ថានទូតក៏មិនបានដឹងពីរឿងឃុំឃាំងអ្នកទាំងនេះដែរ ទាល់តែក្រុម PAP បានប្រទះឃើញគេនៅពេលក្រោយមកជិតពីរសប្ដាហ៍ក្នុងពន្ធនាគារ ។

៩៤. អ្នកទោសកម្ពុជា ជាទូទៅបានទទួលការចុះសាកសួរសុខទុក្ខមួយចំនួនតូចពីមិត្តភក្តិ និងញាតិសារលោហិត ។ បើគិតជាមធ្យមចំពោះអ្នកទោសម្នាក់ៗ គេបានចុះសួរសុខទុក្ខលើសពីពីរដងក្នុងមួយខែ ។ តារាង ៧.១ បានបង្ហាញពីការបែងចែកទស្សនកិច្ចនៅពន្ធនាគារនីមួយៗ ចំពោះអ្នកទោស (៧៨នាក់) ដែលបានឆ្លើយ នឹងសំណួរទាក់ទងនឹងទស្សនកិច្ចនេះ ។ ករណីលើកលែង គឺពន្ធនាគារ T5 ដែលនៅឯកោ នៅខេត្តកំពង់ចាម ដែលសង់សំរាប់ដាក់ទណ្ឌិត ។ នៅទីនេះអ្នកទោសជាច្រើនឥតដែលបានឃើញមុខគ្រួសាររបស់គេអស់រយៈពេលយ៉ាងយូរ ។

៩៥. ការចុះសួរសុខទុក្ខនេះមានបិរវេលាជាលំដាប់លំដោយពីពន្ធនាគារមួយទៅពន្ធនាគារមួយ ។ ប៉ុន្តែ នៅស្ទើរតែគ្រប់ករណីបិរវេលានេះតិចជាងសាមសិបនាទី ហើយក្នុងករណីខ្លះ វាខ្លីៗ ពីប្រាំទៅដប់នាទី ។ គេតែងតែឆែកឆេរអ្នកទោសក្រោយពេលចុះសួរសុខទុក្ខ ទោះបីជាគេមិនឆែកអ្នកចុះទៅមើលក៏ដោយ ។ ដោយមានការលើកលែងចំពោះអ្នកទោសខ្លះដែលត្រូវគេឃាមកាមយ៉ាងតឹងរ៉ឹងចេញ គេឃើញហាក់ដូចជាពុំសូវមានការដាក់កំហិតប៉ុន្មានទៅលើអ្នកដែលអាចទៅមើលអ្នកទោស ឬទៅលើអ្នកទោសណាដែលគេអាចចុះទៅមើលទេ ។

តារាង ៧.១ : ចំនួននៃការចុះសួរសុខទុក្ខនៅពន្ធនាគារនីមួយៗ តាមការរាយការណ៍

| ពន្ធនាគារ | ចំនួននៃការចុះសួរសុខទុក្ខត្រូវអនុញ្ញាតឲ្យក្នុងមួយខែៗ | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|
| | ០ | ១ | ២ | ៣ | ៤ | ៥ | ៦ | |
| បាត់ដំបង | ០ | ០ | ០ | ១០ | ០ | ០ | ០ | ១០ |
| កំពង់ចាម | ០ | ០ | ០ | ៣ | ០ | ១ | ១ | ៥ |
| កំពង់ចាម (T5) | ៦ | ៥ | ០ | ០ | ០ | ០ | ០ | ១១ |
| កំពង់ឆ្នាំង | ០ | ៤ | ០ | ០ | ០ | ១ | ០ | ៥ |
| កំពង់សោម | ១ | ០ | ០ | ០ | ១ | ០ | ០ | ២ |
| PJ | ០ | ០ | ០ | ០ | ៩ | ០ | ០ | ៩ |
| ព្រៃវែង | ០ | ១ | ០ | ០ | ៤ | ០ | ០ | ៥ |
| ព្រៃស | ០ | ០ | ២ | ០ | ០ | ២ | ០ | ៤ |
| ពោធិ៍សាត់ | ០ | ១ | ១ | ០ | ១ | ០ | ០ | ៣ |
| ស្វាយរៀង | ០ | ៥ | ០ | ០ | ០ | ០ | ០ | ៥ |
| សៀមរាប | ០ | ០ | ០ | ៥ | ០ | ០ | ០ | ៥ |
| T3 | ០ | ៣ | ២ | ០ | ៣ | ០ | ០ | ៨ |
| តាខ្មៅ | ០ | ០ | ០ | ៦ | ០ | ០ | ០ | ៦ |
| សរុប | ៧ | ១៩ | ១១ | ១៤ | ១៨ | ៤ | ១ | ៧៨ |

៤៦. ទិដ្ឋភាពម្យ៉ាងទៀត គឺឧបនិស្ស័យនៃរដ្ឋអំណាចពន្ធនាគារក្នុងការបដិសេធការចុះសួរសុខទុក្ខដែលជាផ្នែកមួយនៃរបបវិន័យ ។ អ្នកទោសជាសំណាក ប្រហែលពាក់កណ្ដាល (៤៣) បានរាយការណ៍ថា វិធីនេះត្រូវប្រើជាវិធានការវិន័យ ។ ប្រការនេះត្រូវបែងចែកទៅតាមពន្ធនាគារទាំងអស់លើកលែងតែពន្ធនាគារកំពង់សោម ព្រៃវែង ព្រៃស និងស្វាយរៀង ។ នាយកពន្ធនាគារបានរាយការណ៍ថា គេបានប្រើវិធីផ្អាកការចុះសួរសុខទុក្ខនេះក្រោយពេលដែលមានអ្នកទោសលួចរត់គេចចេញ ឬមានការច្របូកច្របល់ចំបងៗ ។

## សិទ្ធិទទួលបានព័ត៌មាន

៤៧. សិទ្ធិស្ដាប់វិទ្យុ អានសៀវភៅ និងកាសែត មានការខុសៗគ្នាពីពន្ធនាគារមួយទៅពន្ធនាគារមួយ ។ មានចំនួនតែសែសិបប្រាំពីរ (៥៧%) ទេ ដែលមានច្បាប់អនុញ្ញាតិឲ្យប្រើ

វិទ្យុ ។ ចំនួនហុកសិបបួន (៧៥%) មានសិទ្ធិអានសៀវភៅ និងកាសែត ។ ការបែងចែកតាមពន្ធនាគារត្រូវបង្ហាញក្នុងតារាង ៧.២ ។

តារាង ៧.២ : ច្បាប់អនុញ្ញាតឲ្យមានសៀវភៅ កាសែត និងវិទ្យុក្នុងពន្ធនាគារនីមួយៗ

| ឈ្មោះពន្ធនាគារ | សៀវភៅ/កាសែត មាន | អត់ | សរុប | វិទ្យុ មាន | អត់ | សរុប |
|---|---|---|---|---|---|---|
| បាត់ដំបង | ១០ | ០ | ១០ | ១០ | ០ | ១០ |
| កំពង់ចាម | ៤ | ២ | ៦ | ៦ | ០ | ៦ |
| កំពង់ចាម (T5) | ១៣ | ០ | ១៣ | ១ | ១២ | ១៣ |
| កំពុងឆ្នាំង | ៥ | ០ | ៥ | ៥ | ០ | ៥ |
| កំពង់សោម | ០ | ៣ | ៣ | ១ | ២ | ៣ |
| PJ | ៦ | ៣ | ៩ | ៣ | ៦ | ៩ |
| ព្រៃវែង | ៤ | ២ | ៦ | ៥ | ១ | ៦ |
| ព្រៃស | ៦ | ០ | ៦ | ៥ | ១ | ៦ |
| ពោធិសាត់ | ២ | ១ | ៣ | ១ | ១ | ២ |
| ស្វាយរៀង | ៤ | ១ | ៥ | ៥ | ០ | ៥ |
| សៀមរាប | ៥ | ០ | ៥ | ៥ | ០ | ៥ |
| T5 | ៥ | ៣ | ៨ | ១ | ៧ | ៨ |
| តាខ្មៅ | ០ | ៦ | ៦ | ០ | ៦ | ៦ |
| សរុប | ៦៤ | ២១ | ៨៥ | ៤៨ | ៣៦ | ៨៤ |

៨៨. នៅពន្ធនាគារខ្លះ ប្រភេទអ្នកទោសមានការអនុគ្រោះខ្លះមានសេរីភាពជាងនេះ ហើយសិទ្ធិទទួលប្រភពពត៌មានក៏ច្រើនជាងដែរ ។ ពន្ធនាគារតាខ្មៅ និងពន្ធនាគារកំពង់សោម ហាក់ដូចជាមានកំហិតជាពិសេសក្នុងការអនុវត្តន៍របស់គេ ។ T5 បានអនុញ្ញាតឲ្យមានសៀវភៅ និងកាសែត ប៉ុន្តែ គ្មានវិទ្យុទេ លើកលែងតែមួយចំនួនតូចដែលមានបុព្វសិទ្ធិ ។

## ការចុះសួរសុខទុក្ខ

៨៩. គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិចុះសាកសួរសុខទុក្ខ ពន្ធនាគារកម្ពុជា ។ វត្តមានរបស់អង្គការនេះជាផ្នែកមួយដ៏សំខាន់ក្នុងការរក្សាការពារសិទ្ធិរបស់អ្នកទោស ។

៩០. ព្រះរាជអាជ្ញាពីតុលាការមូលដ្ឋានចុះសាកសុខទុក្ខយ៉ាងទៀងទាត់ពីរដងក្នុងមួយខែ ។ ប៉ុន្តែ ដូចដែលបកស្រាយហើយពីខាងដើម ( មើលជំពូក ៤ ) ប្រសិទ្ធភាពនៃការចុះសួរសុខទុក្ខទាំងនេះនៅមានកំរិត ។

៩១. អង្គការក្រៅរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សនៅមូលដ្ឋាន ជាសំខាន់អង្គការលីកាដូ និង ADHOC បានចុះសួរសុខទុក្ខពន្ធនាគារយ៉ាងទៀងទាត់ទាំងនៅភ្នំពេញ ទាំងនៅតាមខេត្ត ។ ប៉ុន្តែ លទ្ធភាពដើម្បីធ្វើឲ្យបានយ៉ាងនេះ គឺស្ថិតនៅក្នុងរង្វង់នៃការខ្វះគោលនយោបាយច្បាស់លាស់ពីរដ្ឋាភិបាល នៅក្នុងវិស័យនេះ ហើយនិងអាស្រ័យលើការប្រុងប្រយ័ត្នយ៉ាងខ្លាំងដែលចេះតែនៅមានបន្តនៃរដ្ឋអំណាចមូលដ្ឋានក្នុងការបដិសេធយ៉ាងសមស្រប មិនឲ្យអង្គការទាំងនេះចេញចូលបាន ។ ក្នុងចំនួនកាន់តែច្រើនឡើងៗ អង្គការដែលមានច្បាប់ការពារដូចជាអង្គការបណ្ដុះបណ្ដាលសិទ្ធិមនុស្សកម្ពុជា និងសមាគមអ្នកការពារក្ដីកម្ពុជា បានចុះទៅមើលពន្ធនាគារ ដើម្បីសម្ភាសន៍ជាមួយអតិថិជន ។ ការធ្វើយ៉ាងនេះ នឹងមានតទៅទៀត បើកាលណាធនធានសំរាប់ធ្វើយ៉ាងនេះមានការរីកចំរើនឡើង ។

## សេចក្ដីសន្និដ្ឋាន

៩២. ប្រព័ន្ធពន្ធនាគារកម្ពុជាមិនបិទទ្វារទេ ។ អាជ្ញាធរទាំងឡាយកាន់តែមានទំនោរទទួលឲ្យមានការចុះសួរទុក្ខដល់អ្នកទោសតាំងតែពីពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសមក ។ គោលនយោបាយបើកចំហរដល់ការទាក់ទងយ៉ាងនេះ ផ្ទុយទៅវិញនឹងបាត់ទៅវិញ បើកាលណាគ្មានគោលនយោបាយ និងការដឹកនាំច្បាស់លាស់ពីរដ្ឋាភិបាល ។

# ជំពូក ៨

## ពន្ធនាគារ PJ : បញ្ហានានាអាចខុសដូចម្ដេចទៅ !

### <u>សេចក្ដីផ្ដើម</u>

៩៣. ពន្ធនាគារ PJ (ពីប៉ូលីសតុលាការបារាំង) ស្ថិតនៅក្នុងកំផែងនៃទីស្នាក់ការប៉ូលីសភ្នំពេញ នៅលើផ្លូវលេខ ៥១ កណ្ដាលក្រុងភ្នំពេញ ។ ពន្ធនាគារនេះបានកសាងក្នុងឆ្នាំ ១៩៧៣ ធ្វើជាពន្ធនាគារប៉ូលីសរយៈពេលខ្លី និងត្រូវគេបង្កើតឡើងសំរាប់ដាក់អ្នកទោសពី ៣០ ទៅ ៤០ នាក់. អាគារ ហើយនិងបន្ទប់ជាប់ៗគ្នាសំរាប់អ្នកទោសស្ត្រី បានដាក់អ្នកទោស ២១៦ នាក់ នៅពេលដែលកម្មវិធី PAP បានចុះសួរសុខទុកជាលើកដំបូងបង្អស់កាលពីថ្ងៃទី ៤ មេសា ១៩៩៤ នោះ ។

៩៤. ប្រវែងរបងពន្ធនាគារ បណ្ដោយ ៣៥ ម៉ែត្រ និងទទឹង ១២ ម៉ែត្រ ហើយប្រវែងអាគារខាងក្រៅនៃប្លុកពន្ធនាគារ ទទឹង ១០ ម៉ែត្រ បណ្ដោយ ១៩ ម៉ែត្រ (មើលឧបសម្ព័ន្ធលេខ ៨) ។ ចំពោះពួកអ្នកជាប់ពន្ធនាគារដែលស្ថិតនៅទីនោះមាន ១៩៣ នាក់ជាបុរស ត្រូវបានដាក់ក្នុងប្លុកធំនៃពន្ធនាគារ ហើយនិង ២៣ នាក់ជាស្ត្រី ត្រូវបានគេដាក់ឲ្យនៅក្នុងអាគារទ្រុឌទ្រោម ។ មានអ្នកទោសតែ ៤១ នាក់ប៉ុណ្ណោះ ដែលត្រូវបានគេកាត់ឲ្យជាប់ទោស ។ ពួកអ្នកទោសដែលមានអាយុជាមធ្យម ២៦ ឆ្នាំ ហើយនិងអ្នកទោសបុរស ៤ នាក់មានអាយុក្រោម ១៨ ឆ្នាំ ។ រយៈពេលមធ្យមនៃការឃុំឃាំងមានរយៈពេល ៩ ខែ ។



## បញ្ហានានា

៩៥. បញ្ហានានាដែលកំពុងតែប្រឈមមុខចំពោះពន្ធនាគារ និងពួកអ្នកគ្រប់គ្រងពន្ធនាគារត្រូវគេបែងចែកជា ៧ បញ្ហា : ការដាក់អ្នកទោសលើសចំណុះ បញ្ហាសុខភាព អំពើហិង្សារវាងអ្នកទោសនិងអ្នកទោស ការខ្វះខាតទឹក ហើយនិងម្ហូបអាហារ អនាម័យ ការរំលោភលើអ្នកទោស ហើយនិងការគ្រប់គ្រង ។

## ការដាក់អ្នកទោសលើសចំណុះ

៩៦. ការរំលោភលើសិទ្ធិមនុស្សដែលកើតឡើងនៅក្នុងពន្ធនាគារនេះហើយ ដែលធ្វើឲ្យកាន់តែអាក្រក់បំផុតនៅក្នុងប្រទេសកម្ពុជានោះ គឺពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការដាក់អ្នកទោសលើសចំណុះនៅក្នុងពន្ធនាគារ ។ បញ្ហានេះពុំមែនជាបាតុភូតមួយរយៈពេលខ្លីទេ បញ្ហានេះកើតមានជានិច្ច ហើយនិងមានរយៈពេលយូរ ។

សំណុំឯកសារដែលបានទទួលពីផ្នែកសិទ្ធិមនុស្សរបស់អ៊ុនតាក់ បានបង្ហាញឲ្យឃើញថា នៅពេលជិតចប់អាណត្តិរបស់អ៊ុនតាក់ មានអ្នកទោសចំនួន ១៧១ នាក់ នៅក្នុងពន្ធនាគារ នៅខែកញ្ញា ១៩៩៣ ។ ចំនួននេះមានការកើនឡើងជាលំដាប់ ទោះជាពន្ធនាគារមួយចំនួនដែលអ្នកទោសច្រើន ឬតិច ត្រូវបានបិទទៅហើយក៏ដោយ (ពន្ធនាគារ T3 ហើយនិងពន្ធនាគារព្រៃស) ។

កំរិតនៃការដាក់អ្នកទោសហួសចំណុះនេះ គេអាចយល់បានយ៉ាងច្បាស់ ដោយសារគេបានចុះទៅសួរសុខទុក្ខដល់ពន្ធនាគារតែម្តង ។ ដូចដែលបានឃើញនៅក្នុងឧបសម្ព័ន្ធលេខ ៨ ស្រាប់ ពន្ធនាគារ PJ ត្រូវគេបែងចែកជា ១០ បន្ទប់ធំៗ ហើយ ៨ បន្ទប់ក្នុងចំណោម ១០ បន្ទប់នេះ មានទំហំប្រហែល ៨ ម៉ែត្របួនជ្រុង (បន្ទប់បន្ធនាគារ ១-៧-៩) ។ បន្ទប់ពន្ធនាគារទាំងនេះ ដាក់អ្នកទោសបុរសចំនួន ១៤៦ នាក់ ដោយទុកឲ្យអ្នកទោស ៨៧ នាក់ទៀតនៅក្នុងរបៀងពន្ធនាគារ ។ របៀងនេះត្រូវបានគេចាត់ទុកថា ជាទីកន្លែងដ៏ប្រសើររបស់ពួកអ្នកទោស ព្រោះថាវាមានកន្លែងស្រឡះ មានខ្យល់ចេញចូល និងពន្លឺល្អប្រសើរ ហើយពួកអ្នកទោសមានសេរីភាពចេញចូលរកទីកលុបលាងនិងផឹក ។ ពួកអ្នកទោសនៅតាមរបៀងនេះ បានចំណាយពេលច្រើន ដោយអង្គុយជាជួរនិងពុំមានធ្វើអ្វី ទោះបីជាអ្នកខ្លះមានវិទ្យុហើយនិងបៀរក៏ដោយ ។ ពួកអ្នកទោសនៅក្នុងបន្ទប់វិញមានការចុញចប់ ពីព្រោះពុំមានខ្យល់ចេញចូលស្រួល ខ្វះពន្លឺ បន្ទប់ចង្អៀត ។ ខ្យល់ចេញចូលហើយនិងពន្លឺជះចូលនោះគឺ តាមចន្លោះទ្វារតូចៗ ហើយនិងរបងខាងក្រៅ ។ ការដាក់អ្នកទោសហួសចំណុះនៅក្នុងបន្ទប់ដ៏តូចបែបនេះ

វាមានសភាពអាក្រក់ណាស់ ដែលអ្នកទោសត្រូវតែដេកនៅលើបង្គន់ ។ គេពុំបានផ្តត់ផ្គង់កន្ទេល ឬមុងទេ ។ ហេតុដូច្នេះហើយ ពួកអ្នកទោសមួយភាគបីត្រូវដេកផ្ទាល់នឹងដី ។ ពួកអ្នកទោសត្រូវបានគេចាក់សោរជាប់នៅក្នុងបន្ទប់របស់គេ ហើយនិងនៅក្នុងរបៀងរយៈពេល ២៤ ម៉ោងក្នុងមួយថ្ងៃ ។ ពួកអ្នកទោសដែលអាចចេញក្រៅប្លុកធំនោះបាន គឺពួកអ្នកដែលដាំស្ល ឬអ្នកដងទឹក ។ ពុំមានអ្នកទោសណាម្នាក់អាចហាត់ប្រាណបានឡើយ ។

## សុខភាព

៩៧. គិលានុបដ្ឋាយិកាម្នាក់ដែលធ្វើការបំរើអ្នកទោស ត្រូវបានគេចាត់ឲ្យដាក់វេនប្រចាំថ្ងៃ ហើយនិងពិនិត្យអ្នកទោសដែលឈឺ ។ នាងពុំមានសម្ភារៈបរិក្ខារពេទ្យ ឬថ្នាំពេទ្យប្រើប្រាស់ទេ ។ នៅពេលចុះពិនិត្យព្យាបាលអ្នកទោសម្តងៗ គិលានុបដ្ឋាយិកាត្រូវទិញសម្ភារៈនិងថ្នាំខ្លួនឯង ដោយពុំមានការធានាចំពោះសំណាងទេ នូវទឹកថ្នាំសំរាប់ចាក់សរសៃឲ្យអ្នកទោសដែលកើតជម្ងឺរាគ ហើយខ្វះជាតិទឹកនោះ ។

៩៨. ក្រុមចំរុះមួយក្រុមមកពីគ្រូពេទ្យពិភពលោក (MDM) ហើយនិងសម្ព័ន្ធកម្ពុជាសំរាប់ការជម្រុញ ហើយនិងការពារសិទ្ធិមនុស្ស (LICADHO) បានទៅសួរសុខទុក្ខនៅពន្ធនាគារពីល្ងាច ក្នុងសប្តាហ៍នីមួយៗ ។ ក្រុមចំរុះនេះមានរួមទាំងវេជ្ជបណ្ឌិតម្នាក់ខាងវះកាត់ គិលានុបដ្ឋាយិកាម្នាក់ ហើយនិងឱសថការីម្នាក់ ។ អង្គការមិនមែនរដ្ឋាភិបាលទាំងនេះ បានធ្វើការស្ថិតក្រោមភាពប្រឹងប្រែងអស់ពីសមត្ថភាព ហើយនិងអាចចូលរួមនៅក្នុងបញ្ហាបន្ទាន់ៗបំផុតផងដែរ ។

៩៩. ពុំមានការពិនិត្យ ឬជ្រើសរើសពួកអ្នកទោសនៅពេលមកដល់ទេ ហើយពួកអ្នកទោសដែលមានសញ្ញា ឬអាការរោគនៃជម្ងឺឆ្លង ក៏គេមិនដាក់ឲ្យនៅដោយឡែកពីគ្នាដែរ ។

១០០. គេគិតថា សភាពរស់នៅក្នុងពន្ធនាគារ គឺជាកត្តាមួយសំរាប់ការចម្លងនៃជម្ងឺរបេង ។ នៅក្នុងចំណោមពួកអ្នកទោសទាំងនោះ គេមិនសូវយកចិត្តទុកដាក់ពិនិត្យទេ អង្គការ ARC ហើយនិង PHR បានពិនិត្យឃើញអ្នកជាប់គុកម្នាក់កើតជម្ងឺរបេងក្រពេញ (Scrofula) ហើយនិងក្អករ៉ាំរ៉ៃ ។ តាមការពិនិត្យរបស់គេឲ្យដឹងថា អ្នកទោសមួយភាគបី (33.3%) កើតជម្ងឺក្អករ៉ាំរ៉ៃនេះ ។

១០១. ពួកអ្នកទោស ៥០% មានស្បែកខុសពីធម្មតា នៅពេលដែលអង្គការ ARC ហើយនិងអង្គការ PHR ចុះពិនិត្យ ។ អ្នកទោសពីរនាក់កើតជំងឺរមាស់ពេញខ្លួន ដែលអាចចម្លងរាលដាលដល់អ្នកដទៃ ដែលស្ថិតនៅក្រោមសភាពកកកុញមានកំដៅ ហើយនិងសំណើម

នោះ ។ ពួកអ្នកទោសជាងពាក់កណ្ដាលបានប្រកាសថា ខ្លួនគេបានកើតជំងឺរមាស់នេះនៅក្នុងពន្ធនាគារ ។ (កន្លងមកអង្គការ ICRC ហើយនិង MDM បានផ្ដល់ថ្នាំរមាស់រួចមកហើយ ។

១០២. ពួកអ្នកទោសគិតជាមធ្យម បានរាគរូសអស់ពេលជាងបីថ្ងៃ នៅក្នុងអំឡុងពេលមួយខែ មុនការចុះត្រួតពិនិត្យ ។ ពួកអ្នកទោសមួយភាគបួនរាយការណ៍ថា ទឹកដាំ ឬទឹកសុទ្ធអាចផឹកបាន ចំណែកអ្នកទោសបីភាគបួនវិញនិយាយថា ទឹកប្រភេទនេះផឹកមិនកើតទេ ។ គេនិយាយថា កន្លែងធ្វើម្ហូបគគ្រុច ហើយមានរុយ ធុងដាក់ម្ហូបអាហារ ហើយនិងគ្រឿងសម្ភារៈផ្ទះបាយអត់លាងសាប៊ូ ងាយស្រួលឲ្យជម្ងឺឆ្លងតទៅទៀត ។ នៅក្នុងចំណោមអ្នកទោស ៩ នាក់ ដែលត្រូវបានគេសម្ភាសន៍នៅក្នុងការត្រួតពិនិត្យទូទៅនោះ មាន ៦ នាក់និយាយថា សុខភាពរបស់គេ "មិន ល្អ" ។

## ការខ្វះខាតម្ហូបអាហារហើយនិងទឹក

១០៣. អ្នកទោសនៅក្នុងពន្ធនាគារ PJ បានទទួលទានបាយជាមួយសម្លម្ជូរតែមួយពេលប៉ុណ្ណោះ ក្នុងមួយថ្ងៃ ។ នៅតាមពន្ធនាគារទាំងអស់គេបានទទួលទានពីរពេល ។ គេបានសម្ភាសន៍អ្នកទោសទាំងអស់ ហើយពួកអ្នកដែលត្រូវគេទាក់ទងក្រៅផ្លូវការ បានរអ៊ូរទាំថា ពុំសូវមានម្ហូបអាហារគ្រប់គ្រាន់ទេ ។ ផ្ទះបាយគុកដែលជាប់នឹងប្លុកធំនៃពន្ធនាគារ គឺច្បាស់ជាមិនគ្រប់គ្រាន់ សំរាប់ចំនួនអ្នកទោសដ៏ច្រើននោះទេ ។ ទោះបីជាមានការស្ដារឡើងវិញនូវអណ្ដូងដែលមានស្រាប់ ចាក់សាបជុំវិញអណ្ដូង តម្លើងស្នប់សប់ដៃ ហើយនិងជួសជុលប្រព័ន្ធទទួលទឹកភ្លៀងនៅចុងឆ្នាំ ១៩៩៣ ដោយអង្គការ ICRC ក៏ដោយ ក៏នៅតែមានការខ្វះខាតទឹកដដែល ពួកអ្នកទោសហើយនិងមន្ត្រីគុកនិយាយ ។ ប្រព័ន្ធទឹកដែលភ្ជាប់ទៅនឹងការផ្គត់ផ្គង់ទឹកក្នុងទីក្រុង គឺច្បាស់ជាមិនគ្រប់គ្រាន់ទេ សំរាប់ចំនួនអ្នកទោសទាំងនោះ ។

១០៤. អ្នកទោស ១០ នាក់ ក្នុងចំណោមអ្នកទោស ១២ នាក់ ដែលត្រូវអង្គការ ARC ហើយនិង PHR សម្ភាសន៍នោះនិយាយថា ពួកគេស្រកទម្ងន់នៅក្នុងអំឡុងពេលជាប់គុកនោះ ។ អ្នកទោស ៥ នាក់និយាយថា គេកើតរោគស្ពឹក ដោយសារខ្វះវីតាមីន B ។

## អនាម័យ

១០៥. បន្ទប់គុកនីមួយៗមានបង្គន់មួយ ហើយនិងទឹក ប៉ុន្តែការផ្គត់ផ្គង់ទឹកជួលកាលរអាក់រអួល ។ បន្ទប់លេខ ៨ ហើយនិងលេខ ៩ បានរាំងស្ទះប្រព័ន្ធទឹក ហើយនិងលូទឹកស្អុយហើយក៏ត្រូវពួកមន្ត្រីពន្ធនាគារ ប្រើធ្វើជាបន្ទប់ធ្វើទារុណកម្មទៅវិញ ។

ពួកអ្នកទោសនៅក្នុងរបៀង មានសិទ្ធិប្រើស្តុកទឹកខាងក្នុងមួយ ដែលជានិច្ចកាលគ្មានទឹកនៅពេលគេមកមើល ហើយដែស្តុកនោះមានទឹករីមៀតែប៉ុណ្ណោះ ។ ទឹកដែលគេប្រើនោះគឺដងមកពីស្តុកខាងក្រៅមួយទៀត ជាប់នឹងប្លុកធំនៃពន្ធនាគារ ។ ពួកអ្នកទោសមានការខ្វះខាតចានបាយ ហើយនិងសម្ភារៈផ្សេងៗ ដូច្នេះគេត្រូវតែប្រើរួមគ្នា ។ នៅកន្លែងនោះមានក្លិនស្អុយដែលបញ្ជាក់ឲ្យឃើញថា មានសភាពគ្មានអនាម័យ ។ បន្ទប់គុកស្ត្រីចង្អៀត ប៉ុន្តែមានពន្លឺ ហើយនិងខ្យល់ចេញចូលគ្រាន់បើជាងបន្ទប់បុរស ។ ប៉ុន្តែបន្ទប់នោះលិច សើមដោយកន្លែង ហើយក្រខ្វក់ទៀតផង ។ គេបានរាយការណ៍ថា គ្រប់ផ្នែកទាំងអស់នៅក្នុងពន្ធនាគារសុទ្ធសឹងតែសើមទាំងអស់ ហើយលិចម្តងម្កាលនៅរដូវវស្សា ។

១០៦. ប្រព័ន្ធលូទឹកស្អុយដែលត្រូវបានជួសជុលឡើងវិញកាលពីឆ្នាំមុន ដោយកម្មវិធី WATSAN របស់ ICRC នោះត្រូវស្ទះញ៉ែកញាប់ ហើយហូរហៀរពាសពេញដូចដែលក្រុមPAP បានឃើញនឹងភ្នែកជាច្រើនលើកស្រាប់មកហើយ ។ ពួកអ្នកទោសមួយភាគបីរាយការណ៍ថា កណ្តុរប្រែងក៏ជាបញ្ហាមួយដែរ ។

## អំពើហឹង្សារវាងអ្នកទោសនិងអ្នកទោស

១០៧. លក្ខណៈមួយដែលពន្ធនាគារ TJ ល្បីឈ្មោះនិងខុសប្លែកពីគុកកម្ពុជាផ្សេងៗទៀតនោះ ត្រូវបានគេរាយការណ៍យ៉ាងខ្លាំងក្លា ពីកំរិតនៃអំពើហឹង្សារបស់ពួកអ្នកទោស ។ អ្នកសម្ភាសន៍ ៧ នាក់ក្នុងចំណោមអ្នកសម្ភាសន៍ ៩ នាក់ បានរាយការណ៍ថា នៅក្នុងចំណោមពួកអ្នកទោស មានការវាយប្រតប់គ្នាជាខ្លាំង ។

បញ្ហានេះ វាមិនដូចទៅនឹងពន្ធនាគារផ្សេងៗខ្លះទៀត ដែលបានរៀនសូត្រនោះទេ ។ ពន្ធនាគារកម្ពុជាជាទូទៅ ហាក់ដូចជាគ្មានអំពើហឹង្សារវាងអ្នកទោស និងអ្នកទោសខ្លាំងក្លាទេ ។ ចំពោះបញ្ហានេះ លើកលែងតែពន្ធនាគារ PJ ប្រហែលជាមកពីមានអ្នកទោសច្រើនពេក ហើយនិងបញ្ហាទាក់ទិនផ្សេងៗទៀត ដូចជាការខ្វះខាតទឹក ហើយនិងម្ហូបអាហារជាដើម ។

## ការរំលោភលើអ្នកទោស

១០៨. មានភស្តុតាងជាក់ស្តែងមួយអំពីការរំលោភលើអ្នកទោស ។ អ្នកទោស ៦ នាក់ក្នុងចំណោមអ្នកទោស ៩ នាក់ បានរាយការណ៍ថា ត្រូវបានគេវាយដំ ដោយឡែកអ្នកទោសទាំងអស់រាយការណ៍ថា រឿងនេះមានកើតឡើងមែន ។ បញ្ហានេះត្រូវបានគេគាំទ្រផងដែរ តាមភស្តុតាងជាក់ស្តែង បានមកពីការទាក់ទងក្រៅផ្លូវការ ។ ចំពោះបញ្ហានេះ មិនត្រឹមតែអ្នកទោសទេ

ដែលត្រូវគេបន្ទាបបន្ថោកភាពថ្លៃថ្នូរនៅក្នុងឱកាសជាប់គុក PJ នោះ ចំពោះពួកឆ្មាំគុកខ្លះក៏ដូច្នេះដែរ ។

## ការគ្រប់គ្រង

១០៩. បញ្ហានៅក្នុងគុកនេះ មានសភាពកាន់តែធ្ងន់ធ្ងរឡើង ដោយសារការរៀបចំការគ្រប់គ្រងនៅនឹងកន្លែង ។ ចំណែកឯពន្ធនាគារផ្សេងទៀតនៅក្នុងតំបន់ក្រុងភ្នំពេញ គឺស្ថិតនៅក្រោមការត្រួតត្រានិងគ្រប់គ្រងដោយផ្ទាល់របស់នាយកដ្ឋានគុករបស់ MI ប៉ុន្តែគុកនេះមិនមែនទេ ។ ពន្ធនាគារនេះ ទំនងជាស្ថិតនៅក្រោមការត្រួតត្រាដោយផ្ទាល់ របស់ស្នងការប៉ូលីសភ្នំពេញ ដោយមានការត្រួតត្រារួមគ្នាបន្តិចបន្តួច ដូចដែលគេបានឃើញនៅក្នុងពន្ធនាគារផ្សេងៗទៀត ។ បញ្ហានេះអាចពន្យល់ឲ្យឃើញថា គេពុំបានបញ្ជូនអ្នកទោសទៅកាន់ពន្ធនាគារផ្សេងដែលមិនសូវចង្អៀត ហើយដែលគុកទាំងនោះ មិនស្ថិតនៅក្រោមការត្រួតត្រាដោយផ្ទាល់របស់ស្នងការប៉ូលីសនោះ ។

## លទ្ធផល

១១០. សភាពធ្ងន់ធ្ងរនៅក្នុងពន្ធនាគារ PJ គឺវាដូច្នេះ ម្ល៉ោះហើយទើបមានកម្មវិធីពិសេសមួយចាប់ផ្តើមធ្វើអន្តរាគមន៍ ។ សេចក្តីរាយការណ៍មួយចុះថ្ងៃទី ១១ ឧសភា ១៩៩៤ ត្រូវបានធ្វើឡើង ហើយនិងត្រូវបញ្ជូនតទៅ MI, MJ ហើយនិងតំណាងពិសេសរបស់អគ្គលេខាធិការទទួលបន្ទុកផ្នែកសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ។ នៅថ្ងៃទី ២៧ ឧសភា លោកបានចុះសួរសុខទុក្ខពន្ធនាគារនេះ ហើយបានសរសេរលិខិតមួយច្បាប់ចុះថ្ងៃទី ២៧ ឧសភា ជូនរដ្ឋមន្ត្រីការបរទេសកម្ពុជា ដោយមានចម្លងជូន MI ហើយនិង MJ ផងដែរ ។ PHR បានចេញផ្សាយពត៌មានមួយ ដោយអំពាវនាវឲ្យបិទពន្ធនាគារនេះ ហើយសារពត៌មានមួយនេះ បានទទួលលទ្ធផល (មើលឧបសម្ព័ន្ធលេខ ៩) ។

ប្រធានស្នងការប៉ូលីសភ្នំពេញ បានព្រមព្រៀងផ្ទេរអ្នកទោសពីពន្ធនាគារ PJ បន្ទាប់ពីមានសំណូមពរមួយពីលោក Jusic Kirby រដ្ឋាភិបាលអូស្ត្រាលី ដែលបានផ្តល់ជំនួយជាលើកដំបូងចំនួន ៥០០០ដុល្លារអាមេរិក ដើម្បីចាប់ផ្តើមធ្វើការជួសជុលថ្មីខ្លះៗ ដែលជាមូលដ្ឋាននោះមក ។ ជំនួយនេះ ត្រូវធ្វើឡើងទៅលើការយោគយល់ដែលថា អ្នកទោសនៅក្នុងពន្ធនាគារ PJ នឹងត្រូវគេកាត់បន្ថយ ហើយនិងយោគយល់ថា គេអនុញ្ញាតឲ្យអ្នកទោសចេញក្រៅហាត់ប្រាណាបួនទៅប្រាំម៉ោងក្នុងមួយថ្ងៃ ហើយនិងអាងទឹកសំអុយ ដែលនឹងត្រូវបង្ហូរចេញនោះ ។ នៅពេលសរសេររបាយការណ៍ មានតែលក្ខខណ្ឌចុងក្រោយប៉ុណ្ណោះ ដែលមិនទាន់បំពេញ ។

នាយកដ្ឋានសំណង់របស់ MI បន្ទាប់មកបានព្រមព្រៀងចាប់ផ្តើមធ្វើការជួសជុលឡើងវិញ នៅក្បែរពន្ធនាគារព្រៃស ហើយនិងពន្ធនាគារ T3 ដើម្បីទទួលពួកអ្នកទោសទាំងនេះ ។ ប្រការនេះ សមទៅនឹងកិច្ចការ ហើយនិងប្រភេទដែលរដ្ឋាភិបាលអូស្ត្រាលីបានសន្យា ។ ជាលទ្ធផលគឺថា នៅពេលគេសរសេររបាយការណ៍ ពួកអ្នកទោសនៅក្នុងពន្ធនាគារ PJ ត្រូវបានគេកាត់បន្ថយចំនួន ១១ នាក់ ដែលនៅក្នុងចំណោមនោះ មានស្ត្រី ៤ នាក់ផងដែរនោះ ។ នៅក្នុងអំឡុងពេលនៃដំណើរការផ្ទេរនេះ យ៉ាងហោចណាស់ក៏មានអ្នកទោស ៥៤ នាក់ ត្រូវបានគេដោះលែងដែរ ។

១១១. វិស្វករដែលបំពើការនៅក្នុងកម្មវិធី WATSAN របស់អង្គការ ICRC នោះបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេសដ៏មានតម្លៃ ដល់ការជួសជុលឡើងវិញ ហើយនិងការចរចាជាមួយនាយកដ្ឋានសំណង់របស់ MI ។

១១២. មកដល់សព្វថ្ងៃនេះ អាងទឹកហើយនិងបង្គន់ត្រូវបានគេស្តារឡើងវិញហើយ ហើយជញ្ជាំងនិងពិដានត្រូវបានលាបកំបោរស បន្ទប់គុកស្ត្រីត្រូវបានប្រក់ដំបូលថ្មី ផ្ទះបាយត្រូវបានជួសជុល កៅអីវែងសំរាប់ដេកត្រូវបានគេយកទៅដាក់ក្នុងបន្ទប់ពន្ធនាគារ ហើយគេបានសង់របងខាងក្រៅ ដើម្បីអាចឲ្យអ្នកទោសហាត់ប្រាណ បង្អួចត្រូវបានពង្រីកឲ្យធំ បន្ទះដ៏រឹងមាំនៅពីលើទ្វារ ត្រូវបានដាក់ជំនួសដោយចម្រឹងដែក ហើយនិងបង្ហូរទឹកសំអុយចេញពីអាង ។ សមត្ថភាពផ្គត់ផ្គង់ទឹកត្រូវបានកែលំអ ដោយពង្រីកអាងទឹកឲ្យធំ តម្លើងទរទឹកដើម្បីត្រងទឹកភ្លៀង ហើយនិងដងបំពេញជាញឹកញាប់ទៀតផង ។

១១៣. មកទល់បច្ចុប្បន្ននេះ រដ្ឋាភិបាលអូស្ត្រាលីបានចំណាយប្រាក់ជាង ៧០០០ដុល្លារអាមេរិក នៅពន្ធនាគារ PJ ហើយនិងប្រហែល ៣០០០ដុល្លារនៅពន្ធនាគារព្រៃស ហើយនិង T3 ។

## <u>សេចក្តីសន្និដ្ឋាន</u>

១១៤. បញ្ហានានានៅក្នុងពន្ធនាគារ PJ ស្ថិតនៅក្នុងកំរិតធ្ងន់ធ្ងរមួយ ដូចគ្នាទៅនឹងពន្ធនាគារកម្ពុជាជាច្រើនទៀតដែរ ។ ចំនួនអ្នកទោសដ៏ច្រើនសន្ធឹកសន្ធាប់នេះ បានធ្វើឲ្យបាត់បង់នូវប្រព័ន្ធមួយ ទាំងលទ្ធភាពទទួលយកអ្នកទោស ហើយនិងការគ្រប់គ្រងនៅពេលមានបញ្ហាកើតឡើង ។ ការផ្លាស់ប្តូរនេះ ផ្តួចផ្តើមឡើងដោយកម្មវិធី PAP អាស្រ័យដោយកិច្ចសហការដ៏មានប្រសិទ្ធិភាពរវាងក្រុមអន្តរវិន័យ ហើយនិងអន្តរទីភ្នាក់ងារ ដែលមានការជឿ

ទុកចិត្ត និងមានការគាំទ្រពីរដ្ឋបាលទទួលខុសត្រូវ ។ ការឆ្លើយតបរបស់ប៉ូលីសក្រុងភ្នំពេញ MI ហើយនិង PJ មានការទទួលខុសត្រូវនិងមានប្រសិទ្ធភាព នៅពេលមានប្រភពធន់ធាន (ទោះជាតិចតួចក៏ដោយ) ។ បញ្ហានេះ ក៏បានបង្ហាញឲ្យឃើញផងដែរថា សុខមាលភាពរបស់អ្នកទោសជាច្រើន ហើយនិងករណីខ្លះ គឺជីវិតរបស់គេអាចត្រូវគេជួយសង្គ្រោះតាមប្រភពធន់ធានថវិកាតិចតួច និងតាមរយៈគំរោងសកម្មភាពនៃកិច្ចសហប្រតិបត្តិការ ។

# ជំពូក ៩

## សៀមរាប : ទីណាមានការព្យាយាម ទីនោះនឹងបានសំរេច

១១៥. ពន្ធនាគារសៀមរាប គឺជាគុកមួយកសាងនៅក្នុងឆ្នាំ ១៩៤០ ដោយរដ្ឋការអាណានិគមបារាំង ។ នៅពេលកម្មវិធី PAP ចុះពិនិត្យសួរសុខទុក្ខកាលពីខែមិថុនា ១៩៩៤ នោះគុកនេះដាក់អ្នកទោស ៩៨ នាក់ ហើយក្នុងចំណោមអ្នកទោស ៩៨ នាក់នេះមាន ២៨ នាក់មិនទាន់កាត់ទោស និងមានស្ត្រី ៨ នាក់ ។ ស្ថិតនៅក្នុងបរិវេណដ៏ធំទូលាយ ដែលនៅក្នុងជំនាន់ប៉ុល ពត គេរាយការណ៍ថា មានអ្នកទោសជាងពីរពាន់នាក់នោះ ។ ទីកន្លែងគុកតូចដោយកំផែងខាងក្រៅមានទទឹងប្រវែង ៥៧ ម៉ែត្រ បណ្តោយ ៣៥ ម៉ែត្រ (មើលឧបសម្ព័ន្ធលេខ១០) ។ ថ្មីមដំបូលពុក ហើយស៊ីម៉ង់ត៍ក៏ពុកផុយដែរ ដោយឡែកកន្លែងផ្ទះបាយជាកន្លែងងងឹត ចាំបាច់ត្រូវជួសជុលកែលំអឡើងវិញ ។ ចំពោះប្រការទាំងអស់នេះ គុកកម្ពុជាគឺជារឿងធម្មតាទៅហើយ ។ ប៉ុន្តែសៀមរាប គឺជាគុកមួយដែលដាក់អ្នកទោសច្រើនលើសគុកផ្សេងទៀតទាំងអស់ នៅក្នុងការសិក្សារបស់យើង ។ កត្តាសំខាន់នៃការខុសប្លែកគ្នានេះ គឺជាឥរិយាបថមួយមានការចាត់ចែងកំរិតខ្ពស់ ។ ដោយសារប្រការនេះហើយ ទើបគេអះអាងថា សៀមរាបគឺជាពន្ធនាគារមួយល្អ ។

## កំណត់សំគាល់លើករណីទី ៨

### គុកខ្មែរក្រហម : កត់ត្រាពីបទសម្ភាសន៍មួយ ជាមួយអ្នកនៅរស់ម្នាក់ ២

នៅក្នុងអំឡុងពេលខ្មែរក្រហមកាន់កាប់ គុកសៀមរាបមានអ្នកទោសប្រមាណ ២.៥០០ នាក់ ។ ពួកអ្នកទោសភាគច្រើន ត្រូវគេដាក់ឲ្យនៅតាមបរិវេណកណ្តាលវាលជុំវិញអាគារគុក ។ ពួកគេពុំមានជម្រក ហើយនិងគ្រែដេកទេ ។ នៅក្នុងបន្ទប់គុកពីរ ដែលឥឡូវនេះដាក់អ្នកទោស

ពី ២០ ទៅ ៣០ នាក់នោះ មានអ្នកទោស ១២៥ នាក់ក្នុងបន្ទប់នីមួយៗ ។ នៅក្នុងអំឡុងឆ្នាំ ១៩៧៨ មានអ្នកទោសប្រហែល ៣០ នាក់ ស្លាប់ក្នុងមួយថ្ងៃ ។ ដោយសារភាពទុរ្ភិក្ស ជម្ងឺ ឬសម្លាប់ ។ ជួនកាលគេយកពួកអ្នកទោសទាំងក្រុមៗទៅសម្លាប់ ។ គេផ្ដល់ឲ្យពួកអ្នកទោសនូវបបរាវដោយមានអង្ករបួនដប់គ្រាប់ប៉ុណ្ណោះ ។ ជាប់គុកបីខែដំបូង ជើងហើយនិងដៃរបស់ខ្ញុំជាប់ខ្នោះច្រវាក់ ២៤ ម៉ោងក្នុងមួយថ្ងៃ ជាមួយនិងអ្នកទោស ៧ នាក់ទៀតនៅក្នុងបន្ទប់ងងឹតតូចមួយ ។ យើងបានទទួលទឹកតែមួយចុងប៉ុណ្ណោះក្នុងមួយថ្ងៃ ។ បន្ទាប់ពីនេះ គេអនុញ្ញាតឲ្យខ្ញុំចេញពីបន្ទប់គុក ប៉ុន្តែជើងនៅតែជាប់ខ្នោះរយៈពេល ២៤ ម៉ោងដដែល ។ ខ្ញុំមានខោខ្លីពីរប៉ុណ្ណោះ ដែលជាសម្លៀកបំពាក់របស់ខ្ញុំ ខ្ញុំកើតជម្ងឺកមរមាស់ ហើយនិងគ្រុនចាញ់ ។ យើងដេកផ្ទាល់នឹងដី សូម្បីតែភ្លៀងក៏ដោយ ។

ពួកអ្នកជាប់គុកជាមួយយើងដែលមានមុខជំនាញ ត្រូវបានគេប្រមូលឲ្យនៅម្ដុំនៅក្នុងបន្ទប់គុកមួយ ហើយនៅពេលថ្ងៃត្រូវចេញធ្វើការជួសជុលរបស់របរ ។

មានអ្នកយាមប្រហែល ៧០ នាក់រង់ចាំធ្វើការវាយដំ ហើយនិងធ្វើទារុណកម្មជាប់ជានិច្ច ។

ខ្ញុំមានជីវិតរស់នៅ ដោយសារខ្ញុំមានមុខជំនាញ ។ មានថ្ងៃមួយ ខ្ញុំត្រូវបានគេនាំយកទៅសម្លាប់ ប៉ុន្តែមានម៉ាស៊ីនមួយខូច ហើយគេត្រូវការឲ្យខ្ញុំជួសជុល ដូច្នេះខ្ញុំក៏មានជីវិតរស់មកទល់សព្វថ្ងៃនេះ ។

១១៦. ពួកអ្នកទោសត្រូវសំអាតបន្ទប់មួយថ្ងៃពីរដង ហើយនិងដុសលាងបង្គន់ ។ ពួកអ្នកទោសត្រូវគេកំណត់ឲ្យមានកម្មវិធីហាត់ប្រាណទៀងទាត់ រត់ជុំវិញទីធ្លាខាងក្នុង ហើយនិងហាត់ក្រាបដើបលើទម្រដៃរាប់ដល់ប្រាំ ពីរលើកក្នុងមួយថ្ងៃ ។ មានទីធ្លាលេងបាល់ទះសំរាប់អ្នកទោស ហើយនិងកន្លែងទាត់សី ។ មានរោងជាងឈើ ហើយនិងកន្លែងធ្វើមងសំណាញ់ និងមានម៉ាស៊ីនដេរប្រើទៀងផង ។ គេបានបញ្ចាំងវិដេអូឲ្យអ្នកទោសមើលក្នុងមួយសប្ដាហ៍ម្ដង ហើយនិងមានគ្រឿងឧបករណ៍តន្ត្រីប្រពៃណីជាច្រើនឲ្យប្រើ ។ ពួកអ្នកទោសមានសិទ្ធិស្ដាប់វិទ្យុ អានកាសែត សៀវភៅ ហើយនិងមានការសិក្សាទៀតផង ។

១១៧. គេអនុញ្ញាតឲ្យអ្នកទោសចេញក្រៅបន្ទប់ឃុំឃាំងរបស់គេ យ៉ាងតិចក៏ ៤ ម៉ោងដែរក្នុងមួយថ្ងៃ ហើយអ្នកទោសជាច្រើន ត្រូវបានគេអនុញ្ញាតឲ្យចេញក្រៅរយៈពេលយូរជាងនេះ ។ ក្នុងមួយខែៗគេអនុញ្ញាតឲ្យមានថ្ងៃទាក់ទងគ្នាបីថ្ងៃ (ថ្ងៃទី១០ ទី២០ និងទី៣០) ។ ទោះបីជាគេឲ្យសួរសុខទុកជាមធ្យមត្រឹម ១៥ នាទីក៏ដោយ ។

១១៨. មន្ទីរព្យាបាលត្រូវបើកពិនិត្យរាល់ថ្ងៃ ទោះជាពេទ្យពុំមានគ្រឿងឧបករណ៍ ហើយនិងមានថ្នាំពេទ្យផ្គត់ផ្គង់តិចតួចក៏ដោយ ។ ប៉ុន្តែពួកអ្នកទោស ត្រូវបានគេពិនិត្យជម្ងឺដោយមានប្រសិទ្ធភាព និងយកចិត្តទុកដាក់ ហើយបញ្ជូនទៅកាន់មន្ទីរពេទ្យពេលណាចាំបាច់ ។

១១៩. ភាពស្មុគ្រស្មាញពិសេសមួយ ដែលពន្ធនាគារនេះជួបប្រទះនោះ ពន្ធនាគារនេះតូចចង្អៀត ហើយត្រូវដាក់អ្នកទោសឲ្យនៅដោយឡែកពីគ្នាទៀតនោះ ។ បន្ទប់ឃុំឃាំងស្ត្រីមិនត្រូវបានគេបែងចែកឲ្យបានគ្រប់គ្រាន់ដោយឡែកពីបន្ទប់បុរសទេ ។ ប៉ុន្តែអ្នកទោសដែលត្រូវគេកាត់ឲ្យជាប់ទោស ហើយនិងអ្នកដែលមិនទាន់កាត់ទោស ត្រូវគេដាក់ឲ្យនៅដោយឡែកពីគ្នា នៅក្នុងអំឡុងពេលជាប់ពន្ធនាគារក្នុងបន្ទប់រៀងៗខ្លួនរបស់គេ ។

១២០. អ្នកទោសពីរនាក់ដែលនៅតែព្យាយាមរត់គេចនោះ ត្រូវបានគេដាក់ខ្នោះច្រវាក់ ។ ក៏ប៉ុន្តែពុំមានការធ្វើទារុណកម្មវាយដំច្រំធាក់ ឬដាក់គុកឲ្យនៅតែឯង ត្រូវបានគេរាយការណ៍ នៅក្នុងពន្ធនាគារនេះទេ ។ គេបានដាក់វិន័យលែងឲ្យមានការដើរហេតរហូត ឬធ្វើឲ្យមានស្នូរសម្លេងនៅជុំវិញទីធ្លាពន្ធនាគារ ។ ជាអកុសលគេនៅតែប្រើ"របៀបហាត់ប្រាណដោយប្រើម្រាមដៃចង្អុល" គឺតម្រូវឲ្យអ្នកទោសម្នាក់ចង្អុលម្រាមដៃទៅនឹងដី ដោយដាក់ក្បាលចុះក្រោម ហើយបង្វិលឲ្យគាត់ ហើយនិងបង្វិលខ្លួនរហូតទាល់តែគាត់វិលមុខហើយដួល ។

១២១. ពន្ធនាគារនេះមានឈ្មោះល្បីផងដែរ ដោយសារខ្លួនបានបើកឲ្យមានកិច្ចសហប្រតិបត្តិចំហរជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងក្នុងស្រុក ក្នុងនោះរួមមាន REDD Barna., Concern ហើយនិង ADHOC ។ ADHOC គឺជាក្រុមដើម្បីសិទ្ធិមនុស្សក្នុងស្រុកមួយ ដែលចុះសួរសុខទុក្ខដល់ពន្ធនាគាររៀងរាល់ថ្ងៃសុក្រ ។ ក្រុមសិទ្ធិមនុស្សនេះ ក៏នឹងសួរសុខទុក្ខផងដែរ នៅពេលមានអ្នកទោសឈឺធ្ងន់ ដើម្បីជួយពិនិត្យព្យាបាល ហើយនិងជួយដល់ NGOs ផ្សេងៗទៀត ដើម្បីអាចឲ្យគេចូលទៅក្នុងពន្ធនាគារបាន ។ អង្គការ Concern បានជួយជាមួយនិងអង្គការនេះ ដោយកសាងសួនច្បារមួយ ផ្គត់ផ្គង់ពូជបន្លែ ហើយនិងប្រដាប់ប្រដាសួនច្បារ ។

១២២. បញ្ហាសំខាន់មួយតាមពួកអ្នកទោសបានសំដែងឲ្យដឹងនៅក្នុងពន្ធនាគារនេះ វាដូចទៅនឹងពន្ធនាគារផ្សេងៗទៀតទាំងអស់ដែរ គឺបញ្ហាខ្វះខាងម្ហូបអាហារ ។ ពួកអ្នកយាមគុកក៏ទទួលស្គាល់ផងដែរថា បញ្ហាខ្វះស្បៀងអាហារនេះ គឺជាបញ្ហាសំខាន់ ។

១២៣. បញ្ហានានាដែលទាក់ទិនទៅនិងពន្ធនាគារផ្សេងៗ ដូចជាការពន្យារពេលយ៉ាងយូរមុនការកាត់ទោស ហើយនិងការមិនបង្ហាញអ្នកទោសនោះ នៅតែមានដដែល ។ គេកប្រេបណ្ដុះបណ្ដាលបុគ្គលិកធ្វើការក្នុងពន្ធនាគារនេះ ដូចពន្ធនាគារផ្សេងៗណាស់ ។

១២៤. អ្វីដែលខុសប្លែកនៅទីនេះ គឺការខំប្រឹងប្រែងយកចិត្តទុកដាក់នៅក្នុងជួរបុគ្គលិកជាន់ខ្ពស់ដែលព្យាយាម ហើយនិងឲ្យផ្ដល់ការសង្គ្រោះដល់ពួកអ្នកទោសយ៉ាងសកម្មទៅតាមលទ្ធភាព ។ បញ្ហានេះ ត្រូវបានពង្រឹងដោយមានវត្តមានដ៏សកម្មរបស់អង្គការទាំងឡាយដែលមានមូលក្នុងសហគមន៍ក្នុងស្រុក ។ ការទាក់ទងរវាងទិដ្ឋភាពទាំងនេះ ហើយនិងការកែលំអសន្តិសុខ គឺពុំមានការខូចខាតអ្វីឡើយចំពោះបុគ្គលិកពន្ធនាគារទេ ។

## ១. កម្មវិធីអក្ខរកម្ម

១.១. នាយកដ្ឋានពន្ធនាគារ បានអនុវត្តកម្មវិធីអក្ខរកម្មមួយនៅក្នុងពន្ធនាគារនានាតាមលទ្ធភាពដែលអាចធ្វើទៅបាន ដោយមានជំនួយពីក្រុមសិទ្ធិមនុស្ស ឬអង្គការមិនមែនរដ្ឋាភិបាល NGOs) ផ្សេងទៀត ។ កម្មវិធីបែបនេះ គួរតែបើកធ្វើតិចបំផុត ពី ៤ ទៅ ៨ ម៉ោងក្នុងមួយសប្ដាហ៍ នៅក្នុងពន្ធនាគារនីមួយៗ ហើយគួរឲ្យអ្នកទោសទាំងអស់ចូលរួមក្នុងកម្មវិធីនេះ ។

១.២. កម្មវិធីសំរាប់កម្មវិធីអក្ខរកម្មនេះ ត្រូវឲ្យអង្គការ NGOs ជាអ្នករៀបចំ ហើយដាក់ជូនក្រសួងមហាផ្ទៃ ហើយនិងក្រសួងយុត្តិធម៌អនុម័ត ។

១.៣. នាយកពន្ធនាគារម្នាក់ៗត្រូវជ្រើសតាំង"មន្ត្រីអប់រំអក្ខរកម្ម" ម្នាក់ ដើម្បីជួយចាត់ចែងកម្មវិធីខាងលើ ជ្រើសរើសអ្នកទោសណាដែលសមរម្យ ហើយរាយការណ៍អំពីការរីកចំរើននៃវគ្គសិក្សាជូននាយកដែលនឹងរាយការណ៍បន្ត ស្ដីពីការរីកចំរើននេះតទៅទៀត ជូនក្រសួងមហាផ្ទៃ ហើយនិងការិយាល័យខេត្តក្រុង ។

## ២. ពិធីសារសន្តិសុខ ហើយនិងបញ្ហាអាវុធ

២.១. គេត្រូវណែនាំឲ្យនាយកពន្ធនាគារម្នាក់ ព្រាងពិធីសារមួយស្ដីពីសន្តិសុខ សំរាប់រក្សាសន្តិសុខនៅក្នុងពន្ធនាគារ ។ ពិធីសារនេះ ត្រូវរួមបញ្ចូលទាំងចំនួនអ្នកយាមល្បាតដែលមានអាវុធ និងគ្មានអាវុធ នៅរាល់ម៉ោងនៃថ្ងៃល្បាត ហើយនិងចំនួនមន្ត្រីពន្ធនាគារដែលចូលរួម, ចំនួនអ្នកយាមមានអាវុធ និងគ្មានអាវុធ ស្ថិតនៅក្នុងពន្ធនាគារនៅម៉ោងណាក៏ដោយ, ទំ-

វង់ការឆ្លើយតបទៅនឹងភាពអាសន្ន ឬលួចរត់ ការខ្វះខាត ឬបញ្ហានានានៅក្នុងការរក្សាសន្តិសុខនៅក្នុងពន្ធនាគារ ។

២.២. បន្ទាប់ពីទទួលពត៌មាននេះហើយ ក្រសួងមហាផ្ទៃត្រូវព្រាង«ពិធីសារសន្តិសុខមួយមានលក្ខណៈឯកភាព» ដែលនឹងដាក់ឲ្យពន្ធនាគារទាំងអស់អនុវត្ត ។ ភ្ជាប់ជាមួយ «ពិធីសារសន្តិសុខឯកភាព» នោះគឺ «ពិធីសារសន្តិសុខជាក់លាក់មួយ» ដែលនឹងត្រូវមានការណែនាំជាក់លាក់ ដើម្បីរក្សាសន្តិសុខនៅក្នុងគុកពិសេស ដែលក្រសួងចេញពិធីសារនេះឲ្យ ។ ពិធីសារសន្តិសុខតាមលក្ខណៈឯកភាព ហើយនិងពិធីសារសន្តិសុខជាក់លាក់ ត្រូវតែចេញប្រើតាមរយៈបទបញ្ជាមួយរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

២.៣. ចំណែក"ពិធីសារសន្តិសុខឯកភាព" នេះ ក្រសួងមហាផ្ទៃត្រូវចេញច្បាប់ សំរាប់ការប្រើអាវុធដោយពួកមន្ត្រីពន្ធនាគារ ។ ក្នុងការបង្កើតច្បាប់ទាំងនេះ ត្រូវតែយោងតាម និងអនុវត្តតាមគោលការណ៍ណែនាំដែលមានចែងនៅក្នុងគោលការណ៍ ជាមូលដ្ឋាន សំរាប់ការប្រើកម្លាំង ហើយនិងប្រើអាវុធដោយពួកមន្ត្រីពង្រឹងច្បាប់ ។ ជាពិសេស ត្រូវតែបញ្ជាក់ឲ្យបានច្បាស់ នៅពេលណាដែលពួកភ្នាក់ងារពន្ធនាគារមិនអាចប្រើប្រាស់អាវុធទាំងនោះ ។

## ៣. ច្បាប់ពន្ធនាគារ

៣.១. កែប្រែច្បាប់ដែលមានស្រាប់ ដែលគេចេញឲ្យប្រើជាលើកដំបូងបង្អស់ក្នុងឆ្នាំ ១៩៧៩ សំរាប់ពួកអ្នកទោស នៅតាមពន្ធនាគារអនុវត្ត ហើយនិងព្រាងច្បាប់ថ្មីមួយ ។

៣.២. ក្រុមការងារមួយក្រុម មានអ្នកតំណាងពីរនាក់មកពីក្រសួងមហាផ្ទៃ ហើយនិងក្រសួងយុត្តិធម៌ ដែលត្រូវអញ្ជើញចូលរួមប្រជុំ ហើយនិងត្រូវអញ្ជើញឲ្យដឹកនាំអង្គប្រជុំ ដើម្បីព្រាងច្បាប់ថ្មីមួយ ។

៣.៣. ក្រុមការងារខាងលើនេះ នឹងធ្វើកិច្ចសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌល អ.ស.ប. ដើម្បីសិទ្ធិមនុស្ស ហើយនិងទីភ្នាក់ងារដែលជាប់ទាក់ទិនផ្សេងៗទៀត ដើម្បីជួយជ្រោមជ្រែងនៅក្នុងដំណើរការនេះ ។

៣.៤. ក្រុមការងារខាងលើនេះពិចារណានៅក្នុងចំណោមប្រការផ្សេងទៀត លើករណី SMRTP ហើយនិងគោលការណ៍នានាជាមូលដ្ឋាន សំរាប់អនុវត្តនៅលើពួកអ្នកទោស នៅពេលគេព្រាងច្បាប់ថ្មី ។

៣.៥. ច្បាប់ថ្មីនេះ នឹងត្រូវគេបញ្ចូលទៅក្នុងប្រកាសរបស់ក្រសួងដែលជាប់ពាក់ព័ន្ធ និងត្រូវបានអនុម័តក្រោមនីតិបញ្ញត្តិដែលទាក់ទិន ។

## ៤. សុខភាពក្នុងពន្ធនាគារ ហើយនិងសេវាកម្មពេទ្យ

៤.១. ក្រសួងយុត្តិធម៌ត្រូវចេញជាបន្ទាន់នូវសេចក្តីណែនាំមួយ ជូនទៅព្រះរាជអាជ្ញាទាំងអស់ ដើម្បីឲ្យគេរៀបចំបញ្ជូនពួកអ្នកទោសទៅកាន់មន្ទីរពេទ្យ នៅពេលនាយកពន្ធនាគារ និងមន្ត្រីពេទ្យប្រចាំនៅពន្ធនាគារនោះ មានសំណូមពរឲ្យធ្វើយ៉ាងនោះ ។

៤.២. នាយកដ្ឋានពន្ធនាគារនៃក្រសួងមហាផ្ទៃ នឹងទាក់ទងជាមួយអង្គការសុខភាពពិភពលោក ដើម្បីសម្រួលការអនុវត្តន៍ការពិនិត្យជម្ងឺរបេង និងពិនិត្យជម្ងឺ HIV/AIDS ហើយនិងវិធានការការពារសុខភាពផ្សេងៗទៀតនៅក្នុងគុក នៅពេលដែលចាំបាច់ ។

៤.៣. នាយកពន្ធនាគារម្នាក់ៗត្រូវជ្រើសរើស"ប្រធានពេទ្យម្នាក់" ហើយនិង"ជំនួយការប្រធានពេទ្យ" ពីរនាក់ ហើយមន្ត្រីពេទ្យបែបនេះ នឹងទទួលការបណ្តុះបណ្តាលពីអង្គការសុខភាពកម្ពុជា ហើយនិងសម្ព័ន្ធភាពសិទ្ធិមនុស្ស ។

៤.៤. ត្រូវប្រកាន់យកវិធានការដើម្បីដាក់ពួកអ្នកទោសដែលកើតជម្ងឺឆ្លង ឲ្យនៅដាច់ដោយឡែកពីគ្នា ។

៤.៥. ប្រធានពេទ្យបង្កើតនិងរក្សាសំណុំឯកសារពេទ្យ ស្តីពីអ្នកទោសម្នាក់ៗ ដែលនឹងត្រូវរក្សាទុក ហើយនិងឲ្យទាន់ពេលវេលាជានិច្ច ។

៤.៦. ពន្ធនាគារនីមួយៗ ត្រូវតែរក្សាបន្ទប់ពិនិត្យជម្ងឺដោយឡែកមួយ ដោយមានតុ ហើយនិងគ្រែពិនិត្យជម្ងឺ និងជាកន្លែងដែលគេរក្សាទុកសំណុំឯកសារពន្ធនាគារ ហើយនិងថ្នាំចាក់ការពារជំនួយបន្ទាន់ ហើយនិងការផ្តល់ថ្នាំសំរាប់ជម្ងឺធម្មតា ដែលគេអាចគ្រប់គ្រងបាន ។

៤.៧. ប្រធានពេទ្យ ឬជំនួយការប្រធានពេទ្យ អាចចូលរួមនៅក្នុងពេលភ្នាក់ងារពេទ្យ NGOs ចុះសួរសុខទុក្ខនិងពិនិត្យជម្ងឺអ្នកទោស ។

៤.៨. នាយកដ្ឋានសុខាភិបាល ក្រសួងមហាផ្ទៃ ហើយនិងក្រសួងយុត្តិធម៌ ក្នុងការពិគ្រោះពិភាក្សាជាមួយគណកម្មាធិការជនភៀសខ្លួនអាមេរិក គ្រូពេទ្យពិភពលោក ហើយនិងអង្គការ LICADHO បានរៀបចំពិធីសារមួយ សំរាប់ការពិនិត្យទំនុកបំរុងពួកអ្នកទោស ហើយថាពិធីសារមួយបែបនេះ ត្រូវចេញឲ្យនាយកពន្ធនាគារទាំងអស់ ហើយនិងនាយកមន្ទីរពេទ្យ ដើម្បីណែនាំពួកគេក្នុងការព្យាបាលពួកអ្នកទោស ។

៤.៩. ពួកអ្នកទោសវិកលចរិត ឬកំពុងទទួលរងនូវជម្ងឺសសៃប្រសាទធ្ងន់ធ្ងរនោះ មិនត្រូវឃុំឃាំងនៅក្នុងពន្ធនាគារទេ ។

៤.១០. អ្នកទោសថ្មីនីមួយៗនៅពេលមកដល់ក្នុងពន្ធនាគារ ត្រូវឲ្យពេទ្យពិនិត្យមុននឹងចូលដល់មណ្ឌលគុកធំ ហើយនិងកសាងសំណុំឯកសារ ស្តីពីសភាពជម្ងឺរបស់គេ ។ ប្រសិនបើគេសង្ស័យថា អ្នកទោសនោះកើតជម្ងឺឆ្លង ឬឈឺធ្ងន់ ឬក៏របួសនោះ ត្រូវបញ្ជូនជាបន្ទាន់ទៅកាន់មន្ទីរពេទ្យក្នុងស្រុក ។ ប្រសិនបើអ្នកទោសកើតជម្ងឺឆ្លង ពេលនោះនឹងត្រូវគេដាក់ឲ្យនៅដាច់ដោយឡែកពីអ្នកដទៃ ។

៤.១១. អ្នកជាប់គុកទាំងអស់ ត្រូវតែមានសិទ្ធិប្រើប្រាស់ទឹក ហើយនិងបង្គន់ ។

៤.១២. គុកទាំងឡាយ ត្រូវតែរក្សាឲ្យបានស្អាតគ្រប់ពេលវេលា ក្នុងនោះរួមមានទាំងបន្ទប់គុក ហើយនិងកន្លែងទូទៅនានា ។

៤.១៣. នៅក្នុងពន្ធនាគារដែលមានអ្នកទោសច្រើនលើសចំណុះ គេត្រូវចែកចន្លោះកន្លែងឲ្យបានស្មើៗគ្នា សំរាប់ឲ្យអ្នកទោសដេកនៅ ។

៤.១៤. នៅក្នុងពន្ធនាគារដែលមានអ្នកទោសកកកុញ រយៈពេលនៅខាងក្រៅបន្ទប់ពន្ធនាគារ ត្រូវតែបន្ថែមឲ្យវែងទៀត ។

## ៥. ការកសាងពន្ធនាគារឡើងវិញ

៥.១. ក្រសួងមហាផ្ទៃ បានទាក់ទងជាមួយកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដើម្បីបញ្ជាក់ឲ្យច្បាស់ពីការប្រើប្រាស់មូលនិធិតទៅទៀត សំរាប់ការកសាងគុកឡើងវិញ ។

៥.២. រាជរដ្ឋាភិបាលកម្ពុជា បានអំពាវនាវដល់បណ្តារដ្ឋាភិបាល ដែលយកចិត្តទុកដាក់ផ្តល់ជំនួយឲ្យផ្តល់មូលនិធិ សំរាប់ធ្វើឲ្យពន្ធនាគារអភិវឌ្ឍន៍សារជាថ្មី ។

៥.៣. ក្រសួងមហាផ្ទៃបានបង្កើតកម្មវិធីកសាង ហើយនិងកិច្ចអភិវឌ្ឍន៍ជាថ្មីមួយ សំរាប់ពន្ធនាគារនានា ដែលជ្រើសរើសកិច្ចការថែរក្សាបន្ទាន់ នៅក្នុងពន្ធនាគានីមួយៗ ហើយនិងតម្រូវឲ្យមានការជួសជុលជាថ្មីឡើងវិញច្រើននិងតិច ហើយនិងកសាងឡើងវិញនៅក្នុងពន្ធនាគារនីមួយៗ ។

## ៦. ការដាក់អ្នកទោសឱ្យនៅដាច់ដោយឡែកពីគ្នា

៦.១. តាម SMRTP គឺថា ត្រូវតែប្រកាន់យកវិធានការបន្ទាន់ ដើម្បីដាក់អ្នកទោសដែលកាត់ទោសរួចហើយ និងអ្នកដែលមិនទាន់កាត់ទោសឲ្យនៅដាច់ដោយឡែកពីគ្នា ។ ជាពិសេស ចាំបាច់ត្រូវមានការពិនិត្យឡើងវិញឲ្យបានឆាប់ ទៀងទាត់ដើម្បីរក្សាអ្នកទោស មុនការកាត់ទោសនៅក្នុងគុក នៅពេលដែលគេពិនិត្យឃើញថា ពួកគេគឺជាជនស្លូតត្រង់នោះ ។

៦.២. ពួកអ្នកទោសស្រ្តី ត្រូវដាក់ឲ្យនៅដោយឡែកពីអ្នកទោសបុរស តាមលទ្ធភាពដែលអាចធ្វើទៅបាន ក្នុងនោះរួមមានការប្រើកន្លែងកំសាន្ត ហើយនិងកន្លែងងូតទឹកដោយឡែកពីគ្នាផងដែរ ។

៦.៣. ពួកអ្នកទោសយុវជន ត្រូវដាក់ឲ្យនៅដោយឡែកពីអ្នកទោសដទៃទៀត ហើយគេត្រូវបង្កើតស្ថាប័នដោយឡែកមួយ សំរាប់អ្នកទោសយុវជននៅជិតក្រុងភ្នំពេញ តាមលទ្ធ-ភាពដែលអាចធ្វើទៅបាន ។

៦.៤. យោងតាមស្ថានការសេដ្ឋកិច្ច និងស្ថានការសង្គម ពួកអ្នកជាប់គុកមិនត្រូវគេចាត់ជាក្រុមជាពួកទេ ។

៦.៥. អ្នកមិនទាន់កាត់ទោស មានសំលៀកឯកសណ្ឋានគុកមួយខុសៗគ្នា ដែលត្រូវគេបែងចែកដោយយោងតាម SMRTP នីមួយៗ ។

## ៧. ការចុះឈ្មោះ ហើយនិងបញ្ជីពន្ធនាគារ

៧.១. ទម្រង់គំរូមួយ ត្រូវរៀបចំឡើងសំរាប់ការចុះឈ្មោះទាំងអស់ក្នុងពន្ធនាគារស្របទៅតាម SMRTP ។

៧.២. ការរក្សាទម្រង់បញ្ជីគំរូមួយ ត្រូវបង្កើតឲ្យមាននៅក្នុងពន្ធនាគារនីមួយៗ ក្រោមការណែនាំរបស់ក្រសួងមហាផ្ទៃ ។ ហើយទម្រង់គំរូនេះ ត្រូវបញ្ជូនសំណុំរឿងដោយឡែកៗស្តីពីអ្នកទោសម្នាក់ៗ ហើយនិងមានរួមទាំងការទទួលទុកទ្រព្យសម្បត្តិរបស់អ្នកទោស ការសរសេរទាក់ទងគ្នាជាផ្លូវការ ហើយនិងការផ្តល់ឯកសារដែលទាក់ទងនឹងអ្នកទោស ។

## ៨. ការផ្គត់ផ្គង់សម្ភារៈដេក និងសម្លៀកបំពាក់ដល់អ្នកទោស

៨.១. អ្នកទោសម្នាក់ៗនឹងត្រូវគេផ្គត់ផ្គង់កន្ទេល ភួយ មុង នៅពេលគេចូលមកដល់ពន្ធនាគារ ហើយសម្ភារៈទាំងនេះ ត្រូវផ្លាស់ថ្មីជារៀងរាល់ឆ្នាំ ។

៨.២. អ្នកទោសម្នាក់ៗ ត្រូវគេចែកសម្លៀកបំពាក់ពីរសំរាប់ នៅពេលចូលពន្ធនាគារ លើកលែងតែអ្នកដែលមិនទាន់កាត់ទោស ត្រូវផ្តល់សិទ្ធិឲ្យគេជ្រើសរើសក្នុងការស្លៀកពាក់នូវសម្លៀកបំពាក់របស់ខ្លួនគេ ។

៨.៣. នៅក្នុងពន្ធនាគារនីមួយៗ គេត្រូវចាត់អ្នកទោសពីរ ឬបីនាក់ ឲ្យធ្វើជា "ជាងកាត់សក់" សំរាប់កាត់សក់ឲ្យពួកអ្នកទោសផ្សេងៗទៀត ។

## ៩. ម្ហូបអាហារ

៩.១. ក្នុងមួយថ្ងៃត្រូវមានម្ហូបអាហារពីរពេលឲ្យអ្នកទោស ។

៩.២. ក្នុងមួយពេល ឬពីរពេលក្នុងមួយថ្ងៃនោះ ត្រូវមានត្រី សាច់ ឬបន្លែ ។

៩.៣. របបម្ហូបអាហារប្រចាំថ្ងៃសំរាប់អ្នកទោសម្នាក់ៗ ត្រូវអោយមានគ្រប់គ្រាន់ ដើម្បីរក្សាសុខភាពល្អ ហើយនិងកម្លាំងមាំមួន ។

៩.៤. របបប្រចាំថ្ងៃ (ដែលបច្ចុប្បន្នមានចំនួន ១.០០០រ ក្នុងមួយថ្ងៃ) គួរតែបន្ថែមបន្ថយជារៀងរាល់ឆ្នាំ ។

៩.៥. ថ្ងៃអុសដុតមិនត្រូវកាត់ពីរបបប្រចាំថ្ងៃនេះទេ ។

៩.៦. ប្រធានពន្ធនាគារម្នាក់ៗ ត្រូវជ្រើសរើសភ្នាក់ងារម្នាក់ ដើម្បីត្រួតពិនិត្យសេចក្តីត្រូវការ ការរៀបចំ ហើយនិងការផ្គត់ផ្គង់ម្ហូបអាហារដល់ពួកអ្នកទោស ហើយនិងធ្វើរបាយការណ៍ជូនប្រធានពន្ធនាគារកន្លះខែម្តង ស្តីពីបញ្ហានេះ ។

## ១០. ការហាត់ប្រាណ ហើយនិងកីឡា

១០.១. អនុប្រធានពន្ធនាគារម្នាក់ៗ ជាមួយនិងមន្ត្រីជាន់ខ្ពស់ផ្សេងទៀត ត្រូវបង្កើតឲ្យមានគណៈកម្មាធិការ "ហាត់ប្រាណហើយនិងកីឡា" មួយ ដែលនឹងរៀបចំរបបហាត់ប្រាណសំរាប់ពន្ធនាគារ ។ របបនេះរួមមាន ៖

- ហាត់ប្រាណយ៉ាងតិចមួយម៉ោងក្នុងមួយថ្ងៃ សំរាប់អ្នកទោសម្នាក់ៗ.

- មានអង្គការកម្មវិធីកីឡាមួយទៀងទាត់ (បាល់ទះ ។ល។) សំរាប់អ្នកទោសទាំងអស់ដែលយកចិត្តទុកដាក់ ។

១០.២. អ្នកទោសទាំងអស់នៅក្នុងពន្ធនាគារកម្ពុជា ត្រូវបានគេអនុញ្ញាតឲ្យចេញក្រៅបន្ទប់គុករបស់គេយ៉ាងតិច ៥ ម៉ោង ក្នុងមួយថ្ងៃ លើកលែងតែកន្លែងណាដែលមានគ្រោះថ្នាក់សន្តិសុខធ្ងន់ធ្ងរ ។

## ១១. វិន័យ ហើយនិងការដាក់ទណ្ឌកម្ម

១១.១. ក្រសួងមហាផ្ទៃត្រូវបង្កើតពិធីសារមួយ ស្តីពីវិន័យ ហើយនិងការធ្វើទារុណកម្ម ឲ្យសមទៅតាមគំរូរបស់អ.ស.ប. សំរាប់ពន្ធនាគារទាំងអស់ ។ ពិធីសារនេះ ត្រូវតែហាមនូវគ្រប់អំពើឃោរឃៅ ហើយនិងការធ្វើទារុណកម្មមិនគប្បី ក្នុងនោះរួមមានវិធីធ្វើទុណ្ឌកម្មដូចតទៅ ៖

- ការដាក់ខ្នោះច្រវ៉ាក់
- ការបង្អត់ម្ហូបអាហារ
- ការដាក់ឲ្យនៅឯកោនៅក្នុងបន្ទប់តូច ឬងងឹត
- ការវាយដំ
- អោយឈរហាលថ្ងៃរយៈពេលយូរ
- ហាត់ប្រាណ"ប្រើម្រាមដៃអង្គុល"គឺបង្ខំឲ្យអ្នកទោស ប្រើម្រាមដៃមួយចង្អុលផ្ចុងនឹងដីបង្វិលខ្លួនជុំវិញ (ដែលបណ្តាលឲ្យងងឹតមុខ)
- មិនឲ្យក្រុមគ្រួសារគេចុះសួរសុខទុក្ខ

១១.២. ការប្រើអ្នកទោសឲ្យពង្រឹងវិន័យទៅលើអ្នកទោសផ្សេងទៀត ត្រូវហាមឃាត់ដាច់ខាត ។

## ១២. ការទាក់ទងខាងក្រៅ

១២.១. រដ្ឋាភិបាលគួរតែចេញច្បាប់ដែលតម្រូវឲ្យពួកអាជ្ញាធរចាប់ចង ជូនដំណឹងដល់បងប្អូនសាច់ញាតិ ឬនៅក្នុងករណីជាជនបរទេស ដែលទាក់ទិនទៅនឹងបុគ្គលិកការទូតឲ្យដឹងក្នុងរយៈពេល ២៤ ម៉ោងនៃការចាប់ខ្លួន ។

១២.២. គេត្រូវអនុញ្ញាតឲ្យអ្នកទោសសរសេរសំបុត្រឆ្លើយឆ្លង ហើយនិងទទួល អានកាសែត ទស្សនាវដ្តី ស្តាប់វិទ្យុ ទូរទស្សន៍ ហើយនិងពត៌មានផ្សេងៗ ។

១២.៣. ពួកអ្នកទោសត្រូវមានសិទ្ធិជួបមិត្តភក្តិ និងបងប្អូនយ៉ាងតិចក៏ ៤ ដងដែរក្នុងមួយខែ ហើយការមកសួរសុខទុក្ខយ៉ាងតិច ក៏មួយម៉ោង ។

១២.៤. អាជ្ញាធរពន្ធនាគារ គួរតែជូនដំណឹងដល់បងប្អូនសាច់ញាតិអ្នកទោសឲ្យដឹងពីការបញ្ជូនអ្នកទោស មានជម្ងឺធ្ងន់ធ្ងរ ឬស្លាប់ក្នុងអំឡុងពេល ២៤ ម៉ោង ។ ត្រូវធ្វើការស៊ើបអង្កេតដោយឯករាជ្យមួយ ទៅលើសាកសពរបស់អ្នកទោសមួយណាក៏ដោយ ។

១២.៥. មេធាវី ឬស្មាក្តីរបស់អ្នកទោស មកសួរនាំពួកគេនៅពេលណាក៏បាន តាមការសមស្រប ។

១២.៦. អង្គការ NGOs ផ្នែកសិទ្ធិមនុស្ស គួរមានសិទ្ធិចូលទៅក្នុងពន្ធនាគារទាំងឡាយ ដោយផ្អែកលើមូលដ្ឋានទៀតទាត់មួយ ។

១២.៧. ដើម្បីហេតុផលសន្តិសុខ គេគួរតែស្រាវជ្រាវស៊ើបសួរបងប្អូនសាច់ញាតិអ្នកទោសនៅពេលចាំបាច់ ហើយស៊ើបសួរតែមនុស្សណាដែលមានភេទដូចៗគ្នា ។

១២.៨. រដ្ឋាភិបាល ត្រូវតែបង្កើតនយោបាយមួយទៅលើការសួរសុខទុក្ខ នៅក្នុងពន្ធនាគារ ដោយមានគ្រឿងផ្សាយពត៌មាន ។

១២.៩. គួរតែអនុញ្ញាតឲ្យលោកសង្ឃ និងយាយជី ដែលមកសួរសុខទុក្ខធម្មតានោះចូលពន្ធនាគារ ។

## ១៣. បុគ្គលិកពន្ធនាគារ

១៣.១. តាមអង្គការ SMRTP ឲ្យដឹងថា តាមរយៈនាយកដ្ឋានបណ្តុះបណ្តាលរបស់ក្រសួងមហាផ្ទៃ គួរតែបង្កើតកម្មវិធីបញ្ចូលគ្នាមួយ រយៈពេលបីខែ សំរាប់ភ្នាក់ងារពន្ធនាគារដែលទើបជ្រើសរើសថ្មីទាំងអស់ ។ ការិយាល័យកម្ពុជា អាចផ្តល់ជំនួយនៅក្នុងការត្រៀមរៀបចំ ហើយនិងការបើកវគ្គនេះ ។

## ១៤. ការត្រួតពិនិត្យ

១៤.១. ការត្រួតពិនិត្យ នឹងត្រូវធ្វើឡើងដោយមានការចូលរួមពីសំណាក់ក្រុមប្រតិភូតុលាការ ហើយនិងព្រះរាជអាជ្ញារួមមកពីតុលាការក្នុងស្រុក យ៉ាងហោចណាស់ក៏មួយខែម្តង

យកល្អពីរដងក្នុងមួយខែ ។ របាយការណ៍របស់ពន្ធនាគារទាំងនេះ នឹងត្រូវបញ្ជូនទៅឲ្យក្រសួងមហាផ្ទៃ ហើយនិងក្រសួងយុត្តិធម៌ ។

១៤.២. ទម្រង់គំរូសំរាប់ធ្វើរបាយការណ៍ នឹងត្រូវអនុវត្តសំរាប់គោលដៅត្រួតពិនិត្យ ដែលបានបង្ហាញនៅក្នុងអនុសាសន៍ ១៤.១. ។

១៤.៣. រដ្ឋាភិបាលត្រូវជួយសមាជិកសភាជាតិ ជាពិសេសអង្គការសិទ្ធិមនុស្ស ហើយគណៈកម្មការទទួលពាក្យបណ្តឹងឲ្យចូលសួរសុខទុក្ខ ហើយនិងត្រួតពិនិត្យពន្ធនាគារ ។

## ១៥. ការងារពលកម្ម

១៥.១. ពលកម្មបង្ខំ ត្រូវហាមឃាត់

១៥.២. ក្រសួងមហាផ្ទៃគួរតែបង្កើតគោលការណ៍មួយ ដែលទាក់ទិនទៅនឹងឱកាសពលកម្មសំរាប់ពួកអ្នកទោស ស្របទៅតាម SMRTP ។ ជាពិសេស ការងារទាំងអស់ ជាការងារមានប្រយោជន៍ មិនមែនការងារអាជីវកម្មទេ ។ នយោបាយនេះ គួរតែកែលំអ ឬរក្សាមុខជំនាញរបស់អ្នកទោស ។

១៥.៣. នាយកពន្ធនាគារនៅក្នុងពន្ធនាគារនីមួយៗ ត្រូវជ្រើសតាំង "ប្រធានការងារម្នាក់" ដើម្បីរៀបចំ និងគ្រប់គ្រងកម្មវិធីការងារមួយ ស្របទៅតាម SMRTP ។ គួរតែមានប្រព័ន្ធមួយ ចេញថ្លៃសងដែលមានគុណធម៌ សំរាប់ការងារពលកម្មរបស់អ្នកទោស ។ គេត្រូវតែចំណាយឲ្យអ្នកទោសយ៉ាងហោចណាស់ ក៏មួយចំណែកនៃប្រាក់ដែលរកបាន សំរាប់ការប្រើប្រាស់ផ្ទាល់ខ្លួនរបស់គេដែរ ។

១៥.៤. បើមានលទ្ធភាព ពន្ធនាគារទាំងអស់គួរតែផ្តល់ឱកាសដល់អ្នកទោស ដើម្បីធ្វើសួនដាំបន្លែ ។

## ១៦. រដ្ឋបាល

១៦.១. ក្រុមការងាររួមមួយ ដែលត្រូវតែងតាំងដោយរដ្ឋាភិបាលនោះ ត្រូវតែពិនិត្យការរៀបចំផ្នែករដ្ឋបាល ដែលពាក់ព័ន្ធទៅនឹងពន្ធនាគារនានា ។ ក្រុមការងាររួមនេះ ត្រូវមានអ្នកតំណាងមកពីក្រសួងនានា ហើយនិងបណ្តាទីភ្នាក់ងារខាងក្រៅ ដែលមានបទពិសោធន៍ខាងកិច្ចការពន្ធនាគារ ។ ក្រុមការងាររួមនេះ ត្រូវតែពិនិត្យនូវបញ្ហានានាដូចខាងក្រោមនេះ ៖

- ទីតាំងរដ្ឋបាលរបស់ពន្ធនាគារនៅក្នុងក្រសួងមហាផ្ទៃ ហើយនិងលទ្ធភាពពីទីកន្លែងរដ្ឋបាលនេះ ទៅកាន់ក្រសួងមួយទៀត ។
- ការអនុវត្តន៍ក្រិត្យលេខ ៣១
- តួនាទីរបស់ប៉ូលីសនៅក្នុងរដ្ឋបាលពន្ធនាគារ
- ការទាក់ទងពត៌មានជាមួយពន្ធនាគារ
- រចនាសម្ព័ន្ធនៃការគ្រប់គ្រងពន្ធនាគារ

## ១៧. នីតិបញ្ញត្តិ

១៧.១. ច្បាប់កិរិតអប្បបរិមា (SMRTP) នឹងត្រូវអនុម័តបញ្ចូលទៅក្នុងនីតិបញ្ញត្តិ ។

## ១៨. ការលួចរត់

១៨.១. ពួកអ្នកទោសដែលលួចរត់ចេញពីពន្ធនាគារ ត្រូវដោះស្រាយតាមច្បាប់ ។

១៨.២. នីតិបញ្ញត្តិ ហើយនិងបទបញ្ជានានា ដែលខាងក្រោមនេះត្រូវតែធានាឲ្យបានថា ពួកអ្នកទោសដែលលួចរត់ចេញពីពន្ធនាគារនោះ នឹងត្រូវគេចោទប្រកាន់ និងកាត់ទោសទៅតាមច្បាប់ដែលបានចែង ។

១៨.៣. នីតិបញ្ញត្តិ ហើយនិងបទបញ្ជាខាងក្រោម ត្រូវធ្វើឡើងសំរាប់ដាក់ទោសចំពោះអ្នកទោសណាដែលលួចរត់ចេញពីពន្ធនាគារ ហើយបន្ទាប់មក ត្រូវបានគេចាប់ខ្លួនម្តងទៀត ដោយត្រូវទទួលការធ្វើទារុណកម្មមិនស្របច្បាប់ ឬទារុណកម្មដែលច្បាប់មិនបានចែង ។

## ១៩. ការបញ្ជូនអ្នកទោស

១៩.១. ត្រូវធានាឲ្យបានថា អ្នកទោសដែលត្រូវគេបញ្ជូនពីពន្ធនាគារមួយ ទៅកាន់កន្លែងមួយទៀតនោះ នឹងធ្វើឡើងតាមបទបញ្ជារបស់ចៅក្រម ឬព្រះរាជអាជ្ញា ។

## ២០. ស្ត្រី

២០.១. ត្រូវធានាឲ្យបានថា អ្នកទោសស្ត្រីត្រូវដាក់ឲ្យនៅដោយឡែកពីអ្នកទោសបុរស ។

២០.២. កន្លែងក់សាន្ត ហើយនិងកន្លែងផ្សេងៗសំរាប់អ្នកទោសស្ត្រី ត្រូវធ្វើឲ្យដាច់ដោយឡែកពីកន្លែងរបស់អ្នកទោសបុរស បើសិនជាអាច ។

២០.៣. ត្រូវធានាឲ្យបានថា ការរំលោភលើភេទ ឬការរំលោភផ្សេងៗលើអ្នកទោសស្ត្រី នោះ គឺជាទោសឧក្រិដ្ឋ ។

២០.៤. ត្រូវធានាឲ្យបានថា សេចក្តីត្រូវការចាំបាច់ពិសេសរបស់អ្នកទោសស្ត្រី ត្រូវបានគេទទួលស្គាល់ថា មាននៅក្នុងច្បាប់ ហើយនិងបទបញ្ជាទាំងអស់ដែលពាក់ព័ន្ធទៅនឹងពន្ធនាគារ ហើយនិងស្របទៅតាម SMRTP ។

២០.៥. នៅក្នុងពន្ធនាគារទាំងអស់ អ្នកទោសស្ត្រីត្រូវស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ភ្នាក់ងារពន្ធនាគារស្រី ។

២០.៦. ត្រូវធ្វើការជ្រើសរើសពិសេសមួយ ដើម្បីប្រើភ្នាក់ងារពន្ធនាគារស្ត្រីនៅក្នុងពន្ធនាគារនីមួយៗ ធ្វើការពិនិត្យអ្នកទោសស្ត្រី ។

២០.៧. អ្នកទោសស្ត្រីត្រូវមានការថែទាំខ្លួនមុនពេលសំរាលកូន ឬក្រោយពេលសំរាលកូន បញ្ហានេះនឹងត្រូវគេផ្គត់ផ្គង់ ហើយនិងចាត់ថាជាបញ្ហាត្រឹមត្រូវ ។

២០.៨. ទារកដែលកំពុងបៅ ត្រូវអនុញ្ញាតឲ្យនៅជាមួយមាតារបស់គេ ហើយត្រូវផ្តល់សេចក្តីត្រូវការពិសេសសំរាប់ទារក ។

## ២១. អ្នកទោសយុវជន

២១.១. គំរោងសំរាប់មជ្ឈមណ្ឌលឯកទេសដែលឃុំអ្នកទោសយុវជន និងសំរាប់យុវជនដែលមានអាយុក្រោម ១៨ ឆ្នាំនោះ នឹងបានទទួលការគិតគូរក្នុងការផ្តល់មូលនិធិមុនគេ ។

២១.២. នៅពេលយុវជនត្រូវបានគេឃុំឃាំងនៅក្នុងពន្ធនាគារនោះ នឹងត្រូវគេដាក់ឲ្យនៅដោយឡែកពីប្រភេទអ្នកទោសផ្សេងៗ ។

២១.៣. ចំពោះសេចក្តីត្រូវការរបស់អ្នកទោសយុវជន គេត្រូវទទួលស្គាល់ថាមាននៅក្នុងច្បាប់ ហើយនិងបទបញ្ជាទាំងអស់ដែលទាក់ទងទៅនឹងពន្ធនាគារ និងស្របទៅតាម SM RTP ហើយនិងច្បាប់សំរាប់អ្នកទោសយុវជន ។

## ២២. ការបិទពន្ធនាគារ T3 ហើយនិងការរើទៅកាន់ពន្ធនាគារព្រៃស

២២.១ ត្រូវធានាឲ្យបានថា មូលដ្ឋានពន្ធនាគារព្រៃស ត្រូវតែធ្វើឲ្យបានល្អប្រសើរ ដើម្បីទទួលយកអ្នកទោសឲ្យបានច្រើន ហើយពិសេសគឺថា :

- ត្រូវមានការផ្គត់ផ្គង់ទឹកឲ្យបានគ្រប់គ្រាន់ សំរាប់ពន្ធនាគារ
- ត្រូវមានសម្ភារៈដឹកជញ្ជូនគ្រប់គ្រាន់សំរាប់នាយកដ្ឋានពន្ធនាគារ ដើម្បីងាយស្រួលក្នុងការដឹកជញ្ជូនអ្នកទោសពីព្រៃសទៅតុលាការ ពីតុលាការទៅកាន់ព្រៃស ហើយនិងមូលដ្ឋានផ្សេងៗទៀត ។
- ត្រូវផ្គត់ផ្គង់ពន្ធនាគារព្រៃសនូវស្បៀងអាហារឲ្យបានល្អប្រសើរ ពីព្រោះពន្ធនាគារនេះ នៅឆ្ងាយដាច់ពីគេ ។
- ត្រូវផ្តល់សម្ភារៈបរិក្ខាពេទ្យឲ្យបានគ្រប់គ្រាន់ដល់ពន្ធនាគារព្រៃស ។

២២.២. ត្រូវបង្កើតមូលដ្ឋានមួយ សំរាប់ឃុំខ្លួនរយៈពេលខ្លីនៅតំបន់កណ្តាលក្រុងភ្នំពេញ ដើម្បីឃុំអ្នកទោសនៅក្នុងអំឡុងពេលកាត់ទោស ហើយនិងរង់ចាំការបញ្ជូនអ្នកទោសនោះទៅកាន់ពន្ធនាគារព្រៃស ។

## ២៣. អនាម័យ ហើយនិងអនាម័យបុគ្គល

២៣.១. នាយកពន្ធនាគារទាំងអស់ ត្រូវធានាឲ្យបាននូវការសំអាតបន្ទប់ពន្ធនាគារ ហើយនិងសម្ភារៈផ្សេងៗឲ្យបានស្អាតល្អជារៀងរាល់ថ្ងៃ ។

២៣.២. ប្រព័ន្ធអាងទទួលទឹកស្អុយនៅក្នុងពន្ធនាគារទាំងអស់ ត្រូវពិនិត្យជារៀងរាល់សប្តាហ៍ ហើយនិងត្រូវបូមចេញពីរខែម្តង និងធានានូវការប្រើប្រាស់ឲ្យមានប្រសិទ្ធភាព ។

២៣.៣. ត្រូវចែកគ្រឿងឧបភោគបរិភោគឲ្យអ្នកទោសម្នាក់ នៅពេលចូលពន្ធនាគារ ។

២៣.៤. គោលការណ៍ណែនាំសំរាប់រក្សាគំរូអនាម័យឲ្យបានត្រឹមត្រូវនោះ និងត្រូវចេញឲ្យនាយកពន្ធនាគារទាំងអស់ ។ បញ្ហានេះគួររួមមាន :

- ការផ្តល់សាប៊ូឲ្យពន្ធនាគារទាំងអស់
- មានសិទ្ធិចូលបង្គន់គ្រប់គ្រាន់
- ការផ្តល់សម្ភារៈងូតទឹកគ្រប់គ្រាន់

២៣.៥. ប្រធានពេទ្យដែលគេជ្រើសតាំងឲ្យប្រចាំការនៅក្នុងពន្ធនាគារនីមួយនោះៗ ត្រូវតែត្រួតពិនិត្យប្រឹក្សាយោបល់ឲ្យបានទៀតទាត់ ជាមួយនាយកពន្ធនាគារស្តីពី :

- បរិមាណ គុណភាព ការរៀបចំ ហើយនិងសេវាកម្ម ម្ហូបអាហារ
- អនាម័យ ហើយនិងការសំអាតពន្ធនាគារជាទូទៅ
- ប្រតិបត្តិតាមច្បាប់ដែលពាក់ព័ន្ធទៅនឹងការកំសាន្ត

២៣.៦. នាយកពន្ធនាគារត្រូវទទួលការណែនាំ ហើយនិងការផ្ដែផ្ដាំរបស់អនុប្រធានពេទ្យនៅក្នុងលេខ ២៣.៥ ហើយនិងប្រកាន់យកនូវវិធានការបន្ទាន់ ដើម្បីអនុវត្តឲ្យដូចៗគ្នាតាមលទ្ធភាព នៅទីណាក៏ដោយ ។

## ២៤. ការឃុំខ្លួនមុនកាត់ទោស (ការចាប់ខ្លួន ការដកប្រាក់ធានា ហើយនិងការសួរចម្លើយ)

២៤.១. ការឃុំខ្លួនមុនពេលកាត់ទោស ជានិច្ចកាលគប្បីរាប់ថាជាពេលវេលាជាប់ទោស ហើយមិនឲ្យលើសពីការកាត់ទោសអតិបរមា សំរាប់ទោសកំហុសដែលត្រូវចោទប្រកាន់លើអ្នកជាប់ឃុំ ។

២៤.២. រយៈពេលឃុំខ្លួនមួយថ្ងៃៗក្នុងរយៈពេលមុនការកាត់ទោស ដែលកំណត់ឡើងដោយច្បាប់ (ក្នុងពេលបច្ចុប្បន្ន តាម(ខ) ដែលបានចែងបណ្ដោះអាសន្ន ស្ដីពីបទឧក្រិដ្ឋមានរយៈពេលបួនខែ ឬក្នុងករណីខ្លះ មានរយៈប្រាំមួយខែ) នឹងត្រូវរាប់ថាជាប់ឃុំបីថ្ងៃ ហើយនិងត្រូវកាត់បន្ថយរយៈពេលតាមរបៀបនេះចេញពីការកាត់ទោសណាមួយ ដែលត្រូវធ្វើឡើង ។ ខ ដែលបានចែងនេះ គប្បីត្រូវបញ្ចូលទៅក្នុងលក្ខន្តិកៈច្បាប់ដែលជាប់ពាក់ព័ន្ធ ។

២៤.៣. អ្នកទោសទាំងអស់ដែលត្រូវគេចោទប្រកាន់ពីបទប្រព្រឹត្តខុសនោះ មានសិទ្ធិប្រើប្រាក់ធានា (ការដោះលែងមានលក្ខខណ្ឌមុនការកាត់ទោស) ។ ខ ដែលបានចែងនេះ គប្បីត្រូវបញ្ចូលនៅក្នុងលក្ខន្តិកៈច្បាប់ដែលជាប់ពាក់ព័ន្ធ ។

## ២៥. កម្មវិធីកាត់ទោស ហើយនិងកម្មវិធីដោះលែងមុនពេលកំណត់

